ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ក្រឡេកក្រឡប់ទៅកាន់ចិរវេលា៧៥ឆ្នាំមុន បន្ទាប់ពីវត្តមាននៃអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

◆ ហោរអដ្ឋិធាតុ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨៨ ខែធ្នូ ឆ្នាំ២០២៣

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨៨ ខែធ្នូ ឆ្នាំ២០២៣

## មាតិកា

### សំបុត្រ

◆ ក្រឡេកត្រឡប់ទៅកាន់ថិរវេលា៧៥ឆ្នាំមុន បន្ទាប់ពីវត្តមាននៃអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍............ ១

### ផ្នែកឯកសារ

◆ ភេ ឌី ត្រូវបានខ្មែរក្រហមចាប់ខ្លួនដោយសារ..... ៤

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ... ៧
◆ ហោអដ្ឋិធាតុ........................................១០
◆ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមចូលរួមផ្សព្វផ្សាយ និងអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម.......... ១៤
◆ យុវជនកម្ពុជាទីមួយ ណាល់ ស៊ីហ៊ិន ដារិទ្ធ ដែលសិក្សានៅសាលារាជបណ្ឌិត្យសភាយោធាចក្រភពអង់គ្លេស ទទួលបាន«ពានរង្វាន់ការសិក្សាអំពីសង្គ្រាម»... ១៦
◆ កែវ ម៉ុន ៖ អតីតកងចល័តលើកទំនប់ត្រយ៉បេក..១៩
◆ គង់ សុខ ៖ ខ្ញុំនៅតែសោកស្តាយដោយសារ...២១
◆ ជឹម យ៉ុម ៖ ឪពុកខ្ញុំធ្លាក់ខ្លួនឈឺស្លាប់ដោយសារ ...២៣
◆ ជុំ សារ៉េត ៖ លាក់ប្រវត្តិរូបព្រោះខ្លាចខ្មែរ..... ២៥
◆ បងស្រី ប្រាក់ អឿន និងប្តីរួមទាំងកូន៧៨នាក់.. ២៧
◆ ប្រាក់ អ៊ី ៖ ក្រុមគ្រួសារខ្ញុំប្រគល់មាសប្រាក់ ... ២៩
◆ សៀង ស៊ុណាត ៖ អតីតកងចល័តលើកទំនប់.. ៣១
◆ សៀង ហេន ៖ អតីតកងចល័តនារីវ័យ ........ ៣៣
◆ កង សេង ៖ កងកុមាររបស់អង្គការ .......... ៣៥
◆ ឆាយ ម៉ៅ ៖ អតីតកងទ័ពការពារព្រំដែន ..... ៣៧
◆ ឆែម គិះ ៖ កុមារអង្គការ ......................... ៤០
◆ ប៉ិច ប៉ាន់ ៖ ប្រធានសហករណ៍តាម៉ៅ ជើង...... ៤២
◆ សូ លន ៖ កងចល័តក្នុងរបបខ្មែរក្រហម...... ៤៤
◆ សួង ឆេង ៖ កងនារីភូមិតាម៉ៅ កើតក្នុង........ ៤៦



ប្រជាជនកម្ពុជាវិលត្រឡប់មកផ្ទះសម្បែង និងភូមិកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមខ្មែរក្រហម ដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

◆ សួន ឃឿយ ៖ កងទ័ពខ្មែរក្រហមប្រចាំតំបន់... ៤៩
◆ ហែម ភណ្ឌ័ ៖ អតីកងនារីផលិតអំបិល.......... ៥១
◆ ខេង សាអ៊ុត ៖ កងចល័តរបស់អង្គការ........ ៥៣

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលបានការសរសើរទៅលើកិច្ចសហការអង្គការជាដៃគូ ...៥៥

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ ស៊ីន សាលីន ៖ ខ្ញុំបាត់បងប្រុសម្នាក់ធ្លាប់ធ្វើពេទ្យក្នុងរបបខ្មែរក្រហម ................................. ៥៩

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, សូ ហ្វារីណា, មីន សាណាស់, សោម ប៊ុនថន, លី ដេវីត, ទូច វណ្ណេត, ទាវ សម្ផស្ស, សេន ពន្លឺ, រី ស៊ីថា, សាំង ចាន់ធូ, ធី គីមហុង, មេក វិន, វន បុប្ផា, ចាន់ ណារិទ្ធ, ណឹម ស្រីណែត និង ឈុំ ភ៉ា
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ុភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ក្រឡេកត្រឡប់ទៅកាន់ថិរវេលា៧៥ឆ្នាំមុន បន្ទាប់ពីវត្តមាននៃអនុសញ្ញាស្ដីពីការបង្ការ និង ផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

*ឆាំង យុ និង សូ ហ្វារីណា*



ប្រជាជនកម្ពុជាវិលត្រឡប់មកផ្ទះសម្បែង និងភូមិកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមខ្មែរក្រហម ដួលរលំនៅ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីជាង៧៥ឆ្នាំមុន លោក រ៉ាហ្វាអែល លេមឃីន បានបង្កើតពាក្យ“ប្រល័យពូជសាសន៍” ដើម្បីពិពណ៌នាអំពីការបំផ្លិចបំផ្លាញដ៏សាហាវឃោរឃៅ ធ្វើឡើងដោយចេតនាទៅលើមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងជាច្រើនលើកច្រើនសា នៅក្នុងជំពូកប្រវត្តិសាស្ត្រ។ ពាក្យ“ប្រល័យពូជសាសន៍” នេះគ្របនូវអត្ថន័យយ៉ាងសំខាន់ ដោយជំរុញឲ្យមានការចាប់បដិសន្ធិឡើងនៃ អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលសហគមន៍អន្តរជាតិតែងប្រារព្ធរំឭក មកទល់ពេលបច្ចុប្បន្ន។ និយមន័យផ្នែកច្បាប់របស់ពាក្យ“ប្រល័យពូជសាសន៍” បានឆ្លុះបញ្ចាំងអំពីកិច្ចព្រមព្រៀងរបស់សហគមន៍អន្តរជាតិ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការទទួលខុសត្រូវក្នុងការឆ្លើយតបរបស់មនុស្សជាតិ ទៅលើការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ទោះបីជា

យ៉ាងណាក្តី ឆ្លៀតក្នុងឱកាសខួបលើកទី៧៥ នៃការបង្កើតអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ យើងសង្កេតឃើញយ៉ាងជាក់លាក់ថា មកទល់សព្វថ្ងៃ កាតព្វកិច្ចជាច្រើនចែងដោយអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៅតែពុំអាចសម្រេចទៅបាន។ ជារួម ខ្លឹមសារចែងនៅក្នុងអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចរក្សានូវតម្លៃបានគឺអាស្រ័យទៅលើការអនុវត្តរបស់មនុស្ស ហើយសហគមន៍សកលលោកនៅមានចន្លោះខ្វះខាតជាច្រើន រវាងពាក្យពេជន៍ដែលចែងនៅក្នុងអនុសញ្ញា និងការអនុវត្តការប្តេជ្ញាជាក់ស្តែងអនុលោមតាមអនុសញ្ញានេះ។

នៅចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ ប្រទេសកម្ពុជា បានទទួលរងការបំផ្លិចបំផ្លាញយ៉ាងដំណំទៅលើអរិយធម៌របស់ខ្លួន។ របបខ្មែរក្រហម បានប៉ុនប៉ងអនុវត្តមនោគមវិជ្ជាកុម្មុយនីស្ត តាមលទ្ធិម៉ៅជ្រុលនិយម ដែលប្រព្រឹត្តទៅនៅក្នុងវិសាលគមនៃគោលនយោបាយ និងសកម្មភាពឃោរឃៅ ផុសឡើងចេញពីការស្រមើស្រមៃ។ ប្រជាជនកម្ពុជាត្រូវបានឃុំឃាំង, ទទួលរងទារុណកម្ម និងត្រូវបានសម្លាប់។ សហគមន៍ជាតិពន្ធុ និងសាសនា ត្រូវបានដាក់គោលដៅទៅលើ ហើយប្រជាជនកម្ពុជាទាំងអស់ ត្រូវទទួលរងភាពភិតភ័យ បង្កឡើងដោយអំពើអមនុស្សធម៌ ដ៏ព្រៃផ្សៃបំផុត។ មានការសន្និដ្ឋានថាប្រជាជនកម្ពុជាប្រមាណជាង២លាននាក់ ក្នុងចំណោមប្រជាជនសរុបចំនួន៧លាននាក់នាពេលនោះ បានបាត់បង់ជីវិតនៅក្នុងអំឡុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩)។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ដែលជាតុលាការបង្កើតឡើងរួមគ្នាដោយ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា) បានសម្រេចផ្តន្ទាទោសលើមេដឹកជាន់ខ្ពស់បំផុតនៃរបបខ្មែរក្រហម ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បន្ថែមពីលើបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងជនជាតិចាម។ ទោះបីជារបបប្រល័យពូជសាសន៍ប៉ុល ពត បានដួលរលំទៅ អស់រយៈកាលជាង៤០ឆ្នាំកន្លងមកហើយក្តី យើងនៅតែអាចមើលឃើញនូវផលប៉ះពាល់ធ្ងន់ធ្ងរបង្កឡើងក្នុងអំឡុងរបបនេះ មកលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងបង្កជាវិបត្តិផ្លូវចិត្ត និងពិការភាពផ្លូវកាយ លើប្រជាជនកម្ពុជាដែលបានរស់រានមានជីវិត ពីការបំផ្លិចបំផ្លាញធ្វើឡើងទៅលើស្ថាប័នរដ្ឋាភិបាល, ស្ថាប័នសង្គមស៊ីវិល និងស្ថាប័នវប្បធម៌ ដោយបន្សល់មកទល់សព្វថ្ងៃ ហើយមិនទាន់សះស្បើយទាំងស្រុងនៅឡើយ។

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នរក្សាទុកឯកសារ និងវត្ថុតាងប្រវត្តិសាស្ត្រដ៏កម្រស្តីពីរបបខ្មែរក្រហម ដែលធំជាងគេលើពិភពលោក ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា និងការគាំទ្រយ៉ាងវិសេសវិសាលពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងបន្តអនុវត្តគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍របស់ខ្លួន (ដែលត្រូវបានស្គាល់ថាជាការអប់រំអំពីឧក្រិដ្ឋកម្មឃោរឃៅ) នៅទូទាំងប្រទេសកម្ពុជា អស់រយៈកាលជាង២០ឆ្នាំកន្លងមកក្នុងគោលបំណងគាំពារដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានចំនួនប្រមាណជាង៥លាននាក់, មនុស្សជំនាន់ក្រោយ ក៏ដូចជាប្រទេសជាតិមួយដែលតស៊ូប្រឈមមុខនឹងអតីតកាលដ៏ជូរចត់របស់ខ្លួន។ តាមរយៈការងាររបស់ខ្លួនដែលប្រព្រឹត្តទៅនៅកម្រិតមូលដ្ឋានផ្ទាល់ជាមួយនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជា បានយល់ច្បាស់ចំពោះគោលគំនិតនៃអត្ថន័យរបស់ អនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

ប្រជាជនកម្ពុជាជាច្រើន នៅតែបន្តចោទជាសំណួរថា ហេតុអ្វីបានជាខ្មែរសម្លាប់ខ្មែរ? នៅស្ទើរតែគ្រប់វេទិកាសាធារណៈ, វគ្គបណ្តុះបណ្តាល ឬព្រឹត្តិការណ៍ប្រមូលផ្តុំនានា សំណួរខាងលើនៅតែលេចឡើង ដោយមិនត្រឹមតែចោទសួរដោយយុវជនដែលចាប់កំណើតក្រោយពីរបបប្រល័យពូជសាសន៍ប៉ុល ពត ដួលរលំទៅអស់ជាច្រើនទសវត្សរ៍ទៅ

ហើយតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងត្រូវបានលើកឡើងដោយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថែមទៀតផង។ នេះគឺជាសំណួរសមហេតុសមផលមួយ ដែលពុំមានចម្លើយពេញលេញសមស្របណាមួយទេ ពីព្រោះថា ថ្វីត្បិតតែសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើន ត្រូវបានប្រមែប្រមូលចងក្រង, ការសិក្សាស្រាវជ្រាវនានាត្រូវបានធ្វើឡើង ឬបទវិភាគច្រើនបែបច្រើនសណ្ឋានបានប្រព្រឹត្តទៅយ៉ាងណាក្តី នៅតែពុំមានចម្លើយសមស្របណាមួយ ឆ្លើយតបឲ្យបានសមប្រកបចំពោះសំណួរខាងលើ ស្របតាមការវិភាគ ឬការសន្និដ្ឋានរបស់មនុស្សលើអតីតកាលនេះដដែលៗ ការចោទជាសំណួរទៅលើព្រឹត្តិការណ៍ពីអតីតកាល គឺពិតជាចាំបាច់។ ជាក់ស្តែង នេះគឺជាកាយវិការដ៏ប្រសើរមួយ។ ក៏ប៉ុន្តែ ការសិក្សាអំពីអតីតកាល ត្រូវតែជាផ្នែកមួយនៃការប្តេជ្ញាមោះមុតចំពោះបច្ចុប្បន្នកាល និងអនាគតកាល។

ការអប់រំអំពីឧក្រិដ្ឋកម្មឃោរឃៅក្នុងសណ្ឋានផ្សេងៗ រួមមាន កាតព្វកិច្ចអប់រំ និងការអប់រំសាធារណៈ គឺជាការបង្ការឧក្រិដ្ឋកម្មឃោរឃៅ។ ការអប់រំគឺជាមាគ៌ាដ៏មានប្រសិទ្ធភាព និងប្រសិទ្ធផលតែមួយគត់ ឈានទៅរារាំងស្ថានភាព និងកត្តាជំរុញដែលរុញច្រានឲ្យឧក្រិដ្ឋកម្មឃោរឃៅកកើតឡើងនាពេលអនាគត។ ការអប់រំដែលជោគជ័យ ទាមទារនូវកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្នះខ្នែង ពីសំណាក់រាជរដ្ឋាភិបាល និងស្ថាប័នសង្គមស៊ីវិល។ បន្ថែមលើសពីនេះទៅទៀត ការអប់រំ ទាមទារនូវធនធាន និងការប្តេជ្ញាយ៉ាងមធ្យ័ត លើសពីអ្វីដែលមនុស្សជាតិបានអនុវត្តនាពេលកន្លងមក ក្នុងការឆ្លើយតប, កាត់ទោស និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មដែលបានកើតមានឡើង។

ការអប់រំ ថែមទាំងទាមទារឲ្យមានជារំពឹងទុកជាមុន។ កម្មវិធីអប់រំ ដែលផ្តោតទៅលើការបង្ការឧក្រិដ្ឋកម្មឃោរឃៅ គួរតែរួមបញ្ចូល លំហាត់ដែលបណ្តុះជាការប្រមើមើលអនាគត ជំរុញឲ្យអ្នកសិក្សារៀនសូត្រ ត្រិះរិះពិចារណាថាតើ សង្គមជាតិមួយអាចមានសភាពខុសប្លែកយ៉ាងម្តេចខ្លះ ប្រសិនបើឧក្រិដ្ឋកម្មឃោរឃៅពុំបានកើតមានឡើងទេនោះ? តើសង្គមជាតិមួយ អាចទទួលរងផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ ប្រសិនបើឧក្រិដ្ឋកម្មឃោរឃៅក្នុងប្រវត្តិសាស្ត្រទាំងនោះ កើតមានឡើងនាពេលសព្វថ្ងៃ? និង តើការបង្ការអ្វីខ្លះគួរអនុវត្តឡើងនាពេលអនាគត ដើម្បីសម្រេចបាននូវពិភពលោកក្នុងការប្រមើមើល ដែលអាចស្របទៅនឹងការប្តេជ្ញា "សូមកុំឲ្យកើតមានម្តងទៀត"។

មជ្ឈមណ្ឌលឯកសារកម្ពុជា អំពាវនាវទៅកាន់ប្រជាជាតិទាំងអស់ សូមដាក់បញ្ចូលការអប់រំអំពីឧក្រិដ្ឋកម្មឃោរឃៅ ទៅក្នុងកម្មវិធីអប់រំផ្លូវការថ្នាក់ជាតិ នៅកម្រិតវិទ្យាល័យ។ ស្ថាប័នយោធាទាំងអស់ គួរតែតម្រូវឲ្យដាក់បញ្ចូលកម្មវិធីអប់រំអំពីឧក្រិដ្ឋកម្មឃោរឃៅ ជាសមាសធាតុស្នូលនៃការអប់រំមន្ត្រីយោធា និងថ្នាក់ដឹកនាំយោធាជាន់ខ្ពស់។ អ្វីដែលសំខាន់ជាងនេះទៅទៀតគឺ ការអប់រំអំពីឧក្រិដ្ឋកម្មឃោរឃៅ គួរតែចែងជាលាយលក្ខណ៍អក្សរនៅក្នុងគោលនយោបាយអភិវឌ្ឍន៍អន្តរជាតិទាំងអស់ ដោយតម្រូវឲ្យរាល់អ្នកទទួលជំនួយអភិវឌ្ឍន៍ស្ថានផ្លូវផ្ទាល់ និងគម្រោងផ្សេងៗ ត្រូវស្ថិតក្រោមលក្ខខណ្ឌក្នុងការអនុវត្តកម្មវិធីអប់រំដែលមានបទដ្ឋានច្បាស់លាស់ អំពីឧក្រិដ្ឋកម្មឃោរឃៅ។ កិច្ចសន្ទនាពីការអប់រំអំពីឧក្រិដ្ឋកម្មឃោរឃៅ មិនគួរតែធ្វើឡើងដោយផ្តោតតែទៅលើការអភិវឌ្ឍន៍ក្រោយជម្លោះនោះទេ ក៏ប៉ុន្តែគួរចាប់ផ្តើមចេញពីបញ្ហាទាំងអស់នេះ ពីព្រោះថាជំនួយអន្តរជាតិ គឺជាមធ្យោបាយចម្បងបំផុតក្នុងការកសាងនូវ សមាសធាតុ និងយន្តការរារាំងឧក្រិដ្ឋកម្មឃោរឃៅ ពីការកកើតឡើងវិញនាពេលអនាគត។ សេចក្តីចែងនៅក្នុងអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទាមទារឲ្យមានការដាក់ចេញជាសកម្មភាព ដែលមិនមែនត្រឹមតែផ្តល់ជាផលប្រយោជន៍ស្របតាមការកំណត់នៃច្បាប់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងធានាសម្រេចបាននូវការសន្យារបស់យើងសម្រាប់មនុស្សជំនាន់ក្រោយៗថែមទៀតផង។

# ភេ ឌី ត្រូវបានខ្មែរក្រហមចាប់ខ្លួនដោយសារសរសេរសំបុត្រក្លែងក្លាយឱ្យ នី ទៅរកបងប្អូននៅខេត្តព្រះវិហារ

*មីន សាណាស់*



ប្រជាជននៅក្នុងកងចល័តលើកប្រព័ន្ធធារាសាស្ត្រ សម្រាប់ស្តុកទឹកធ្វើស្រែនៅក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ភេ ឌី អាយុ៤០ឆ្នាំ (ក្នុងឆ្នាំ១៩៧៦) ជនជាតិខ្មែរ កើតនៅភូមិស្រះជីក សង្កាត់ស្រះជីក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង។ ខ្ញុំមានឪពុកឈ្មោះ ភេ ឡាក និង ម្តាយខ្ញុំឈ្មោះ កុយ ហ៊ាក់ មានមុខរបរធ្វើស្រែ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់មានឈ្មោះដូចតទៅ ១) ភេ ផុន ភេទប្រុស អាយុ៥០ឆ្នាំ មានប្រពន្ធឈ្មោះ សារ៉ុត ២) ភេ ធើ ភេទស្រី អាយុ៤៦ឆ្នាំ មានប្តីឈ្មោះ ផង់ ៣) ភេ ភាន់ ភេទប្រុស អាយុ៤៣ឆ្នាំ មានប្រពន្ធឈ្មោះ លីប ៤) ខ្ញុំផ្ទាល់ និង ៥) ភេ ដៃ ភេទប្រុស អាយុ៣៦ឆ្នាំ មានប្រពន្ធឈ្មោះ សារ៉ាយ។ ខ្ញុំមានប្រពន្ធចំនួន៣នាក់ គឺ ប្រពន្ធទី១) ឈ្មោះ សែម សន រស់នៅភូមិតាប៉ោង សង្កាត់កំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ, ប្រពន្ធទី២) ឈ្មោះ សយ សារឿង រស់នៅភូមិអូរាំងឪ ខេត្តកំពង់ចាម និងប្រពន្ធទី៣) ឈ្មោះ ស៊ិន សាយ រស់នៅភូមិទួលស្វាយព្រៃ សង្កាត់លេខ៤ ក្រុងភ្នំពេញ។ ខ្ញុំមានកូនស្រីចំនួនបី

នាក់ជាមួយប្រពន្ធទីមួយ គឺ ១) ឈ្មោះ ភេ សុចាន់ អាយុ៨ឆ្នាំ ២) ឈ្មោះ ភេ សុចា អាយុ៦ឆ្នាំ និង ៣) ឈ្មោះ ភេ សុចារី អាយុ៤ឆ្នាំ។

កាលអាយុ១០ឆ្នាំ ខ្ញុំចូលរៀននៅសាលាវត្តជ័យឧត្តម ក្នុងស្រុកកំណើតនៅភូមិស្រះជីក សង្កាត់ស្រះជីក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង។ ខ្ញុំបានស្នាក់នៅរៀនសូត្រក្នុងវត្តជ័យឧត្តមរយៈពេល៣ឆ្នាំ។ ក្នុងឆ្នាំ១៩៥២ ទើបឪពុកម្ដាយខ្ញុំបញ្ជូនខ្ញុំឲ្យទៅរៀននៅសាលាបឋមសិក្សាបំពេញវិជ្ជាព្រះនេត្រព្រះ សង្កាត់ព្រះនេត្រព្រះ ស្រុកទឹកជោ ខេត្តបាត់ដំបង។ ខ្ញុំរៀនបន្តរយៈពេល៦ឆ្នាំ ទើបប្រឡងជាប់សញ្ញាប័ត្របឋមសិក្សាជាន់ដំបូង។ ក្រោយពីប្រឡងជាប់ ក្នុងឆ្នាំ១៩៥៧ ខ្ញុំត្រូវបន្តការសិក្សាក្នុងវិទ្យាល័យមុនីវង្ស ស្ថិតនៅទីរួមខេត្តបាត់ដំបង។ ខ្ញុំរៀននៅវិទ្យាល័យមុនីវង្សរយៈពេល៤ឆ្នាំ ទើបប្រឡងឌីប្លូម ប៉ុន្តែខ្ញុំប្រឡងធ្លាក់ឌីប្លូមចំនួន៣ដង។

ដោយសារតែជីវភាពក្រីក្រពេក ខ្ញុំសម្រេចចិត្តធ្វើដំណើរទៅភ្នំពេញហើយចូលរៀនផ្នែក គិលានសង្គ្រោះ ផ្នែកចាក់ថ្នាំ និងលក់ថ្នាំពេទ្យអស់រយៈពេល៦ខែទើបចប់។ បន្ទាប់ពីរៀនចប់ខ្ញុំបានចូលធ្វើការនៅឱសថស្ថាន«ជី ឡាប៉ុស្ដិ៍» ផ្នែកឯកជនមានប្រាក់ខែ ៩០០រៀល ហើយខ្ញុំក៏ឆ្លៀតឱកាសខំរៀនវាយអង្គុលីលេខខ្មែរ-បារាំងយ៉ាងស្ទាត់ជំនាញ។ ខ្ញុំថែមទាំងទៅរៀនផ្នែកជួលជុលម៉ាស៊ីនអង្គុលីលេខ និងរៀនភាសាអង់គ្លេស និងបារាំងបន្ថែមទៀត។ នៅឆ្នាំ១៩៦៤ ខ្ញុំបានប្រឡងជាប់ឌីប្លូម។ ក្រោយពីប្រឡងជាប់ ខ្ញុំក៏ទៅធ្វើជាគ្រូបង្រៀនភាសាអង់គ្លេសនៅអនុវិទ្យាល័យឯកជនឈ្មោះ រស្មីវិជ្ជា ដែលមានទីតាំងនៅក្នុងទីរួមខេត្តស្វាយរៀងរយៈពេល២ឆ្នាំ។ ពេលឈប់ពីគ្រូបង្រៀនខ្ញុំបានទៅធ្វើការនៅចម្ការកៅស៊ូ ចម្ការអណ្ដូង ខេត្តកំពង់ចាម។ ពេលធ្វើការក្នុងចម្ការកៅស៊ូ ខ្ញុំខស្បាហ៍ឈឺពេកក៏ឈប់ រួចត្រឡប់មកទីក្រុងភ្នំពេញវិញ។

ពេលមកដល់ទីក្រុងភ្នំពេញ ខ្ញុំក៏ដាក់ពាក្យប្រឡងចូលធ្វើជាកងរាជអាវុធហត្ថ«ប៉ូលីស» ជាប់។ ខ្ញុំជាប់ធ្វើការជាប៉ូលីស ស្ថិតនៅក្រោមមេបញ្ជាការវរសេនីត្រីយ៍ អ៊ុំ ម៉ាណូរិន។ ដោយសារការខ្វះខាតបុគ្គលិកប៉ូលីសនៅទីរួមខេត្តបាត់ដំបង ក្រសួងក៏ផ្លាស់ខ្ញុំពីភ្នំពេញទៅធ្វើការនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបាត់ដំបង ដែលមានអនុសេនីយ៍ឯក ជា ហេងគ្រី គឺជាមេបញ្ជាការ។ មេបញ្ជាការរបស់ខ្ញុំបានចាត់តាំងខ្ញុំជាលេខាធិការវាយអង្គុលីលេខខ្មែរ បារាំង និងជាអ្នកជួលជុលម៉ាស៊ីនអង្គុលីលេខ។ ខ្ញុំធ្វើការនៅទីរួមខេត្តបាត់ដំបងតាំងពីឆ្នាំ១៩៦៧ រហូតដល់ថ្ងៃធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៦៨ ខ្ញុំបានរៀបការជាមួយនារីឈ្មោះ សែម សន អាយុ១៨ឆ្នាំ ជាតិខ្មែរ នៅភូមិអន្លង់ស្វាយ សង្កាត់វត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង ដែលមានមុខរបររកស៊ីខាងចម្ការក្រូច។ ប្រពន្ធខ្ញុំមានឪពុកឈ្មោះ សែម និងម្ដាយឈ្មោះ នាង ងិន។

## អំពីសកម្មភាពក្នុងសង្គ្រាម និងក្រោយរដ្ឋប្រហារ

ក្រោយរដ្ឋប្រហារភ្លាមៗខ្ញុំធ្វើជាប៉ូលិសប្រចាំនៅខេត្តបាត់ដំបង ប៉ុន្តែត្រូវបានទាហានរបស់ លន់ នល់ចាប់ដកអាវុធក្នុងថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧០ រួចទាហាន លន់ នល់ បញ្ជាឲ្យប៉ូលីសទាំងអស់ជិះរថភ្លើងឡើងមកភ្នំពេញ។ ពេលមកដល់ភ្នំពេញ ទាហាន លន់ នល់ បញ្ជាឲ្យប៉ូលីសទាំងអស់ដោះឯកសណ្ឋានចេញរួចស្លៀកឈុតទាហានព្រមទាំងបង្ខំឲ្យធ្វើជាទាហានទាំងអស់គ្នាវិញ។ ក្នុងករណីប៉ូលីសមិនព្រមគឺត្រូវក្រុមទាហានសម្លាប់ចោល។

ចាប់ពីថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំត្រូវតែងតាំងជាទាហានយ៉ាងបង្ខំ ដែលមានឋានន្តរស័ក្តិជាពលទោ ដែលមានប្រាក់ខែចំនួន១៧៤០រៀល ជាទាហានក្នុងផ្នែកសឹករងភ្នំពេញ ដែលមានឧត្តមសេនីយ៍ត្រី ឈឹម ឈួន គឺជាមេបញ្ជាការ។

បន្ទាប់មកទៀត ថ្នាក់លើបានបញ្ជូនខ្ញុំឲ្យទៅរៀនវិជ្ជាពេទ្យ ដោយសំអាងថាខ្ញុំចេះវិជ្ជាពេទ្យម្ដងរួចមកហើយ។ ខ្ញុំរៀនពេទ្យរយៈពេល៣ខែចប់ ក្រសួងទាហានបានឲ្យខ្ញុំទៅធ្វើការ ជំនួសបុគ្គលិកពេទ្យព្រះមុនីវង្សភ្នំពេញចំនួនមួយឆ្នាំជាង។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧១ ខ្ញុំឈប់ធ្វើការនៅក្នុងពេទ្យព្រះមុនីវង្ស ហើយមកធ្វើការក្នុងក្រសួងទាហានវិញ។ ក្រោយមកបញ្ជាការទាហានផ្នែកសឹងរងភ្នំពេញ បានជ្រើសរើសខ្ញុំឲ្យទៅបន្តវិជ្ជាផ្នែកយុទ្ធសាស្ត្រ នៅប្រទេសវៀតណាមខាងត្បូង ក្នុងតំបន់ដុងបាធិន។ កាលនោះមានគ្នាចំនួន១៨០នាក់ បានទៅរៀនពីយុទ្ធសាស្ត្រ ដែលមានគ្រូបង្ហាត់បង្រៀនសុទ្ធតែអាមេរិកាំងទាំងអស់។ នៅក្នុងពេលរៀន ដោយសារខ្ញុំចេះភាសាអង់គ្លេសតិចតួច គ្រូក៏ចាត់តាំងឲ្យខ្ញុំធ្វើជាអ្នកបកប្រែភាសាអង់គ្លេសមកខ្មែរ។ ក្នុងចំណោមគ្រូទាំងអស់គឺមានគ្រូម្នាក់ឈ្មោះ ដកធើ្យ មានតួនាទីជាស័ក្តិ៥ និងជាចាងហ្វាងសាលាបានស្រឡាញ់រាប់អានខ្ញុំណាស់។ រាល់ថ្ងៃអាទិត្យ ដកធើ្យ តែងតែមកនាំខ្ញុំដើរលេងតាមតំបន់នានាក្នុងប្រទេសវៀតណាម ដូចជា ៖ ព្រៃនគរ ដាណាង ក្រុងវៃ ភូមិមីយសាវ ឌុកមី និនរ៉ា និង ក្រុងញ៉ាត្រាងជាដើម។ ខ្ញុំបានរៀននិងរស់នៅក្នុងប្រទេសវៀតណាមរយៈពេល៧ខែ ទើបខ្ញុំត្រឡប់មកកាន់ស្រុកខ្មែរវិញ។

មកដល់ស្រុកខ្មែរវិញ មេបញ្ជាការផ្នែកសឹករងភ្នំពេញបានឲ្យខ្ញុំកាន់ការនៅក្នុងការិយាល័យលេខាធិការវាយអង្គុលីលេខខ្មែរ បារាំង ធ្វើជាអ្នកជួលជុលម៉ាស៊ីនអង្គុលីលេខ និងឲ្យបង្ហាត់វិជ្ជាយុទ្ធសាស្ត្រដល់កងស្វ័យត្រាណរាល់ល្ងាច។ ទីតាំងដែលខ្ញុំធ្វើការគឺនៅក្នុងតំបន់ការពារពលរដ្ឋលេខ១ មានទីស្នាក់ការនៅខាងជើងផ្សារថ្មី ខាងមុខក្រសួងឃោសនាការ ដែលមានលោកវរសេនីយ៍ទោ សរ សារុន គឺជាមេបញ្ជាការ។

## សារភាពកំហុសរបស់ខ្ញុំ ក្រោយចប់សង្គ្រាម

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃបញ្ចប់សង្គ្រាមរវាងទាហាន លន់ នល់ និងកងកម្លាំងរំដោះខ្មែរក្រហម។ អង្គការចាប់ជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ។ ចំណែកខ្ញុំ អង្គការបានដាក់ទិសដៅឲ្យមកនៅភូមិតាប៉ោង សង្កាត់កំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៦ អង្គការបានបើកការដ្ឋានមួយយ៉ាងធំស្ថិតក្នុងភូមិរលួស ខាងត្បូងខេត្តកំពង់ធំ ប្រហែល៥គីឡូម៉ែត្រ ដើម្បីលើកប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយ ដែលមានប្រជាជនរាប់ម៉ឺននាក់មកពីគ្រប់ទិសដៅ។ ពេលខ្ញុំជីកប្រឡាយក៏បានស្គាល់ឈ្មោះ នី អាយុ២០ឆ្នាំ ធ្វើការជាមួយគ្នា។ ក្នុងម៉ោងសម្រាក នី បានមកក្បែរខ្ញុំ ហើយក៏ប្រាប់ខ្ញុំថា គាត់មានបងប្រុសម្នាក់រស់នៅស្រុកសៀម។ ហេតុនេះ នីបានបបួលខ្ញុំទៅស្រុកសៀម។ ខ្ញុំឆ្លើយតបដាច់ខាតគឺមិនទៅរស់នៅស្រុកសៀមទេ។

ក្រោយមក នី ក៏បានពឹងខ្ញុំឲ្យសរសេរសំបុត្រក្លែងក្លាយឲ្យដើម្បីធ្វើដំណើរទៅរកឪពុកម្ដាយនៅខេត្តព្រះវិហារ។ ខ្ញុំក៏សរសេរសំបុត្រឲ្យ។ នីបានសំបុត្រភ្លាម ក៏លួចរត់ទៅបាត់ ក្នុងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៧៦ ថែមទាំងលួចយកនាឡិកាម៉ាក់ស៊ីទីហ្សែនខ្ញុំទៅជាមួយផង។ ចុងក្រោយនៅយប់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៦ អង្គការបានចុះមកស្នើនាំខ្លួនខ្ញុំនៅម៉ោង២១យប់ មកកាន់មន្ទីរសន្តិសុខសង្កាត់កំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ រួចបញ្ជូនមកមន្ទីរសន្តិសុខខេត្តកំពង់ធំរហូតមកដល់សព្វថ្ងៃនេះ។

***កំណត់ចំណាំ ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពJ០០០៧០។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខខ្មែរក្រហម សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ភេ ឌី ពិតបុយ៉ាងណានោះទេ។***

# «ព្រះរាជបណ្ណាល័យហ្លួងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រក្នុងព្រះរាជដំណើរទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជាឆ្នាំ១៩៧៣» ជូនសាធារណជន បានចំនួន៨០២៩០ក្បាល គិតត្រឹមដើមខែធ្នូ ឆ្នាំ២០២៣

*សោម ប៊ុនថន*



សម្តេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ និងសម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។
(ជេ គូសម៉ាន់/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងខួប៥០ឆ្នាំ នៃការកត់ត្រាព្រះរាជដំណើរទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជានៅឆ្នាំ១៩៧៣ របស់សម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នៅក្នុងឆ្នាំ២០២៣នេះ «ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការបកប្រែកំណត់ត្រារបស់ទ្រង់នៅក្នុងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ក្នុងព្រះរាជដំណើរទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣» ដោយលោកឆាំង យុ និងអ្នកស្រី សុភ័ក្រ្ត ភាណា ពីភាសាអង់គ្លេសមកជាភាសាខ្មែរដើម្បីបោះពុម្ព និងផ្សព្វផ្សាយ។

គិតត្រឹមដើមខែធ្នូ ឆ្នាំ២០២៣ «ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ»បានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រក្នុងព្រះរាជដំណើរទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣» ជូនសាធារណជន




ក្របសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ក្នុងព្រះរាជដំណើរ សម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣» ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ព្រះរាជលិខិតរបស់សម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បានចំនួន ៨០២៨០ ក្បាល រួចមកហើយ។ នៅដើមឆ្នាំ២០២៤ ខាងមុខ «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» នឹងបន្តចែកសៀវភៅនេះ ទៅតាមការស្នើសុំនានាពីសាធារណជន ជាពិសេសប្រជាជនកម្ពុជាដែលរស់នៅតាមទីជនបទដាច់ស្រយាល។

សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ក្នុងព្រះរាជដំណើរទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣» គឺជាព្រះរាជសំណេរដើមរបស់ព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាភាសាបារាំង ហើយបានបកប្រែមកជាភាសាអង់គ្លេស ដោយមិនមានការកែសម្រួល ហើយបានឆ្លុះបញ្ចាំងអំពីព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនៈរបស់ហ្វូងម៉ែផ្ទាល់។

សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ក្នុងព្រះរាជដំណើរទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣» រៀបរាប់អំពីព្រះរាជដំណើរសម្តេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ យាង



ជនជាតិភាគតិចចាមរស់នៅតាមសហគមន៍ជនបទដាច់ស្រយាលទទួលសៀវ «សាក្សីប្រវត្តិសាស្ត្រ ក្នុងព្រះរាជដំណើរ សម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប្រជាជននៅតាមជនបទដាច់ស្រយាល ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ក្នុងព្រះរាជដំណើរ សម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សមកពីសាលាអង្គការតារាម៉ាណាដែលមានជីវភាពខ្វះខាត ទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្វូងម៉ែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



មកកាន់តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា ក្នុងឆ្នាំ១៩៧៣ ដោយចេញព្រះរាជដំណើរពីទីក្រុងប៉េកាំង មកទីក្រុងហាណូយ ហើយបន្តតាមផ្លូវលំហូជីមិញ និងផ្នែកខ្លះនៃប្រទេសឡាវ មកកាន់ប្រទេសកម្ពុជា។ ក្នុងរយៈពេល៣៩ថ្ងៃនៃព្រះរាជដំណើរ ហ្វូងម៉ែ បានសរសេរកំណត់ហេតុជារៀងរាល់ថ្ងៃ ព្រមទាំងបង្ហាញឲ្យឃើញពីភាពទន់ភ្លន់ និងសេចក្តីថ្លៃថ្នូររបស់ព្រះអង្គ ទោះបីស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងចលាចលយ៉ាងណាក៏ដោយ។

«ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» ទទួលស្វាគមន៍ភ្ញៀវជាតិ និងអន្តរជាតិ អង្គទូត អគ្គរដ្ឋទូត និងរាជទូតមកពីបណ្តាប្រទេសនានា មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល សិស្ស និស្សិត និងប្រជាពលរដ្ឋដែលរស់នៅតាមបណ្តាខេត្តនានាមកទស្សនកិច្ច សិក្សាស្រាវជ្រាវ និងទស្សនាពិព័រណ៍រូបថតប្រវត្តិសាស្ត្រនៃព្រះរាជសកម្មភាព និងរាជកិច្ចរបស់ព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ និង ព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។



សិស្សវិទ្យាល័យទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ក្នុងព្រះរាជដំណើរ សម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហោរអដ្ឋិធាតុ

ឆាំង យុ



*ហោរអដ្ឋិធាតុ ឬបណ្ណាល័យអដ្ឋិធាតុ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ប្រវត្តិសាវតារនៃហោរអដ្ឋិធាតុ ឬបណ្ណាល័យអដ្ឋិធាតុ ផ្សារភ្ជាប់ទំនាក់ទំនងស៊ីជម្រៅជាមួយនឹងប្រវត្តិសាស្ត្រទំនើបរបស់ប្រទេសកម្ពុជា ក៏ដូចជា ការតស៊ូរបស់ប្រជាជនកម្ពុជា ក្នុងការជាសះស្បើយពីអតីតកាលរបស់ខ្លួន។

នៅក្នុងឆ្នាំ២០១៥ បងស្រីរបស់ខ្ញុំ ឈ្មោះ កែវ កុលធីតា ឯកស័ក បានទទួលមរណភាពក្រោយពីបានព្យាយាមជម្នះនឹងជំងឺមហារីកអស់រយៈពេលជាច្រើនឆ្នាំ។ បងស្រីរបស់ខ្ញុំ គឺជាមនុស្សគួរជាទីស្រឡាញ់ពីកំណើត។ គាត់ជាកូនស្រីពៅគេបង្អស់ក្នុងចំណោមបងស្រីប្រាំនាក់របស់ខ្ញុំ។ គាត់មានអាយុខុសគ្នាជាមួយខ្ញុំត្រឹមតែពីរឆ្នាំប៉ុណ្ណោះ ហេតុដូច្នេះ គាត់និងខ្ញុំហាក់បីដូចជាមិត្តជិតស្និទ្ធនឹងគ្នា។ មរណភាពរបស់គាត់ គឺជាពេលវេលាដ៏លំបាកលំបិនមួយសម្រាប់ខ្ញុំ ហើយខ្ញុំបានបួសជាសង្ឃនៅវត្តលង្កា ក្រោយការលាចាកលោកទៅរបស់គាត់។ ក្រោយពីមរណភាពរបស់គាត់ ព្រះសង្ឃបានលើកទឹកចិត្តឲ្យខ្ញុំតាំងសម្មាធិ ហើយខ្ញុំក៏បានដើរជុំវិញបរិវេណព្រះវិហារ។ នៅពេលដែលខ្ញុំដើរជុំវិញបរិវេណព្រះវិហារ ដោយចៃដន្យ ខ្ញុំបានសង្កេតឃើញពន្លឺលេចចេញពីប្រឡោះតូចមួយនៅក្បែរឆព្វណ្ណរង្សីនៃព្រះពុទ្ធប្បដិមា។ ខ្ញុំបានស្នើសុំព្រះសង្ឃនៅក្នុងវត្តឲ្យជួយរំកិលព្រះពុទ្ធប្បដិមា ដើម្បី

ដឹងថាតើពន្លឺលេចឡើងនោះ មានប្រភពមកពីណា។ ព្រះសង្ឃប្រមាណជាង១៥អង្គរួមគ្នា ទើបអាចរំកិលព្រះពុទ្ធប្បដិមាធ្វើឡើងពីស៊ីម៉ង់ត៍មួយអង្គនេះរួច។ ក្រោយពីរំកិលពុទ្ធប្បដិមា យើងបានប្រទះឃើញរូងបន្ទប់មួយនៅពីក្រោយ ទ្វារមួយផ្ទាំងដែលជាប់សោរ និងប្រវ៉ាក់។ រូងនៅពីក្រោយ ទ្វារនេះជាប់សោរ និងប្រវ៉ាក់នោះមានសណ្ឋានងងឹត និងគួរឲ្យព្រឺក្បាល។ ទោះបីជាយ៉ាងនេះក្តី យើងបានសម្រេចចិត្តបើកទ្វារនោះ ដើម្បីពិនិត្យថាតើមានអ្វីនៅពីក្រោយ។ នៅពេលដែលយើងបើកទ្វារ ហើយប្រើពិលដើម្បីឆ្លុះមើល យើងបានឃើញកោដ្ឋ ដែលត្រូវបានគរជាគំនរៗ រុំព័ទ្ធជុំជិតទៅដោយសម្បុកពីងពាង, ធូលី និងពីងពាងជាច្រើន។

គណៈកម្មាធិការវត្តលង្កា បានអនុញ្ញាតឲ្យខ្ញុំរើយកកោដ្ឋទាំងអស់ចេញពីក្នុងរូងនោះ រួចចាត់ថ្នាក់និងថតរូប ទុកជាឯកសារ។ យើងកំណត់បានថាមានកោដ្ឋសរុបចំនួន ៨៦៨។ កោដ្ឋភាគច្រើន មានសភាពបាក់បែក ធ្វើឲ្យយើងមិនអាចកំណត់អំពីព័ត៌មានដែលសរសេរបិទភ្ជាប់ទៅនឹងកោដ្ឋទាំងនោះបាន កុំថាឡើយកំណត់ពីអាយុនៃកោដ្ឋទាំងនោះ។ កោដ្ឋខ្លះមានកាលបរិច្ឆេទបិទភ្ជាប់ ដែលយើងអាចសន្និដ្ឋានថា កោដ្ឋទាំងនេះត្រូវបានបន្សល់ពីជំនាន់សង្គ្រាមស៊ីវិល ដែលកើតមានឡើងក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ចំណែកឯកោដ្ឋខ្លះត្រូវបានបន្សល់ទុកពីដើមទសវត្សរ៍ឆ្នាំ១៩៩០។ ទោះបីជាយ៉ាងណាក្តី ឆ្លងកាត់ការសិក្សាស្រាវជ្រាវរបស់យើង យើងជឿជាក់ថា ភាគច្រើននៃកោដ្ឋទាំង នេះ ត្រូវបានបោះបង់ចោលនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៥។

ភ្លាមៗបន្ទាប់ពីខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខិតបង្ខំប្រជាជនក្នុងទីក្រុងភ្នំពេញទាំងអស់ឲ្យចាកចេញ និងធ្វើការនៅក្នុងសហករណ៍ដែលខ្មែរក្រហមបានបង្កើតឡើង។ ប្រជាជន ត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង ដោយនាំយកទៅជាមួយនូវរបស់របរបន្តិចបន្តួច ដែលខ្លួនអាចកាន់យកទៅជាមួយបាន។ ប្រជាជនខ្លះ បាននាំយកអដ្ឋិធាតុសាច់សារលោហិតរបស់ខ្លួន ទៅប្រគេនរក្សាទុកនៅឯវត្តលង្កា ដោយប្រហែលជារំពឹងថា ខ្លួនអាចសុំយកអដ្ឋិធាតុទាំងនោះត្រឡប់មកវិញ នៅពេលដែលខ្លួនវិលមកកាន់ទីក្រុងភ្នំពេញ។

ព្រះសង្ឃ ដែលទទួលរក្សាទុកកោដ្ឋទាំងនេះកាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ បានទទួលអនិច្ចធម្ម។ ក្រោយពីព្រះតេជគុណអង្គនោះ ទទួលអនិច្ចធម្មទៅ ព័ត៌មានស្តីអំពីរូងតម្កល់កោដ្ឋនេះក៏បានសាបសូន្យទៅតាមព្រះអង្គ ពីព្រោះថា ពុំមានព្រះសង្ឃមួយអង្គណា នៅក្នុងវត្តលង្កា បានជ្រាបអំពីរូងសម្ងាត់នេះឡើយ នៅមុនពេលត្រូវបានពើបប្រទះឃើញសាជាថ្មី នៅក្នុងឆ្នាំ២០១៥។

ដោយមានការគាំទ្រយ៉ាងសប្បុរសពីសំណាក់ស្ថានទូតអាមេរិក, ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងទាហានជើងទឹកសហរដ្ឋអាមេរិក ប្រចាំនៅប្រទេសជប៉ុន យើងបានសាងសង់ទូឈើ សម្រាប់ដាក់តម្កល់កោដ្ឋទាំងអស់នេះ។ បច្ចុប្បន្ន កោដ្ឋទាំងនេះ ត្រូវបានតម្កល់រក្សាទុកនៅក្នុងទូ ចំនួន១០ នៅវត្តលង្កា។ ចាប់តាំងពីពេលដែលយើងបានស្រាវជ្រាវរកឃើញកោដ្ឋទាំងនេះ និងបានតម្កល់ទុកនៅ ទីតាំងសមរម្យជាងមុន នៅវត្តលង្កា យើងបានធ្វើសេចក្តីប្រកាសអំពីវត្តមាននៃកោដ្ឋទាំងនេះ ដោយសង្ឃឹមថា ក្រុមគ្រួសារនៃកោដ្ឋអាចមកទទួលយកត្រឡប់ទៅវិញ។ តាមលំអាននៃទំនៀមទម្លាប់ក្នុងព្រះពុទ្ធសាសនា កោដ្ឋទាំងអស់នេះពុំអាចត្រូវបោះបង់ចោលទេ។ កោដ្ឋទាំងនេះ ត្រូវទទួលបានសេចក្តីគោរពឲ្យបានសមស្របតាមប្រពៃណី។ ទោះបីជាយ៉ាងណាក្តី អស់រយៈពេលជាង ៨ ឆ្នាំបន្ទាប់ពីការរកឃើញកោដ្ឋទាំងនេះ មានតែក្រុមគ្រួសារចំនួន៩ តែប៉ុណ្ណោះ ដែលបានមកទទួលយកអដ្ឋិធាតុនៃសាច់សារលោហិតរបស់


ហោអដ្ឋិធាតុ

មជ្ឈមណ្ឌលឯកសារកម្ពុជា

THE URN LIBRARY

DOCUMENTATION CENTER OF CAMBODIA

Story –
As a deaf person, no one bothered to ask my sister about her experience during the Khmer Rouge period. At that time, my sister was undergoing treatment for cancer, and also I re-connected with her about topics and experiences that we had never discussed before.

She told me about her experience as a deaf person during the Khmer Rouge regime, and her stories made me embarrassed by how little I knew about her suffering.

Her stories also made me realize how many other people with mental or physical disabilities have had to suffer alone. How many other life stories are forgotten, overlooked, or are simply never told?

"This project is made possible by the support of the American People through the Embassy of the United States of America in Phnom Penh, U.S. Agency for International Development (USAID), and the Seabees of NMCB FIVE."

23 December 2023

ខ្លួនត្រលប់ទៅវិញ។ យើងជឿជាក់ថា ចំពោះកោដ្ឋដែលបានរក្សាទុកនៅក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ ក្រុមគ្រួសារនៃអដ្ឋិធាតុ ដែលបានយកកោដ្ឋមកតម្កល់ទុកនៅក្នុងអំឡុងពេលនៃការជម្លៀសកាលពីឆ្នាំ១៩៧៥នោះ អាចបាត់បង់ជីវិតទៅអស់ហើយ ទើបពុំអាចមកទទួលយកកោដ្ឋទាំងនេះត្រឡប់ទៅវិញ។

ឆ្លងកាត់ការពិភាក្សារវាងព្រះចៅអធិការវត្តលង្កា សម្តេចព្រះធម្មលិខិត បណ្ឌិត សៅរ៍ ចាន់ថុល្ល និងគណៈកម្មាធិការសង្ឃគ្រប់គ្រងវត្តលង្កា ព្រះតេជគុណ បានសម្រេចប្រទានបន្ទប់មួយចំនួននៅអគារកំពុងសាងសង់ថ្មី ក្នុងបរិវេណវត្តលង្កា ដើម្បីតម្កល់កោដ្ឋទាំងនេះ ព្រមទាំងធ្វើជាបណ្ណាល័យ និងទីតាំងសម្រាប់ភ្ញៀវក្នុងការសិក្សារៀនសូត្រ, សមាធិ និងឈ្វេងយល់អំពីប្រវត្តិសាស្ត្រ, វប្បធម៌ និងអត្តន័យផ្នែកសាសនា របស់កោដ្ឋទាំងនេះ នៅក្នុងបរិបទនៃអត្តសញ្ញាណរបស់កម្ពុជា, ទំនៀមទម្លាប់ក្នុងព្រះពុទ្ធសាសនា និងមនុស្សជាតិ។ គណៈកម្មាធិការសង្ឃ ក៏បានប្រទាននូវបន្ទប់តូចចំនួន២ ទុកសម្រាប់ភ្ញៀវស្នាក់នៅ ព្រមទាំងបន្ទប់មួយទៀតសម្រាប់ថ្វាយបង្គំព្រះពុទ្ធជាម្ចាស់។ បន្ទប់ទាំងនេះ រួមគ្នាបង្កើតបានជាហោអដ្ឋិធាតុ ឬ បណ្ណាល័យអដ្ឋិធាតុ នៅក្នុងវត្តលង្កា



ហោអដ្ឋិធាតុ ឬបណ្ណាល័យអដ្ឋិធាតុ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដែលជាទីតម្កល់កោដ្ឋ និងជាបណ្ណាល័យតម្កល់សៀវភៅ អមជាមួយនឹងឯកសារប្រវត្តិសាស្ត្រ និងសាសនា។

ជាក់ស្តែង ការអភិរក្ស និងការការពារកោដ្ឋទាំងអស់នេះ គឺស្របទៅតាមចក្ខុវិស័យរបស់លោក រ៉ាហ្វាអ៊ែល លេមឃីន តាំងពីឆ្នាំ១៩៤៨មកម្ល៉េះ ក្នុងការរារាំងទប់ស្កាត់ និងផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ នៅមុនពេលដែលយើងសម្រេចកំណត់បាននូវនិយមន័យផ្លូវច្បាប់នៃឧក្រិដ្ឋប្រល័យពូជសាសន៍ដូចសព្វថ្ងៃ លោកលេមឃីន បានកំណត់ថា ការបំផ្លិចបំផ្លាញលើវត្ថុនិងបេតិកភណ្ឌវប្បធម៌ គឺជាទង្វើមួយដែលចាត់ចូលជាអំពើប្រល័យពូជសាសន៍លើវប្បធម៌។ កិច្ចការដែលបម្រើដល់ការកំណត់អត្តសញ្ញាណ, ការគោរព និងការអភិរក្សកោដ្ឋទាំងអស់ ដែលស្ទើរតែបាត់



គំនូរនៅក្នុងហោអដ្ឋិធាតុ ឬបណ្ណាល័យអដ្ឋិធាតុ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បង់ទៅដោយសារតែរបបខ្មែរក្រហម បង្កឡើងកាលពីជាង៥០ឆ្នាំមុន ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាកិច្ចការបំពេញបន្ថែមចំពោះការតស៊ូតតឈប់ឈរ ក្នុងការឆ្លើយតបចំពោះអំពើប្រល័យពូជសាសន៍លើវប្បធម៌ ដែលបានកើតមានពីអតីតកាល ព្រមទាំងបានបន្តរហូតមកដល់សព្វថ្ងៃ។

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមចូលរួមផ្សព្វផ្សាយ និងអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម

***លី វេជវីត***



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចូលរួមផ្សព្វផ្សាយ និងអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសហគមន៍ និងសាលារៀន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អស់រយៈពេល១១ខែ ក្នុងឆ្នាំ២០២៣នេះ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម អនុវត្តកិច្ចការងារស្នូលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងការចងក្រងឯកសារ ការអប់រំ និងផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ដើម្បីសម្រេចបានគោលបំណងនេះ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ធ្វើការសហការជាមួយភាគីពាក់ព័ន្ធចាប់តាំងពីរដ្ឋបាលសាលាខេត្តរហូតដល់ថ្នាក់មូលដ្ឋានភូមិឃុំ, បណ្ដាញសមាគម អង្គការ និងគ្រឹះស្ថានសិក្សានៅខេត្តកំពង់ចាម ក្នុងការផ្ដល់កម្មវិធីអប់រំបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

ក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២-២០២៣ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលបានលិខិតសរសើរពីឯកឧត្តម អ៊ុន






KINGDOM OF CAMBODIA
NATION RELIGION KING
BSDA
CERTIFICATE OF APPRECIATION
Buddhism for Social Development Action (BSDA)
would like to thank
The Documentation Center of Cambodia, Kampong Cham Branch
for participating the training courses on "Communication Strategy, Team Building, Leadership Skills, All Policies Required for NGOs, Fund-raising Strategy, Resource Mobilization, Concept Note, Full Proposal Writing, Advocacy Strategy, Monitoring & Evaluation System, Financial Management and Internal Control System" for Kampong Cham NGO Network Members in 2023.

*ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចូលរួមផ្សព្វផ្សាយ និងអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសហគមន៍ និងសាលារៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ចំពោះកិច្ចសហការល្អក្នុងការផ្តល់សេវាសង្គមនានា ដែលរួមមានការស្រាវជ្រាវចងក្រង និងផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការលើកកម្ពស់សុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ចំពោះកិច្ចសហកាជាមួយបណ្តាញសមាគម និងអង្គការ នៅខេត្តកំពង់ចាម មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម សហការជាមួយអង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម ក្នុងការបញ្ជូនបុគ្គលិកចូលរួមប្រជុំពិគ្រោះយោបល់ និងសិក្ខាសិលាជាបន្តបន្ទាប់។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ នេះ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលបានលិខិតសរសើរចំពោះកិច្ចសហការល្អរវាងអង្គការជាដៃគូក្នុងការចូលរួមពិគ្រោះយោបល់ និងចែករំលែកបទពិសោធន៍ទៅវិញទៅមកដើម្បីភាពប្រសើរឡើងក្នុងអង្គភាព។

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ក៏បានរៀបចំវេទិកាថ្នាក់រៀន វេទិកាអប់រំសហគមន៍ ដំណើរទស្សនកិច្ចសិក្សាទៅកាន់ទំនប់ខ្មែរក្រហម និងពិព័រណ៍រូបថត ដែលមានសិស្សប្រមាណ១៥០០នាក់ ក្នុងចំណោមវិទ្យាល័យ និងគ្រឹះស្ថានសិក្សាសរុបចំនួន៧បានចូលរួម។ នៅក្នុងកម្មវិធីនីមួយៗ សិស្សទទួលបានការយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបទពិសោធន៍ថ្មីៗ ជាពិសេសការជួបជជែកផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីដឹងអំពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ បន្ថែមលើនេះទៀត មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចូលរួមរៀបចំពិព័រណ៍របស់ខ្លួនដែលបែកចែកជា៣ផ្នែករួមមាន៖ ពិព័រណ៍រូបថតអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន៨០ផ្ទាំង, ការចាក់បញ្ចាំងវីដេអូឯកសារ និងការចែកទស្សនាវដ្តីស្វែងរកការពិត លេខពិសេសសម្រាប់ផ្សព្វផ្សាយរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីខ្មែរក្រហមនៅខេត្តកំពង់ចាម។

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តតួនាទីរបស់ខ្លួនជាមជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំសម្រាប់សិស្ស-និស្សិត អ្នកស្រាវជ្រាវ និងសាធារណជនក្នុងការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម សម្រាប់ឆ្នាំ២០២៤។

# យុវជនកម្ពុជាទីមួយ ណាល់ ស្ទីហ៊ិន ដារិទ្ធ ដែលសិក្សានៅសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស ទទួលបាន «ពានរង្វាន់ការសិក្សាអំពីសង្គ្រាម»

**ឆាំង យុ**



យុវជនកម្ពុជា ស្ទីហ៊ិន ណាល់ ទទួលពានរង្វាន់សិក្សាអំពីសង្គ្រាម ប៊ីគ្រេន ស្មុរីត ពីសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស តាមរយៈការវាយតម្លៃលើសំណេរស្រាវជ្រាវរបស់សិស្សនាយទាហានទាំង សិស្សនាយទាហានអង់គ្លេស និងអន្តរជាតិ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ណាល់ ស្ទីហ៊ិន ដារិទ្ធ ឬហៅក្រៅថា ស្ទីហ៊ិន ណាល់ គឺជាយុវជនកម្ពុជាទីមួយ ដែលបានសិក្សានៅសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស។ យុវជនរូបនេះ ទទួលបានពានរង្វាន់កិត្តិយសមួយ ក្នុងពេលបញ្ចប់ការសិក្សា នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣នេះ។

ព័ត៌មានស្ដីអំពីពានរង្វាន់ ដែល ស្ទីហ៊ិន ណាល់ បានទទួល មិនសូវជាត្រូវបានផ្សព្វផ្សាយទូលំទូលាយប៉ុន្មានទេ ក្រៅពីព័ត៌មានមួយដែលថា សំណេរស្រាវជ្រាវរបស់ ស្ទីហ៊ិន ត្រូវបានវិនិច្ឆ័យនិងជ្រើសរើសជាសំណេរដ៏ល្អបំផុត ក្នុងចំណោមសំណេរដាក់ចូលរួមដោយមិត្តរួមថ្នាក់ទាំងអស់របស់ខ្លួន។ ខុសប្លែកពីពានរង្វាន់អន្តរជាតិដទៃទៀត ស្ទីហ៊ិន ទទួលបានពានរង្វាន់នេះ មកពីការប្រកួតប្រជែងជាមួយនឹងសិស្សនាយទាហានអង់គ្លេស និងសិស្សនាយទាហានអន្តរជាតិដទៃទៀត។ នេះអាចនិយាយបានម្យ៉ាងទៀតថា ពានរង្វាន់ដទៃទៀត គឺត្រូវប្រគល់ជូនដល់សិស្សនាយទាហានអន្តរជាតិតែប៉ុណ្ណោះ។ ពានរង្វាន់ការសិក្សាអំពីសង្គ្រាម ប៊ីគ្រេន ស្មុរីត ត្រូវបានប្រគល់ជូនសំណេរស្រាវជ្រាវលេចធ្លោបំផុត (សរសេរឡើងដោយទាំងសិស្សនាយទាហាន

អង់គ្លេស ឬសិស្សនាយទាហានអន្តរជាតិ)។ ស៊ី ហ៊ិន បានយកឈ្នះលើសិស្សនាយទាហានអង់គ្លេស នៅក្នុងការប្រកួតសំណេរនេះ។

សូមស្វែងយល់អំពីព័ត៌មានខាងក្រោម ស្តីអំពីបុគ្គលល្បីល្បាញដទៃទៀត ដែលបានសិក្សានៅសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស និងថាតើសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេសជាអ្វី។

សាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស គឺជាទីតាំងបណ្តុះបណ្តាលមន្ត្រីយោធាអង់គ្លេសទាំងអស់ ដែលទទួលបន្ទុកដឹកនាំកងទ័ព។ នៅក្នុងអំឡុងពេលបណ្តុះបណ្តាល សិស្សនាយទាហានទាំងអស់ រៀនសូត្រដោយប្រកាន់ខ្ជាប់នូវទ្រឹស្តីរៀនសូត្រមួយ គឺ៖ «បម្រើដើម្បីដឹកនាំ»។ ប្រជាជាតិនានា បានជ្រើសរើសបញ្ជូនសិស្សនាយទាហានរបស់ខ្លួនទៅកាន់សាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស ដើម្បីចូលរួមទទួលការបណ្តុះបណ្តាលនេះ ពីព្រោះថា សាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស ត្រូវបានទទួលស្គាល់ថា ជាស្ថាប័នបណ្តុះបណ្តាលយោធាដ៏ឈានមុខគេកម្រិតពិភពលោក។ សិស្សនាយទាហានប្រមាណជាង៥៤០០រូប មកពីប្រទេសចំនួន១២៩ ទទួលបានការបណ្តុះបណ្តាលនៅស្ថាប័ននេះ បើគិតចាប់តាំងពីឆ្នាំ១៩៤៧។ សិស្សនាយទាហានអន្តរជាតិ បានផ្តល់ជាតម្លៃបន្ថែមដល់វគ្គសិក្សានៅស្ថាប័ននេះ តាមរយៈការនាំនាំមកជាមួយនូវវប្បធម៌ និងបទពិសោធន៍ប្រតិបត្តិការសឹក ពីជុំវិញពិភពលោក។ សិស្សនាយទាហាន ដែលត្រូវបានជ្រើសរើសដោយស្ថាប័នការពាររបស់ខ្លួននីមួយៗ ហើយសំណុំបែបបទនៃបេក្ខជននីមួយៗ ត្រូវបានបញ្ជូនទៅកាន់ក្រសួងការពារជាតិ តាមរយៈអនុព័ន្ធការពារជាតិ។

បុគ្គលល្បីល្បាញនានា ដែលបញ្ចប់ការសិក្សានៅសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេសរួមមាន៖ ព្រះអង្គម្ចាស់ ហារី ស្តេចត្រាញ់នៃរដ្ឋស័រសេច, ព្រះអង្គម្ចាស់ វីល្លាម រាជទាយាទនៃចក្រភពអង់គ្លេស, អាប់ដុលឡា ទីពីរ នៃប្រទេសហ្ស៊កដានី (ព្រះមហាក្សត្រប្រទេសហ្ស៊កដានី), និងអតីតនាយករដ្ឋមន្ត្រី វីនស្តិន ឆឺឈីល (នាយករដ្ឋមន្ត្រីអង់គ្លេស២ដងហើយ តែម្នាក់គត់ ដែលបានបញ្ចប់ការសិក្សាពី សាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស)។


យុវជនកម្ពុជា ស៊ី ហ៊ិន ណាល់ ទទួលពានរង្វាន់សិក្សាអំពីសង្គ្រាម ប៊ឺគ្រេន ស្មុរីត ពីសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស តាមរយៈការវាយតម្លៃលើសំណេរស្រាវជ្រាវរបស់សិស្សនាយទាហានទាំង សិស្សនាយទាហានអង់គ្លេស និងអន្តរជាតិ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពានរង្វាន់ព្រះខ័នអន្តរជាតិ៖ សិស្សនាយទាហាន គ្រីស្ទៀន ប៉ារីស មកពីសហរដ្ឋអាមេរិក (ឧបត្ថម្ភគាំទ្រដោយព្រះរាជាណាចក្រ គុយវ៉ែត) ត្រូវបានទទួលស្គាល់ថាជា សិស្សនាយទាហានអន្តរជាតិដ៏លេចធ្លោនៅក្នុងថ្នាក់។

ពានរង្វាន់អន្តរជាតិ៖ សិស្សនាយទាហាន គ្រីស្ទៀន ប៉ារីស មកពីសហរដ្ឋអាមេរិក (ឧបត្ថម្ភគាំទ្រដោយសាធារណរដ្ឋកាតា) ត្រូវបានទទួលស្គាល់ថាជា សិស្សនាយទាហានអន្តរជាតិ ដែលទទួលបានពិន្ទុខ្ពស់បំផុត ក្នុងជួរយោធា, ការសិក្សា និងការអនុវត្ត។ ពានរង្វាន់ព្រះចៅហ៊ូសេន៖ សិស្សនាយទាហាន ឪចាណា ហ្គូដីនិក មកពីប្រទេសម៉ុងតេណេហ្គ្រោ (ឧបត្ថម្ភ

គាំទ្រដោយព្រះរាជាណាចក្រហូកដានី) ត្រូវបានទទួលស្គាល់ថាជា សិស្សនាយទាហានមានការរីកចម្រើនលឿនបំផុតនៅក្នុងថ្នាក់។

ពានរង្វាន់កិត្តិយសនៃ ហូតសិន ហ៊ិស៖ សិស្សនាយទាហាន ម៉ូហាម៉ាត់ សាឡេម មកពីប្រទេសអេហ្ស៊ីប ត្រូវបានទទួលស្គាល់ថាជា សិស្សនាយទាហានមួយ ដែលបំពេញការសិក្សាជារួមបានល្អ សក្តិសមតាមតម្រូវការនៃពានរង្វាន់នេះ។

ពានរង្វាន់ពីមេបញ្ជាការ៖ បានបំពេញការសិក្សាគួរឲ្យកត់សម្គាល់ យោងតាមការវាយតម្លៃពីមេបញ្ជាការ។ អ្នកទទួលពានរង្វាន់នេះ រួមមាន សិស្សនាយទាហាន ស្ទេខ ខាលីដ អាល់ខាលីហ្វា មកពីប្រទេសបារ៉ែន និងសិស្សនាយទាហានសេហ្វ ម៉ូហាម៉ាត់ អាល់គីយូមិ មកពីប្រទេសអូម៉ង់។

ពានរង្វាន់សិក្សាអំពីសង្គ្រាម ប៊ីគ្រេន ស៊ូវីត៖ ត្រូវបានជ្រើសរើសដោយមេបញ្ជាការនៃសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស តាមរយៈការវាយតម្លៃលើសំណេរស្រាវជ្រាវរបស់សិស្សនាយទាហានទាំងអស់ (ទាំងសិស្សនាយទាហានអង់គ្លេស និងអន្តរជាតិ)។ ពានរង្វាន់មួយ ត្រូវបានប្រគល់ជូនដល់សិស្សនាយទាហាន ស៊ីហ៊ុន ណាល់ មកពីព្រះរាជាណាចក្រកម្ពុជា។ ស៊ីហ៊ុន គឺជាសិស្សនាយទាហានកម្ពុជាទីមួយ ដែលទទួលបានការបណ្ដុះបណ្ដាលនៅ សាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស។

ពានរង្វាន់នេះ ប្រគល់ជូនដល់សំណេរស្រាវជ្រាវស្ដីពីការសិក្សាអំពីសង្គ្រាមដែលល្អបំផុត តែងនិពន្ធដោយសិស្សនាយទាហាន នៃសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស នៅក្នុងជំនាន់នីមួយៗ។

សិស្សនាយទាហាន ស៊ីហ៊ុន ណាល់ បាននាំយកនូវមុខមាត់ថ្មីមួយ របស់យោធាកម្ពុជា ទៅកាន់សាកលលោក ហើយ ស៊ីហ៊ុន កំពុងបង្កើតប្រវត្តិ-សាស្ត្ររវាងចក្រភពអង់គ្លេស និងកម្ពុជា ដោយសារតែ ស៊ីហ៊ុន នឹងត្រូវបានគេស្គាល់ជារៀងរហូតថា ជានិស្សិតបញ្ចប់ការសិក្សារបស់កម្ពុជាដំបូងគេ នៃសាលាដ៏មានកិត្យានុភាព ដែលធ្លាប់ជាសាលាតែមួយដែលបានអប់រំ អតីតនាយករដ្ឋមន្ត្រីចក្រភពអង់គ្លេស វីនស្តុន ឆឺឈីល ព្រះមហាក្សត្រ ប្រមុខរដ្ឋ និងមេដឹកនាំនៃកងទ័ព។

យុវជនកម្ពុជា ស៊ីហ៊ុន ណាល់ ទទួលពានរង្វាន់សិក្សាអំពីសង្គ្រាម ប៊ីគ្រេន ស៊ូវីត ពីសាលារាជបណ្ឌិត្យសភាយោធា ចក្រភពអង់គ្លេស តាមរយៈការវាយតម្លៃលើសំណេរស្រាវជ្រាវរបស់សិស្សនាយទាហានទាំង សិស្សនាយទាហានអង់គ្លេស និងអន្តរជាតិ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# កែវ ម៉ុន ៖ អតីតកងចល័តលើកទំនប់ត្រួយចេក

ទូច វណ្ណេត



កែវ ម៉ុន អាយុ៨២ឆ្នាំ សព្វថ្ងៃរស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ កែវ ម៉ុន អាយុ៨២ឆ្នាំ កើតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំដដែល។ នៅឆ្នាំ១៩៦៥ ខ្ញុំរៀបការប្តីឈ្មោះ សុខ អ៊ុយ និងមានកូនប្រុសស្រីចំនួន២នាក់។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំមានឪពុកឈ្មោះ កែវ ចន និងម្តាយឈ្មោះ ម៉ន។ ខ្ញុំគឺជាកូនទី២ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៣នាក់។

កាលពីក្មេងខ្ញុំរៀននៅសាលាបឋមសិក្សាកំពង់ក្របី។ ខ្ញុំរៀនដល់ថ្នាក់ទី៩ សង្គមចាស់។ បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំឃើញបាតុកម្មប្រឆាំងរដ្ឋប្រហារបានផ្ទុះឡើង និងមានក្បួនបាតុករដង្ហែទៅ ទីរួមខេត្តកំពង់ចាម។

នៅឆ្នាំ១៩៧១ មានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ដូច្នេះក្រុមគ្រួសារខ្ញុំក៏បានភៀសខ្លួនទៅរស់នៅ ទីក្រុងភ្នំពេញ។ ក្រុមគ្រួសាររបស់ខ្ញុំបានធ្វើដំណើរទៅរស់នៅតាខ្មៅរយៈពេលកន្លះឆ្នាំ។ នៅឆ្នាំ១៩៧២ ខ្ញុំនិងក្រុមគ្រួសារបានវិលត្រឡប់មកស្រុកកំណើតដែលពេលនោះគ្រប់គ្រងដោយកងទ័ពរំដោះខ្មែរក្រហម។

នៅឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាមត្រូវបានឡោមព័ទ្ធទៅដោយកងទ័ពរំដោះខ្មែរក្រហមគឺមានតែផ្លូវទឹកប៉ុណ្ណោះដែលជាផ្លូវអាចចូលមកដល់ទីរួមខេត្ត។ នៅពេលទាហានម៉ារីន លន់ នល់ បើក

នាវាដឹកស្បៀង និងសម្ភារសឹកពីទីក្រុងភ្នំពេញមក ទីរួមខេត្តកំពង់ចាមម្តងៗ គឺតែងតែទទួលរងការវាយប្រហារពីកងទ័ពរំដោះខ្មែរក្រហមពីត្រើយម្ខាងទន្លេមេគង្គ។ ដូច្នេះនៅពេលឮសំឡេងម៉ារីនបើកមក ខ្ញុំត្រូវរត់ចូលរណ្ដៅត្រង់សេដើម្បីលាក់ខ្លួន ពីព្រោះមានការប្រយុទ្ធគ្នារវាងទាហានម៉ារីន និងកងទ័ពរំដោះខ្មែរក្រហមខ្លាំងក្លាណាស់។

នៅពាក់កណ្ដាលឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមវាយរំដោះបានពាក់កណ្ដាលនៃទីរួមខេត្តកំពង់ចាម និងនៅបន្តប្រយុទ្ធជាមួយទាហាន លន់ នល់ ដែលនៅសេសសល់។ នៅឆ្នាំ១៩៧៤ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅក្នុងកងសាមគ្គី។ បន្ទាប់មកទៀតនៅឆ្នាំ១៩៧៥ ខ្ញុំធ្វើការក្នុងកងប្រវាស់ដៃ ដើម្បីជួយប្រូតស្រូវ និងប្រមូលផលដំណាំផ្សេងៗ ចែកគ្នាហូប។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្ដើមបង្កើតជាសហករណ៍ និងបែងចែកប្រជាជនឲ្យធ្វើការនៅកងចល័តនៅតាមការដ្ឋាននានា។ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅកងចល័តដែលមានទិសដៅលើកទំនប់ត្រួយចេក ស្ថិតនៅឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំត្រូវក្រោកនៅម៉ោង៤ទៀបភ្លឺ ដើម្បីទៅប្រជុំជួរ និងស្ដាប់អំពីផែនការរបស់ខ្មែរក្រហមដាក់ឲ្យធ្វើប្រចាំថ្ងៃ។ ខ្ញុំចាប់ផ្ដើមធ្វើការពីម៉ោង៦ព្រឹក ដល់ម៉ោង១១ ទើបឈប់សម្រាកហូបបបរនៅពេលបាយរួមរួចហើយ ខ្ញុំត្រូវបន្តធ្វើការចាប់ពីម៉ោង១ ដល់ម៉ោង៥ល្ងាច។ ខ្ញុំលើកទំនប់ត្រួយចេកបានរយៈពេល៦ខែ ទើបខ្មែរក្រហមបញ្ជូនខ្ញុំទៅជីកប្រឡាយនៅក្រឡាបន្តរយៈពេល៦ខែទៀត។

នៅរដូវប្រូតកាត់ ខ្ញុំត្រូវងើបពីម៉ោង៣ទៀបភ្លឺ ដើម្បីដើរទៅកន្លែងប្រូតដោយមានគ្នាចំនួន១៥នាក់ ប្រូតឲ្យហើយក្នុង១ហិកតា។ ខ្ញុំចាប់ផ្ដើមប្រូតដល់ម៉ោង១១ព្រឹក ទើបឈប់សម្រាកហូបបបរ។ ខ្ញុំបន្តធ្វើការចាប់ពីម៉ោង១២ រហូតដល់ម៉ោង៥ល្ងាច។ ប្រសិនបើខ្ញុំប្រូតស្រូវមិនហើយតាមផែនការ ខ្ញុំត្រូវធ្វើការដល់ម៉ោង៩យប់ ទាល់តែរួចទើបអាចឈប់សម្រាកបាន។ នៅពេលប្រូតរួច ខ្ញុំត្រូវចងកណ្ដាប់ស្រូវជាមួយកងចល័ត។ នៅពេលនោះ មិត្តជា បានបើកគម្របកាម៉ែលរបស់ខ្ញុំមើលឃើញបាយ ក៏បានសួរខ្ញុំថា កងមិត្តឯងហូបបាយយ៉ាងម៉េចនៅសល់។ ខ្ញុំបានឆ្លើយប្រាប់ថា បាយរួមទេ គេឲ្យខ្ញុំយួរ។ ខ្ញុំត្រូវបានចោទប្រកាន់ ប៉ុន្តែអ្នកធ្វើការជាមួយជួយនិយាយបន្ថែមថា គឺជាបាយរួម។ ពេលនោះ ខ្ញុំភិតភ័យញ័រដូចកូនសត្វ ហើយកុំតែបានអ្នកចងកណ្ដាប់ស្រូវជាមួយគ្នាជួយនិយាយ កុំអីខ្មែរក្រហមយកខ្ញុំទៅសម្លាប់ចោលបាត់ទៅហើយ។

នៅឆ្នាំ១៩៧៨ ខ្ញុំបានធ្លាក់ខ្លួនឈឺ និងមកព្យាបាលនៅមន្ទីរពេទ្យក្រឡា។ ពេលនោះមានមិត្តនារីម្នាក់ឈ្មោះ ភាព បានយល់សប្តិថាមានតាឥសីម្នាក់ស្លៀកពាក់ស ពុកមាត់វែងស្រម៉ូម មាឌធំហើយខ្ពស់ និយាយប្រាប់នៅខែមួយ ថ្ងៃមួយ មានគេមកជួយរំដោះហើយ។ ស្រាប់តែដល់ខែមួយ ថ្ងៃមួយ ខ្ញុំបានឮសំឡេងគ្រាប់ផ្លោងចេញពីទន្លេបិទ សំដៅមកភ្នំប្រុសភ្នំស្រី និងបាញ់ផ្សែងពុល។ ខ្ញុំបានឃើញកងទ័ពខ្មែរក្រហមបាក់ទ័ពរត់គេចខ្លួន ចំណែកកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយចូលមករំដោះប្រជាជនចេញពីការកាប់សម្លាប់របស់ខ្មែរក្រហម។ ខ្ញុំបានរួចផុតពីសេចក្តីស្លាប់នៅពេលនោះមករស់នៅភូមិជាមួយគ្រួសារវិញ។



ទិដ្ឋភាពភូមិចំការសាមសិប ថតពីលើអាកាស។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# គង់ សុខ ៖ ខ្ញុំនៅតែសោកស្ដាយដោយសារខ្ញុំធ្លាក់ខ្លួនពិការ

**ផាង សម្ផស្ស**



គង់ សុក អាយុ៦៧ឆ្នាំ បច្ចុប្បន្នរស់នៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គង់ សុខ ភេទប្រុស អាយុ៦៧ឆ្នាំ មានទីកន្លែងកំណើតនៅភូមិព្រែកតូច ឃុំព្រែកទម្លាប់ ស្រុកលើកដែក ខេត្តកណ្ដាល។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តមានជ័យ។ ខ្ញុំមានបងប្អូនចំនួន៣នាក់ ហើយខ្ញុំគឺជាកូនពៅនៅក្នុងគ្រួសារ។ ខ្ញុំបានឈប់រៀនត្រឹមថ្នាក់ទី១២ពីសង្គមចាស់ ដោយសារនៅសម័យនោះឪពុកម្ដាយភាគច្រើនមិនសូវយកចិត្តទុកដាក់ និងមិនសូវឲ្យតម្លៃលើការសិក្សារបស់កូនៗឡើយ។ ឪពុកម្ដាយរបស់ខ្ញុំច្រើនតែប្រើកូនៗជួយធ្វើស្រែចម្ការ ដូច្នេះកូនៗមិនសូវបានទៅរៀនសូត្រជាប់លាប់ឡើយ។

ចំណែករឿងដែលខ្ញុំចងចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហម គឺនៅពេលដែលខ្ញុំដើរយាមល្បាតនៅព្រំដែន ហើយមិនបានប្រយ័ត្នក៏ជាន់ចំគ្រាប់មីនបណ្ដាលឲ្យផ្ទុះដាច់ជើងម្ខាង។ ខ្ញុំបានសន្លប់ ហើយនៅពេលដឹងខ្លួនវិញខ្ញុំមានអារម្មណ៍សោកស្ដាយជាខ្លាំងដែលខ្ញុំធ្លាក់ខ្លួនពិការ។

ខ្ញុំចូលធ្វើកងទ័ពខ្មែរក្រហមនៅអាយុ១៦ឆ្នាំ។ ខ្ញុំសម្រេចចិត្តចូលកងទ័ពខ្មែរក្រហមដោយសារខ្មែរក្រហមប្រកាសរើសកងទ័ព។ ខ្មែរក្រហមនិយាយថា ប្រសិនបើខ្ញុំចូលបម្រើកងទ័ព នឹងឲ្យហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធានៅក្នុងស្រុកភូមិ គឺមិនបញ្ជូនប្

ជម្លៀសទៅទីណាឡើយ ហើយម៉្យាងទៀតពេលនោះ មានអ្នកស្គាល់ខ្ញុំម្នាក់ឈ្មោះ ខេង គឺជាអ្នកភូមិជាមួយខ្ញុំ បានបបួលខ្ញុំ ទើបខ្ញុំសម្រេចចិត្តចូលធ្វើកងទ័ពចាប់តាំងពីពេលនោះមក។ ចូលកងទ័ពដំបូង ខ្មែរក្រហមមិនបានឲ្យខ្ញុំទៅ ហ្វឹកហាត់ភ្លាមទេ គឺឲ្យខ្ញុំទៅធ្វើការងារបោចស្មៅនៅវាលស្រែអស់រយៈពេលបីខែ ក្រោយមកទើបឲ្យខ្ញុំចូលហ្វឹកហាត់ក្នុងក្បួនយុទ្ធសាស្ត្រទ័ព។ ដំបូងមិនសូវមានមនុស្សចូលហាត់ទេ គឺមានតែបួននាក់ប៉ុណ្ណោះ។ ខ្មែរក្រហមឲ្យខ្ញុំទៅ ហ្វឹកហាត់នៅតាមមាត់ទន្លេបាសាក់ (ក្នុងស្រុកកោះធំ)។ ខ្មែរក្រហមបានបង្ហាត់បច្ចេកទេសខាងឡើងវាយប្រយុទ្ធ មានដូចជា លូន ក្រាប និងបាញ់រយៈពេលមួយខែកន្លះ។ របបអាហារនៅពេលហ្វឹកហាត់ ខ្មែរក្រហមមិនសូវឲ្យខ្ញុំហូបគ្រប់គ្រាន់ទេ ពេលខ្លះហូបបបរមួយថ្ងៃពីរពេល ពេលខ្លះក៏ទទួលបានបបរបីពេល។ ក្រោយមក ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅនៅតាមអង្គភាព។

អង្គភាពខ្ញុំមានកងទ័ពប្រហែល ២០០-៣០០នាក់ និងមានឈ្មោះ សុខ គឺជាប្រធាន។ ក្រោយមក ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅប្រយុទ្ធចល័តតាមសមរភូមិ ដោយដំបូងខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅវាយនៅសមរភូមិផ្លូវជាតិលេខ១ បន្ទាប់ពីសមរភូមិនៅផ្លូវជាតិលេខ១ ខ្ញុំបន្តទៅវាយនៅស្វាយរលំ និងចាក់អង្រែលើ។ ថ្ងៃមួយ ខ្ញុំបានលួចរត់ទៅលេងគ្រួសារបានមួយរយៈ ខ្មែរក្រហមក៏ដឹងហើយចាប់ខ្ញុំយកមកដាក់នៅអង្គភាពវិញ។

ពីឆ្នាំ១៩៧៤ ដល់ឆ្នាំ ១៩៧៥ ខ្ញុំត្រូវរបួសដោយសារកងទ័ព លន់ នល់ បាញ់ត្រូវ ព្រោះខ្ញុំគឺជាកងទ័ពនៅខ្សែត្រៀមជួរមុខរបស់ខ្មែរក្រហម។ ខ្ញុំវាយជាមួយកងទ័ព លន់ នល់ ចាប់ពីតាខ្មៅ ឆ្ពោះទៅទីក្រុងភ្នំពេញ ប៉ុន្តែរបួសខ្ញុំក៏បានរើឡើងវិញ ទើបខ្ញុំស្នើសុំគ្រូពេទ្យត្រឡប់ទៅសម្រាកនៅជំរំកងទ័ពវិញ ដូច្នេះខ្ញុំមិនបានវាយចូលទីក្រុងភ្នំពេញជាមួយកងទ័ពដទៃទេ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះលើកងទ័ពរបស់លោកលន់នល់នៅទីក្រុងភ្នំពេញធ្វើឲ្យខ្ញុំសប្បាយចិត្តយ៉ាងខ្លាំង ដោយគិតថាប្រទេសទទួលបានសន្តិភាពនិងលែងមានសង្គ្រាមទៀតហើយ។ ប្រហែលមួយឆ្នាំក្រោយមក ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅនៅខេត្តរតនគិរី។ អំឡុងពេលនៅខេត្តរតនគិរី ខ្ញុំបានធ្វើស្រែចម្ការ និងបានឃើញប្រជាជនប្រមូលផលស្រូវជាច្រើន ប៉ុន្តែខ្មែរក្រហមឲ្យប្រមូលយកទៅដាក់ក្នុងឃ្លាំងនិងជម្រុក ហើយបានដឹកចេញ។ ខ្ញុំមិនដឹងថាខ្មែរក្រហមដឹកស្រូវទាំងនោះយកទៅទីណាឡើយ។

មកដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនខ្ញុំរួមទាំងកងទ័ពដទៃទៀតទៅព្រំដែន ដើម្បីវាយតទល់ជាមួយកងទ័ពវៀតណាមរយៈពេល៥ខែ។ នៅពេលនោះកងទ័ពខ្មែរក្រហមបានស្លាប់អស់ជាច្រើន ហើយមេបញ្ជាការខ្មែរក្រហមក៏ចាប់ផ្ដើមដកកងទ័ពបន្តិចម្ដងៗ ។ នៅឆ្នាំ១៩៧៩ ខ្មែរក្រហមបានរំសាយនិងដកកងទ័ពទាំងអស់លែងប្រយុទ្ធ ហើយខ្ញុំបានរត់ទៅរស់នៅជំរំហួរណាយ។ ចំណែកកងទ័ពវៀតណាមបន្តវាយចូលមកប្រទេសកម្ពុជា។ នៅឆ្នាំ១៩៨៤ ខ្ញុំជាន់មីននៅឃុំទំនប់ដាច់ ជាប់ឃុំព្រះប្រឡាយ ក្នុងស្រុកត្រពាំងប្រាសាទគ្រប់គ្រងដោយ តាម៉ុក អំឡុងពេលខ្ញុំដើរយាមល្បាតហើយមិនបានប្រយ័ត្ន។ ពេលខ្ញុំត្រូវរបួស កងទ័ពបានបញ្ជូនខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យនៅលើភ្នំដងរែក ឬហៅថាមន្ទីរពេទ្យផ្កាម្ទេស។ បន្ទាប់មក តាម៉ុក បានឲ្យខ្ញុំទៅរស់នៅរួមគ្នានៅជំរំជនពិការ។ តាម៉ុក បានផ្ដល់ អាហារ និងស្បៀងផ្សេងៗឲ្យខ្ញុំ និងបានឲ្យខ្ញុំបិតចម្រុង ។ នៅឆ្នាំ១៩៨៥ ខ្ញុំបានរៀបការជាមួយនារីដឹកជញ្ជូន។ បន្ទាប់ពីរៀបការរួច ខ្ញុំនៅធ្វើការងារជាអ្នកបិតចម្រុងនៅជំរំដដែល។ ពេលនោះខ្ញុំបានសង់ខ្ទមរស់នៅជាមួយប្រពន្ធ និងហូបអាហារជុំគ្នាជាមួយគ្រួសារ។ នៅឆ្នាំ១៩៩០ ខ្ញុំមានកូន២នាក់ ហើយតាម៉ុក បានឲ្យប្រជាជនទាំងអស់ចុះពីលើភ្នំមករស់នៅក្នុងភូមិស្រុកវិញ។ ខ្ញុំនិងគ្រួសារបានចុះពីលើភ្នំដងរែកមករស់នៅភូមិជើងភ្នំ ក្នុងស្រុកអន្លង់វែងរហូតមកដល់សព្វថ្ងៃ។

# ជឹម យ៉ុម ៖ ឪពុកខ្ញុំធ្លាក់ខ្លួនឈឺស្លាប់ដោយសារធ្វើការងារធ្ងន់ក្នុងរបបខ្មែរក្រហម

*សេន ពន្លឺ*



*ជឹម យ៉ុម អាយុ៥៥ឆ្នាំ និងចៅស្រី បច្ចុប្បន្នរស់នៅភូមិស្នាយបុណ្យ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ជឹម យ៉ុម អាយុ៥៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្នាយបុណ្យ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ នៅក្នុងរបបខ្មែរក្រហមខ្ញុំនៅកុមារដូច្នេះខ្មែរក្រហមប្រើខ្ញុំឲ្យឃ្វាលក្របី និងរៀនអក្សរបានតិចតួចពេលសម្រាកពីឃ្វាលក្របី។ ពេលក្របីស៊ីស្មៅមិនឆ្អែត ហើយទៅស៊ីស្រូវ ពូជីដូនមួយរបស់ខ្ញុំ ដែលជាកម្មាភិបាលខ្មែរក្រហមវាយខ្ញុំបីខ្សែតី ធ្វើឲ្យខ្ញុំឈឺចាប់យ៉ាងខ្លាំង។ ពូរបស់ខ្ញុំមិនអត់ឱនឲ្យខ្ញុំឡើយ និងប្រាប់ខ្ញុំថា អង្គការនឹងបង្អត់អាហារមួយថ្ងៃថែមទៀតផង ប្រសិនបើក្របីស៊ីស្រូវម្តងទៀត។

ខ្ញុំត្រូវទៅឃ្វាលក្របីដូចសព្វមួយដង ស្រាប់តែថ្ងៃមួយ ខ្ញុំបានឃើញត្រីងាប់ ក៏រើសត្រីនោះបម្រុងយកទៅដុតដើម្បីបានហូបឆ្ងាញ់។ ខ្ញុំបានទៅដើរទៅសុំអំបិលពីរោងបាយយកមកហូបជាមួយត្រីដុត

ប៉ុន្តែត្រូវអ្នកគ្រប់គ្រងផ្ទះបាយ ស្តីឲ្យខ្ញុំថាយកអំបិលធ្វើអី ព្រមទាំងវាយខ្ញុំថែមទៀត។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំទទួលរបបបបរ ឬបាយមួយកូនចានតូចតែប៉ុណ្ណោះក្នុងមួយពេល។ ចំណែកសម្លមានតែបន្លែស្រោចលាមកដែលគ្មានអនាម័យ និងគ្មានគ្រឿងផ្សំត្រឹមត្រូវឡើយ ហេតុនេះពេលដល់ម៉ោងហូបអាហារម្តងៗ ខ្ញុំសុខចិត្តហូបបាយជាមួយអំបិល ព្រោះខ្ញុំខ្ពើមបន្លែដែលលាងមិនស្អាត។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានសំណាងដោយសារកងទ័ពខ្មែរក្រហមឲ្យបាយខ្ញុំហូបជារឿយៗ។ ដោយសារបានបាយហូប ខ្ញុំក៏ខំប្រឹងស្ម័គ្រចិត្ត... ដោយសារបានបាយហូប ខ្ញុំក៏ខសង្រ្គាហ៍យកក្របីទៅឃ្វាលនៅម្តុំបន្ទាយទាហាន ស្ថិតនៅក្នុងភូមិបេកធ្លក។ ខ្ញុំមិនមានខោអាវស្លៀកពាក់ត្រឹមត្រូវឡើយ ព្រោះមិនទាន់គ្រប់អាយុដែលអង្គការចែកក្រណាត់ខោអាវឲ្យ។ ខ្ញុំមានតែខោអាវមួយសម្រាប់ពាក់ជាប់ខ្លួន។

ខ្ញុំមានបងប្អូនស្លាប់នៅក្នុងសម័យខ្មែរក្រហមម្នាក់ដោយសារតែគាត់ធ្វើជាកងទ័ពរបស់ខ្មែរក្រហមក្នុងឆ្នាំ១៩៧៧-៧៩។ បងខ្ញុំឈ្មោះ ជឹម សាំ បានស្លាប់នៅមន្ទីរពេទ្យវត្តជីផុចមានទីតាំងស្ថិតនៅក្នុងវត្តជីផុចនាពេលបច្ចុប្បន្ន បន្ទាប់ពីគាត់ត្រូវរបួសមកសម្រាកព្យាបាលនៅមន្ទីរពេទ្យនេះ។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងគ្រួសារមិនហ៊ានស្នាក់នៅផ្ទះដែលស្ថិតជិតផ្លូវទេ គឺខ្ញុំទៅរស់នៅភូមិស្នួល ស្រុកបាភ្នំ។ ពេលធ្វើដំណើរតាមផ្លូវ ខ្ញុំបានឃើញរោងបាយមួយ ប៉ុន្តែរោងបាយនោះគ្មានសេសសល់អ្វីឡើយ គឺសល់តែទឹកប៉ុណ្ណោះ។ ខ្ញុំយកទឹកនោះមកប្រើប្រាស់ និងមកដឹក។ ពេលយប់ ខ្ញុំរកកន្លែងដែលមានទីធ្លាស្រឡះ ហើយដេកផ្ទាល់ដីតែម្តង។ ខ្ញុំធ្វើដំណើរចេញពីភូមិប្រមាណ៣ទៅ៤ថ្ងៃ ស្រាប់តែម៉ោង១២យប់ មានរថយន្តបើកមកពីទិសខាងលិចប្រាប់ថា បងប្អូនកុំទៅទិសខាងលិចទៀត ត្រូវត្រឡប់មកកើតវិញ ទើបខ្ញុំនិងគ្រួសារត្រឡប់មករស់នៅផ្ទះស្ថិតនៅភូមិស្វាយបុណ្យរហូតមកដល់សព្វថ្ងៃ។

ក្រោយពីប្រទេសកម្ពុជាត្រូវបានរំដោះពីរបបខ្មែរក្រហម នៅឆ្នាំ១៩៧៩ ឪពុករបស់ខ្ញុំធ្លាក់ខ្លួនឈឺគ្រាំក្នុងដោយសារធ្វើការហួសកម្លាំងក្នុងរបបខ្មែរក្រហម។ ឪពុករបស់ខ្ញុំ បានក្អួតឈាមរហូតដល់គាត់ស្លាប់។



សិស្សបឋមសិក្សាក្នុងស្រុកមេសាង ខេត្តព្រៃវែង កំពុងជិះកង់ទៅសាលារៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជុំ សារ៉េត ៖ លាក់ប្រវត្តិរូបព្រោះខ្លាចខ្មែរក្រហមសម្លាប់

ឌី ស៊ីថា



ជុំ សារ៉េត អាយុ៩២ឆ្នាំ សព្វថ្ងៃរស់នៅភូមិលាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជុំ សារ៉េត អាយុ៩២ឆ្នាំ មានស្រុកកំណើតនៅភូមិលាជលើ ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ ឪក និងម្តាយឈ្មោះ ជុំ ស៊ូ។ ខ្ញុំមានបងប្អូន៣នាក់ គឺស្រី២នាក់ និងប្រុស១នាក់។ កាលពីកុមារ ខ្ញុំបានសិក្សារៀនសូត្រ និងបួសជាសង្ឃ។ នៅឆ្នាំ១៩៥០ ប្រជាជននៅក្នុងប្រទេសកម្ពុជាទាំងអស់រស់ក្រោមការគ្រប់គ្រងរបស់បារាំង ហើយក្រុមឥស្សរក៏កើតឡើងដែរ។ ចំណែកខ្ញុំបានចូលធ្វើទ័ពជាមួយឥស្សរ។ សម័យនោះប្រជាជនខ្លះគេចខ្លួនទៅរស់នៅក្នុងព្រៃប៉ុន្តែការហូបចុកគ្រប់គ្រាន់។ ក្រោយមក ប្រជាជនប្រកបរបរធ្វើស្រែចម្ការធម្មតា ហើយពេលប្រមូលផលបាន គឺទុកក្នុងផ្ទះរៀងៗខ្លួន។ ប្រជាជនរស់នៅក្នុងភូមិធម្មតា និងប្រកបរបរធ្វើស្រែចម្ការលក់ដូរទៅតាមសមត្ថភាពរបស់ខ្លួន។ ប្រជាជនខ្លះធ្វើស្រែចម្ការបានច្រើន និងសម្បូរសប្បាយ។

មួយរយៈក្រោយមក មានយន្តហោះមកទម្លាក់គ្រាប់នៅស្រុកមេមត់ ហើយចំប្រជាជនមួយចំនួន។ ចំណែកភូមិលាជលើក៏មានការទម្លាក់គ្រាប់បែកដែរ ប៉ុន្តែមិនត្រូវប្រជាជនទេ ព្រោះប្រជាជនលាក់ខ្លួនក្នុងរណ្តៅត្រង់សេតាមផ្ទះរៀងៗខ្លួន។ ពេលនោះខ្ញុំមិនបានរស់នៅជុំបងប្អូន និងឪពុកម្តាយទេ គឺខ្ញុំរស់នៅជាមួយគ្រូរបស់ខ្ញុំសម្តេចសង្ឃ ជួន ណាត និងបានចូលបួសបាន៨វស្សា។ បន្ទាប់ពីខ្ញុំសឹក ខ្ញុំបានចូលធ្វើទាហាន លន់ នល់។

លុះដល់ពេលកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញទាំងមូល នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជននៅទូទាំងប្រទេស។ រីឯខ្ញុំវិញត្រូវបានកងទ័ពខ្មែរក្រហមជម្លៀសចេញពីភូមិស្រុកឲ្យទៅរស់នៅកន្លែងផ្សេងឆ្ងាយពីគ្រួសារ។ អំឡុងពេលនោះ ខ្មែរក្រហមបានជម្លៀសខ្ញុំទៅអាលួច ក្នុងស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំបានលាក់ប្រវត្តិរូបមិនឲ្យខ្មែរក្រហមដឹងថា ខ្ញុំធ្លាប់បួសរៀន និងធ្លាប់ធ្វើជាទាហាន លន់ នល់ ឡើយ។ ប្រសិនបើខ្មែរក្រហមបានដឹងថាខ្ញុំធ្លាប់ធ្វើជាទាហានពីមុនមកច្បាស់ជាត្រូវខ្មែរក្រហមយកខ្ញុំទៅសម្លាប់

ចោលមិនខាន។ នៅពេលខ្មែរក្រហមជម្លៀសខ្ញុំទៅដល់ខេត្តក្រចេះ ខ្មែរក្រហមបានឲ្យខ្ញុំនៅខាងកាស់គល់ឈើ និងធ្វើស្រែរយៈពេល២ខែ។ បន្ទាប់ពីនោះមក ខ្ញុំត្រូវបានកងទ័ពខ្មែរក្រហមចាត់តាំងឲ្យធ្វើខាងនេសាទត្រី។ ថ្ងៃមួយពេលកំពុងនេសាទត្រី ខ្ញុំបានឈ្លោះគ្នាជាមួយកងទ័ពខ្មែរក្រហម៦នាក់ ក្នុងចំណោមនេះខ្ញុំនៅចាំឈ្មោះកងទ័ពខ្មែរក្រហមតែម្នាក់ឈ្មោះ ឃ្នាង ពីព្រោះ ឈ្មោះ ឃ្នាង គឺជាប្រធាន ហើយដើរប្រមាថគេឯង ប៉ុន្តែខ្ញុំមិនខ្លាចឡើយ។ ខ្ញុំបានប្រមាថកាប់កងទ័ពខ្មែរក្រហមវិញ ដែលមកគំរាមកំហែងគ្រាន់តែរឿងលេចទូកនៅព្រែកទេរ។ កងខ្ញុំមានគ្នា៦នាក់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពខ្មែរក្រហម។ សមាជិកផ្សេងមិនហ៊ានតវ៉ាជាមួយកងទ័ពខ្មែរក្រហមដូចខ្ញុំឡើយ។ កន្លែងខ្ញុំស្នាក់នៅគឺនៅរោងផ្សេង ចំណែកបាយទឹកគឺដាំហូបតាមកងរៀងខ្លួន។ នៅពេលនោះ ប្រធានសហករណ៍ម្នាក់បានបររទេះបម្រុងកិនក្បាលប្អូនខ្ញុំ ទើបខ្ញុំទាញកាំបិតរកកាប់ប្រធានសហករណ៍នោះចោល។ ក្រោយមកខ្ញុំបានឃើញ និងជួបហេតុការណ៍ដ៏រន្ធត់បំផុត គឺប្រជាជនដើរជាន់គ្រាប់មីនផ្ទុះស្លាប់ជាច្រើននាក់។ នៅពេលយប់ កងឈ្លបដើរលបមើលប្រជាជន ថាតើមានអ្នកណាប្រព្រឹត្តខុស និងចាប់យកទៅសម្លាប់ចោលភ្លាម។ នៅអំឡុងពេលនោះ កូនស្រីរបស់ខ្ញុំម្នាក់បានស្លាប់ដោយសារតែអត់អាហារ។

នៅក្នុងឆ្នាំ១៩៧៦ ខ្មែរក្រហមរៀបចំការឲ្យយុវជន-យុវនារី ដែលប្រជាជនភាគច្រើននិយាយថា អង្គការអ្នករៀបចំឲ្យ។ ក្នុងពេលរៀបការម្តងៗ គឺមានចាប់ពី២០គូឡើងទៅ។ សម្រាប់ក្មេងៗនៅក្នុងរបបខ្មែរក្រហមមិនបានរៀនសូត្រទេ សូម្បីតែពេលទំនេរក៏គ្មានដែរ។ ខ្មែរក្រហមឲ្យក្មេងៗទៅដកស្មៅ និងឃ្វាលគោក្របី។ ខ្មែរក្រហមជម្លៀសខ្ញុំទៅនៅខេត្តក្រចេះមួយរយៈ ក៏ជម្លៀសបន្តទៅស្រុកចំការលើ ខេត្តកំពង់ចាម។ ពេលនៅស្រុកចំការលើខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅអារឈើធ្វើសម្ភារប្រើប្រាស់។ ចំណែកកាំភ្លើងដែលខ្ញុំដាក់ជាប់ខ្លួន ខ្ញុំបានយកទៅលាក់ទុក ព្រោះខ្ញុំមិនចង់ឲ្យខ្មែរក្រហមឃើញ ម៉្យាងទៀតខ្លាចយកខ្ញុំទៅអប់រំ។ នៅស្រុកចំការលើខ្ញុំបានហូបគ្រប់គ្រាន់មិនដូចខាងអាលួច ខេត្តក្រចេះ ដែលហូបតែបបរទេ។

នៅឆ្នាំ១៩៧៩ ខ្ញុំបានទទួលដំណឹងថា ប្រទេសបានរំដោះហើយ។ ពេលនោះខ្ញុំក៏ធ្វើដំណើរដោយថ្មើរជើងត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំបានធ្វើដំណើររយៈពេលប្រហែលមួយសប្តាហ៍ ទើបមកដល់ស្រុកមេមត់។ អំឡុងពេលធ្វើដំណើរ ខ្ញុំបានឃើញសាកសពប្រជាជនស្លាប់ជាច្រើននៅតាមបណ្តោយផ្លូវ។ សាកសពខ្លះស្លាប់ដោយសារកងទ័ពខ្មែរក្រហមបាញ់ សាកសពខ្លះទៀត ស្លាប់ដោយអត់អាហារក៏មានដែរ។ ពេលធ្វើដំណើរត្រឡប់មកវិញ ខ្ញុំបានជួបជុំបងប្អូននៅតាមផ្លូវ ប៉ុន្តែអកុសល ប្អូនខ្ញុំម្នាក់ដែលជិះរទេះតែឯង ក៏បរកិនលើគ្រាប់មីនបណ្តាលផ្ទុះស្លាប់។ ខ្ញុំបានបាត់សមាជិកគ្រួសារម្នាក់ ទម្រាំតែធ្វើដំណើរមកដល់ភូមិកំណើតវិញ។



ចាស់ទុំនៅភូមិលាចលើ ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ចូលរួមវេទិកាសាធារណៈ ស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# បងស្រី ប្រាក់ អឿន និងប្ដី រួមទាំងកូនៗ៨នាក់ ត្រូវខ្មែរក្រហមសម្លាប់នៅខេត្តពោធិ៍សាត់

សេន ពន្លឺ



ប្រាក់ ឈួន មានអាយុ៧១ឆ្នាំ រស់នៅភូមិស្នាយបុណ្យ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប្រាក់ ឈួន មានអាយុ៧១ឆ្នាំ រស់នៅភូមិស្នាយបុណ្យ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ មុនពេលដែលកងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះ ខ្មែរក្រហមមិនទាន់រៀបចំហូបរួម និងធ្វើការងាររួមនៅក្នុងភូមិខ្ញុំទេ។ លុះបានមួយរយៈក្រោយមក ពេលខ្មែរក្រហមទទួលជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបខ្មែរក្រហមចាប់ផ្ដើមបង្កើតជាសហករណ៍ ហើយប្រជាជនត្រូវហូបរួម និងធ្វើការងាររួមគ្នា។

បន្ទាប់មកទៀត នៅចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានប្រធានកងចល័តប្រើឲ្យជីកប្រឡាយ និងលើកទំនប់ស្ថិតនៅភូមិមេសាង ភូមិទានភ្លឺ ភូមិសាឡុងសាឡី ភូមិក្រាំងចំបក់ ដើម្បីយកទឹកសម្រាប់ធ្វើស្រែមួយឆ្នាំពីរដង ដូចជានៅភូមិសំរោងវត្ត។ ខ្មែរក្រហមឲ្យខ្ញុំក្រោកទៅជីកប្រឡាយតាំងតែពីម៉ោង២ទៀបភ្លឺ។ ដោយសារប្រឡាយមានជម្រៅជ្រៅ ដូច្នេះម៉ោង៩ព្រឹក ខ្ញុំរែកដីឡើងលើខ្នងទំនប់លែងរួច ព្រោះហត់នឿយខ្លាំងពេក។ ចំពោះការងារជីកប្រឡាយ គឺខ្មែរក្រហមបានកំណត់មួយក្រុមមានគ្នា៣០នាក់ ត្រូវជីកប្រឡាយបណ្ដោយ១០ម៉ែត្រ ជម្រៅ១,៥ម៉ែត្រ ក្នុងមួយថ្ងៃឲ្យហើយ។ នៅពេលកំពុងជីកប្រឡាយ ខ្ញុំមានជំងឺរាគធ្ងន់ធ្ងរ ដូច្នេះប្រធានកងបញ្ជូនខ្ញុំឲ្យទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យស្ថិតនៅភូមិប្រមូលដុំ។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានប្រធានក្រុមឲ្យទៅច្រូតស្រូវនៅស្រុករំដួល ខេត្តស្វាយរៀង ដោយខ្ញុំត្រូវធ្វើដំណើរដោយថ្មើរជើង។ នៅពេលខ្ញុំដើរទៅដល់ស្ពានតាហោ ក្នុងក្រុងស្វាយរៀង គឺគ្មានស្ពានដើរឆ្លងកាត់ឡើយ ដូច្នេះប្រធានក្រុមបានឲ្យក្រុមខ្ញុំដើរឆ្លងទឹក។ ទឹកព្រែកពេលនោះមិនសូវជ្រៅប៉ុន្មានទេ គឺត្រឹមទ្រូងខ្ញុំ ហើយខណៈពេលនោះដែរ ក៏ចាប់ផ្ដើមមានសង្គ្រាមជាមួយកងទ័ពវៀតណាមដែរ។ នៅពេលទៅដល់ស្រុករំដួល ខ្មែរក្រហមកំណត់ឲ្យខ្ញុំច្រូតស្រូវក្នុងមួយថ្ងៃឲ្យបាន៣ហិកតា ដោយត្រូវក្រោកទៅច្រូតតាំងតែពីម៉ោង២ទៀបភ្លឺ ចំណែកបាយមួយពេល ខ្មែរក្រហមកំណត់ចែកអង្ករឲ្យ១២០

កំប៉ុង សម្រាប់មនុស្ស១៣០នាក់។ នៅទីនោះសម្លគឺពិបាកហូបដោយសារតែចុងភៅដាក់បន្លែចម្រុះគ្រប់សព្វ។

ពេលខ្លះ ប្រធានកងប្រើខ្ញុំឲ្យទៅទូលកណ្ដាប់ស្រូវពីស្រែដែលនៅឆ្ងាយយកមកទុក ដោយទូលស្រូវម្ដងចំនួនបីកណ្ដាប់ធំ បើគិតជាស្រូវប្រហែលមួយតៅ។ ពេលខ្លះខ្ញុំនឿយហត់ ទូលមិនដល់គោលដៅ ទើបស្រែកឲ្យគេជួយក៏មាន។

បន្ទាប់មក ខ្មែរក្រហមឲ្យខ្ញុំត្រឡប់មកស្រុកមេសាងវិញ ដើម្បីស្ទូងស្រូវមួយថ្ងៃឲ្យអស់សំណាប១ផ្លូន ក្នុងទំហំក្បាលដី៧ម៉ែត្រ និងបណ្ដោយ១០០ម៉ែត្រ។ ខ្ញុំត្រូវក្រោកទៅស្ទូងតាំងតែពីម៉ោង៥ទៀបភ្លឺ។ ក្រោយមកទៀត ខ្ញុំចូលធ្វើការក្នុងកងពិសេស ហើយត្រូវបានខ្មែរក្រហមចល័តឲ្យទៅស្ទូងស្រូវនៅភូមិថ្មី ឃុំជីផុច ប៉ុន្តែនៅទីនោះប្រធានកងមិនបានកំណត់ទំហំដី ឬចំនួនកណ្ដាប់ដើម្បីស្ទូងនោះទេ។

នៅក្នុងរបបខ្មែរក្រហម បងប្អូនខ្ញុំបង្កើតមានចំនួនពីរនាក់ ត្រូវបានខ្មែរក្រហមសម្លាប់នៅខេត្តពោធិ៍សាត់ ក្នុងនោះបងស្រីខ្ញុំទីមួយមានឈ្មោះប្រាក់ អឿន មានកូន៨នាក់រួមទាំងប្ដីរបស់គាត់។ ការដែលអង្គការបញ្ជូនបងទីមួយខ្ញុំទៅនោះ ដោយសារគាត់ទៅចុះឈ្មោះទៅនៅខេត្តពោធិ៍សាត់ ព្រោះគាត់បានស្ដាប់ឮពេលអង្គការហៅទៅប្រជុំថា នៅទីនោះមានត្រាវដាំចុះមើមធំៗ ហើយត្រីក៏សម្បូរទៀត។ ចំណែកបងប្រុសពៅខ្ញុំម្នាក់ទៀតត្រូវអង្គការបញ្ជូនទៅធ្វើទាហាន ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក។ ឆ្នាំដែលខ្មែរក្រហមបញ្ជូនបងប្អូនខ្ញុំទាំងពីរទៅគឺប្រហែលជានៅឆ្នាំ១៩៧៨។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំ និងប្រជាជនក្នុងភូមិត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅអ្នកលឿងរួចបន្តទៅទិសខាងលិច។ ពេលជម្លៀសនោះ គឺមានចោរ ហ្វាយស្រុកឈ្មោះ ជន ជិះសេះដេញខ្ញុំនិងប្រជាជនពីក្រោយ។ ក្រោយពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមកដល់ ខ្ញុំក៏វិលត្រឡប់មករស់នៅផ្ទះនៅឯស្រុកកំណើតវិញ។



វាលស្រែនៅក្នុងស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រាក់ អ៊ី៖ ក្រុមគ្រួសារខ្ញុំប្រគល់មាសប្រាក់ទាំងអស់ឱ្យខ្មែរក្រហមដើម្បីបញ្ជាក់ពីភាពស្មោះត្រង់

**សេន ពន្លឺ**



ប្រាក់ អ៊ី អាយុ៧៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្នាយបុណ្យ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប្រាក់ អ៊ី មានអាយុ៧៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្នាយបុណ្យ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានប្រធានកងចាត់តាំងឲ្យធ្វើការងារជាច្រើនរួមមាន ចុងភៅ, ធ្វើស្រែ, ដាំដំណាំ, ជីកប្រឡាយ, ជាន់រហាត់ទឹក, បុកអង្ករ និងវាស់ទំហំដីឲ្យអ្នកភូមិប្រូតស្រូវជាដើម។

ដំណាក់កាលដំបូងដែលកងទ័ពខ្មែរក្រហមទទួលជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើស្រែរួមគ្នាជាមួយអ្នកភូមិឯទៀត ហើយដាក់ដីស្រែរួមគ្នា ប៉ុន្តែការហូបចុកនៅតាមផ្ទះរៀងៗខ្លួនជាធម្មតា។ មិនបានរយៈពេលប៉ុន្មានផង គឺនៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្ដើមបង្កើតជាសហករណ៍។ ខ្មែរក្រហមចាប់ប្រមូលសម្ភារមានតម្លៃ មាសប្រាក់ ពីអ្នកភូមិទាំងអស់ យកមកដាក់រួម ហើយប្រជាជនទាំងអស់ត្រូវទៅហូបបាយរួមគ្នា។ ប្រជាជនដែលមិនប្រគល់មាសប្រាក់ឲ្យខ្មែរក្រហម គឺត្រូវបានចោទថាមិនស្មោះត្រង់ជាមួយនឹងអង្គការ។ គ្រួសារខ្ញុំមិនហ៊ានលាក់ទុកមាសប្រាក់ទេ គឺបានប្រគល់ឲ្យខ្មែរក្រហមទាំងអស់ដើម្បីបញ្ជាក់ពីភាពស្មោះត្រង់ជាមួយអង្គការ។

បន្ទាប់មក ខ្មែរក្រហមក៏ចាត់តាំងខ្ញុំឲ្យបុកស្រូវមួយថ្ងៃ១៥ធុង ដោយមួយធុងមានទម្ងន់ចំនួន១៥គីឡូក្រាម។ ខ្ញុំត្រូវបុកស្រូវរួចរែងរោយឲ្យស្អាតជូនខ្មែរក្រហម។ ចំណែកនៅរដូវវស្សាខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅដកសំណាបមួយថ្ងៃមួយផ្លូន ហើយក្រោយមកឡើងទៅដល់មួយផ្លូននិងបីដំប។ ខ្ញុំត្រូវក្រោកទៅស្ទូងនៅម៉ោង៤ទៀបភ្លឺរហូតដល់ម៉ោង១១ ឬ១២។ លុះដល់ម៉ោង១រសៀល ប្រធានកងឲ្យខ្ញុំទៅដកសំណាបបន្តរហូតដល់ម៉ោង៥ទើបឈប់។

ក្រោយចប់ការងារដកស្ទូង ខ្ញុំត្រូវបានប្រធានកងចាត់តាំងឲ្យទៅដាំកប្បាសនៅភូមិវាំង ឃុំជីផុច ស្រុកមេសាង គឺនៅត្រង់អធិការស្រុកមេសាងសព្វថ្ងៃ។ ក្នុងមួយថ្ងៃ ខ្ញុំត្រូវដាំ និងស្រោចទឹកកប្បាស៥០គុម្ព ហើយពេលខ្លះប្រធានកងឲ្យខ្ញុំដាំដំណាំនៅភូមិវាំងដែរ។

លុះដល់រដូវប្រូត ប្រធានកងចាត់តាំងឲ្យខ្ញុំដើររាវរាស់ដីស្រែឲ្យអ្នកភូមិប្រូតស្រូវ ហើយខ្ញុំក៏ត្រូវប្រូតស្រូវដូចអ្នកឯទៀតដែរ។ ខ្មែរក្រហមកំណត់ឲ្យកងចល័តម្នាក់ត្រូវប្រូតក្នុងទំហំក្បាលដីទំហំ៧ម៉ែត្រ និងបណ្ដោយ១០០ម៉ែត្រ។ នៅពេលខ្លះទៀត ប្រធានកងចាត់ខ្ញុំឲ្យទៅធ្វើការងារនៅរោងបាយ ដោយក្នុងមួយថ្ងៃត្រូវដាំបាយ៣០ឆ្នាំង សម្រាប់មនុស្ស៣០០នាក់។ នៅក្នុងរោងបាយមួយ មានសមាជិក៣នាក់ ក្នុងនោះមានស្រី២នាក់ និងប្រុសម្នាក់កាប់ខស។

នៅដើមឆ្នាំ១៩៧៨ ខ្ញុំមានបងប្អូនចំនួនពីរនាក់ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅខេត្តពោធិ៍-សាត់។ បងស្រីខ្ញុំឈ្មោះ ប្រាក់ អឿន និង ប្ដី ព្រម ទាំងកូន១២នាក់ ចំណែកប្អូនប្រុសខ្ញុំម្នាក់ទៀត ឈ្មោះ ប្រាក់រី មានប្រពន្ធកំពុងពោះធំ។ បងប្អូនខ្ញុំទាំងពីរគ្រួសារត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលទាំងអស់។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំកើតបានកូនម្នាក់។ ពេលខ្ញុំកើតកូនបានរយៈពេល១៥ថ្ងៃ ប្រធានកងចាត់ខ្ញុំឲ្យទៅដកសំណាប និងស្ទូងស្រូវ។ ខ្ញុំខិតខំធ្វើការគ្រប់តាមផែនការដែលប្រធានកងដាក់ឲ្យរហូត។ ពេលខ្ញុំកំពុងតែធ្វើការ ស្រាប់តែឮសំឡេងស្រែកតៗគ្នាថា ប្រយ័ត្នយួនអារក។ ពេលនោះ ខ្ញុំក៏ប្រញាប់នាំកូននាំប្ដីរត់សំដៅទៅខាងអ្នកលឿង។ ពេលខ្ញុំនិងប្ដីរត់ទៅដល់ជើងភ្នំឈើកាច់ ក៏សំឡឹងឃើញផ្ទុះគ្រាប់បែកនៅអ្នកលឿង ពេលនោះខ្ញុំនិងប្ដីក៏រត់ត្រឡប់មកភូមិរក្សជ័យវិញ។ ខ្ញុំបម្រុងទៅសុំផ្ទះឪពុកមានៅរក្សជ័យស្នាក់នៅបណ្ដោះអាសន្ន ប៉ុន្ដែពេលទៅដល់ទីនោះក៏ឃើញកងទ័ពខ្មែរក្រហមនៅកាន់កាំភ្លើងនៅឡើយ ទើបខ្ញុំគេចចេញមកវិញ។ រំលងបានមួយថ្ងៃ មានឧទ្ទម្ភាគចក្រហោះទាបៗ ហើយប្រកាសតាមមេក្រូប្រាប់បងប្អូនប្រជាជនរស់នៅស្រុកភូមិណា សូមត្រឡប់ទៅស្រុកវិញ ទើបខ្ញុំវិលមករស់នៅស្រុកកំណើតរហូតមក។



ផ្ទះរបស់ ប្រាក់ អ៊ី នៅភូមិស្វាយបុណ្យ ឃុំជីផុចស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សៀង ស៊ីណាត ៖ អតីតកងចល័តលើកទំនប់ត្រួយចេក

*លី វេជវីត*



សៀង ស៊ីណាត អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ (សាំង ចានធូ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សៀង ស៊ីណាត អាយុ៦២ឆ្នាំ កើតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ មៀន និងម្ដាយឈ្មោះ ផុន។ ខ្ញុំគឺជាកូនទី៤ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៥នាក់។ កាលពីក្មេងខ្ញុំមិនបានរៀនសូត្រទេ ដោយសារប្រទេសកើតសង្គ្រាម ។ បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ ទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំឃើញបាតុកម្មប្រឆាំងរដ្ឋប្រហារបានផ្ទុះឡើង និងមានក្បួនបាតុករដង្ហែទៅទីរួមខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ មានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ហើយក្រុមគ្រួសារខ្ញុំបានភៀសខ្លួនទៅរស់នៅ ទួលស្រែ។ បន្ទាប់មក ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរបន្តទៅរស់នៅភូមិវិហារធំបានរយៈពេលកន្លះឆ្នាំ។

នៅឆ្នាំ១៩៧២ ខ្ញុំនិងគ្រួសារបានវិលត្រឡប់មកស្រុកកំណើតវិញ ដែលពេលនោះគ្រប់គ្រងដោយកងទ័ពរំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាមត្រូវបានឡោមព័ទ្ធដោយកងទ័ពរំដោះខ្មែរក្រហមគឺមានតែផ្លូវទឹកប៉ុណ្ណោះដែលជាផ្លូវអាចចូលមកដល់ទីរួមខេត្តកំពង់ចាម។ នៅពេលទាហានម៉ារីន លន់ នល់ បើកនាវាដឹកស្បៀង និងសម្ភារ

សឹកផ្សេងៗពីទីក្រុងភ្នំពេញទៅ ទីរួមខេត្តកំពង់ចាម តែងតែទទួលរងការវាយប្រហារពីកងទ័ពរំដោះខ្មែរក្រហមពីត្រើយម្ខាងៗនៃទន្លេមេគង្គ។ នៅពេលឮសំឡេងម៉ារីនបើកមកម្តងៗ ខ្ញុំត្រូវរត់ចូលរណ្តៅត្រង់សេដើម្បីលាក់ខ្លួន ពីព្រោះមានការប្រយុទ្ធគ្នារវាងទាហានម៉ារីន និងកងទ័ពរំដោះខ្មែរក្រហមខ្លាំងក្លាណាស់។

នៅពាក់កណ្តាលឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមវាយរំដោះបានពាក់កណ្តាលនៃទីរួមខេត្តកំពង់ចាម និងនៅបន្តប្រយុទ្ធជាមួយទាហាន លន់ នល់ ដែលនៅសេសសល់។ បន្ទាប់មកទៀតនៅឆ្នាំ១៩៧៥ ខ្ញុំចូលធ្វើការក្នុងកងសាមគ្គី ដើម្បីជួយប្រូតស្រូវ និងប្រមូលផលដំណាំផ្សេងៗចែកគ្នាហូប។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមបង្កើតជាសហករណ៍ និងបែងចែកប្រជាជនឲ្យធ្វើការនៅកងចល័តនៅតាមការដ្ឋាននានា។ ខ្ញុំត្រូវងើបពីម៉ោង៤ទៀបភ្លឺទៅប្រជុំជួរ និងដើរទៅកន្លែងធ្វើការដោយមានការដឹកនាំពីមេកងឈ្មោះ នាង។ ខ្ញុំចាប់ផ្តើមធ្វើការពីម៉ោង៦ព្រឹកដល់ម៉ោង១១ ទើបឈប់សម្រាកហូបបបរនៅរោងបាយរួម រួចហើយខ្ញុំត្រូវបន្តធ្វើការចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាចៗ ការហូបចុកមិនគ្រប់គ្រាន់ទេហើយការស្លៀកពាក់ខ្មែរក្រហមចែកខោអាវឲ្យម្នាក់១មួយសម្រាប់ក្នុងមួយឆ្នាំ។ នៅពេលដែលសើមទទឹកខោអាវ ខ្ញុំមិនមានអ្វីផ្លាស់ទេ គឺដេកទាំងសើមរហូតដល់ស្ងួតៗ

ខ្ញុំទៅលើកទំនប់ព្រែកសង្កែបានរយៈពេល៦ខែ ហើយនៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានផ្លាស់មកធ្វើការនៅកងចល័តនារីដកស្ទូងដឹកប្រឡាយ និងលើកទំនប់ត្រយចេក។ នៅរដូវប្រូតកាត់ ខ្ញុំត្រូវងើបពីម៉ោង៣ទៀបភ្លឺដើម្បីដើរឲ្យដល់កន្លែងប្រូត ដោយមានគ្នាចំនួន២៥នាក់ ប្រូតស្រូវ២ហិកតា។ ខ្ញុំចាប់ផ្តើមប្រូតរហូតដល់ម៉ោង១១ព្រឹក ទើបឈប់សម្រាកហូបបបរ។ ខ្ញុំបន្តធ្វើការទៀតនៅម៉ោង១២ថ្ងៃត្រង់ រហូតដល់ម៉ោង៥ល្ងាចៗ ប្រសិនបើខ្ញុំប្រូតស្រូវមិនហើយ ខ្ញុំត្រូវធ្វើការដល់ម៉ោង៩យប់ ទាល់តែរួចរាល់ទើបបានឈប់សម្រាក។ នៅពេលប្រូតស្រូវរួច ខ្ញុំត្រូវបងកណ្តាប់ស្រូវជាមួយកងចល័ត។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានផ្លាស់មកធ្វើការងារលើកទំនប់នៅភូមិគគរក្នុង១ថ្ងៃ ២ម៉ែត្រគុបៗ រហូតដល់ឆ្នាំ១៩៧៩ ខ្ញុំបានឮស្នូរកាំភ្លើងបាញ់គ្នាល្មើយៗ និងបាញ់ផ្សេងដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលចូលមករំដោះប្រជាជនចេញពីការកាប់សម្លាប់របស់ខ្មែរក្រហម។ ខ្ញុំបានរួចផុតពីសេចក្តីស្លាប់នៅពេលនោះ និងមករស់នៅភូមិកំណើតជាមួយគ្រួសារវិញ។



ទិដ្ឋភាពភូមិចំការសាមសិប ថតពីលើអាកាស ។
( សាំង ចាន់ធូ / មជ្ឈមណ្ឌលឯកសារកម្ពុជា )

# សៀង ហេន ៖ អតីតកងចល័តនារីវ័យកណ្តាល

**សាំង ចាន់ធូ**



*សៀង ហេន អាយុ៧៧ឆ្នាំ សព្វថ្ងៃរស់នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។។*
*(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ សៀង ហេន អាយុ៧៧ឆ្នាំ រស់នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅឆ្នាំ១៩៦៨ ខ្ញុំរៀបការប្តីឈ្មោះ លីវ ង៉ុយ និងមានកូនប្រុសស្រីចំនួន២នាក់ ហើយខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំមានឪពុកឈ្មោះ មាន និងម្តាយឈ្មោះ ជុន។ ខ្ញុំគឺជាកូនទី២ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៥នាក់។

នៅពីក្មេងខ្ញុំចូលរៀននៅសាលាបឋមសិក្សាគគរ។ ខ្ញុំរៀនបន្តរហូតបានដល់ថ្នាក់ទី៥សង្គមចាស់។ បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ខ្ញុំឃើញបាតុកម្មប្រឆាំងរដ្ឋប្រហារបានផ្ទុះឡើង និងមានក្បួនបាតុករដង្ហែទៅ ទីរួមខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ មានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ពេលនោះក្រុមគ្រួសារខ្ញុំបានភៀសខ្លួនទៅរស់នៅទួលស្រែ។ បន្ទាប់មក ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរបន្តទៅរស់នៅភូមិវិហារធំបានរយៈពេលកន្លះឆ្នាំ។

នៅឆ្នាំ១៩៧២ ខ្ញុំបានវិលត្រឡប់មកស្រុកកំណើតដែលគ្រប់គ្រងដោយកងទ័ពរំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាមត្រូវបានឡោមព័ទ្ធដោយកងទ័ពរំដោះខ្មែរក្រហមគឺមានតែផ្លូវទឹកប៉ុណ្ណោះដែលជាផ្លូវអាចចូលមកដល់ទីរួមខេត្តកំពង់ចាម។ នៅពេលទាហានម៉ារីន លន់ នល់ បើកនាវាដឹកស្បៀង និងសម្ភារសឹកផ្សេងៗពីទីក្រុងភ្នំពេញទៅ ទីរួមខេត្តកំពង់ចាមជា

រឿយៗ ទទួលរងការវាយប្រហារពីកងទ័ពរំដោះខ្មែរក្រហម ពីត្រើយម្ខាងនៃទន្លេមេគង្គ។ ដូច្នេះនៅពេលឮសំឡេងម៉ារីនបើកមក ខ្ញុំត្រូវរត់ចូលលាក់ខ្លួនក្នុងរណ្ដៅត្រង់សេ ពីព្រោះមានការប្រយុទ្ធគ្នារវាងទាហានម៉ារីន និងកងទ័ពរំដោះខ្មែរក្រហមយ៉ាងខ្លាំងក្លា។

នៅពាក់កណ្ដាលឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមវាយរំដោះបានពាក់កណ្ដាលនៃទីរួមខេត្តកំពង់ចាម និងបន្តប្រយុទ្ធជាមួយទាហាន លន់ នល់ ដែលនៅសេសសល់នៅក្នុងក្រុងកំពង់ចាម។

នៅឆ្នាំ១៩៧៥ ខ្ញុំចូលធ្វើការក្នុងកងសាមគ្គី ដើម្បីជួយច្រូតស្រូវ និងប្រមូលផលដំណាំផ្សេងៗមកចែកគ្នាហូប។ នៅឆ្នាំ១៩៧៦ គឺជាចាប់ផ្ដើមបង្កើតជាសហករណ៍ និងចូលធ្វើការងារក្នុងកងចល័តនៅតាមការដ្ឋាន។ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការងារបុកស្រូវអង្ករ ដោយសារខ្ញុំមានកូនខ្ចី។ ខ្ញុំត្រូវងើបពីម៉ោង៤ទៀបភ្លឺទៅប្រជុំជួរ និងស្ដាប់អំពីផែនការរបស់អង្គការដាក់ឲ្យខ្ញុំធ្វើប្រចាំថ្ងៃ។ ខ្ញុំចាប់ផ្ដើមធ្វើការពីម៉ោង៦ព្រឹកដល់ម៉ោង១១ ទើបឈប់សម្រាកហូបបបរនៅរោងបាយរួម រួចហើយខ្ញុំត្រូវបន្តធ្វើការងារចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច។ ខ្ញុំទៅលើកទំនប់ព្រែកសង្កែបានរយៈពេល៦ខែ បន្ទាប់មកខ្ញុំត្រូវបានបញ្ជូនទៅធ្វើចុងភៅតាមសហករណ៍។

នៅឆ្នាំ១៩៧៧ ខ្ញុំបានផ្លាស់មកធ្វើការនៅកងវ័យកណ្ដាលនៅមូលដ្ឋាន និងដកស្ទូងនៅទួលស្រែ។ នៅពេលច្រូតកាត់ ខ្ញុំត្រូវងើបពីម៉ោង៣ទៀបភ្លឺដើម្បីដើរទៅដល់កន្លែងច្រូតដោយមានគ្នាចំនួន១០នាក់ច្រូតស្រូវក្នុង១ហិកតា។ យើងចាប់ផ្ដើមច្រូតដល់ម៉ោង១១ព្រឹកទើបឈប់សម្រាកហូបបបរ។ ខ្ញុំបន្តច្រូតនៅម៉ោង១២រហូតដល់ម៉ោង៥ល្ងាច បើយើងច្រូតស្រូវមិនហើយ យើងត្រូវច្រូតបន្តដល់ម៉ោង៩យប់ ទាល់តែរួចរាល់ទើបបានឈប់សម្រាក។ នៅពេលច្រូតរួច ខ្ញុំត្រូវចងកណ្ដាប់ស្រូវជាមួយកងចល័ត។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការងារលើកទំនប់នៅភូមិគគរក្នុង១ថ្ងៃ២ម៉ែត្រគុប។ រហូតដល់ឆ្នាំ១៩៧៩ ខ្ញុំបានឮស្នូរកាំភ្លើងបាញ់គ្នាល្មើយៗ និងឃើញបាញ់ផ្សែងដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលចូលមករំដោះប្រជាជនចេញពីការកាប់សម្លាប់របស់ខ្មែរក្រហម។ ខ្ញុំបានរួចផុតពីសេចក្ដីស្លាប់នៅពេលនោះហើយមករស់នៅភូមិកំណើតជាមួយគ្រួសារវិញ។



ទិដ្ឋភាពស្រុកកំពង់សៀមថតពីលើអាកាស។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# កង សេង ៖ កងកុមាររបស់អង្គការ

ផាន សម្ភស្ស



កង សេង អាយុ៦១ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិក្រពើពីរក្រោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ កង សេង ភេទស្រី អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅភូមិព្រៃឈើទាល ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិក្រពើពីរក្រោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ កង ពៅ និង ម្ដាយឈ្មោះ ឆែម។ ខ្ញុំមានបងប្អូនចំនួន៥នាក់ ក្នុងនោះប្រុស២នាក់ និងស្រី៣នាក់។ ខ្ញុំគឺជាកូនទី៤នៅក្នុងគ្រួសារ។ ខ្ញុំបានរៀបការប្ដីឈ្មោះ ឆាយ ម៉ៅ ព្រមទាំងមានកូនចំនួន៥នាក់ គឺប្រុស២នាក់ និង ស្រី៣នាក់ ក្នុងនេះមានកូនប្រុសម្នាក់បានស្លាប់។

កាលនៅកុមារ ខ្ញុំចូលរៀនបានតិចតួច ហើយក្រោយមកក៏ឈប់រៀនដើម្បីទៅស៊ីឈ្នួលធ្វើស្រែចម្ការឲ្យគេ ព្រោះគ្រួសារខ្ញុំមានជីវភាពក្រីក្រពេក។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ។ ក្រោយមក ស្រាប់តែមានការទម្លាក់គ្រាប់បែកមកលើកងទ័ពខ្មែររំដោះនៅក្នុងភូមិ ដែលទាមទារឲ្យសម្ដេចព្រះ នរោត្តម សីហនុ យាងមកគ្រប់គ្រងប្រទេសវិញ។ ពេលឮសូរសំឡេងយន្តហោះមកម្ដងៗ ម្ដាយរបស់ខ្ញុំនាំកូនៗរត់ទៅលាក់ខ្លួនក្នុងត្រង់សេដើម្បីគេចពីគ្រាប់បែក។

នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់។ របបថ្មីដែលប្រជាជនគ្រប់គ្នាហៅថា អង្គការក៏កើតឡើងដែរ។ ខ្ញុំត្រូវបានអង្គការចាត់ចូលឲ្យធ្វើជាកងកុមារក្នុងភូមិលើ ជិតព្រំដែនវៀតណាម។ នៅក្នុងកងកុមារដែលខ្ញុំរស់នៅមានកុមារប្រមាណជិត១០០នាក់។ អង្គការឲ្យខ្ញុំធ្វើការងារដេញចាប រែកអាចម៍គោដាក់ក្នុងស្រែ កាប់ដើមទន្ទ្រានខែត្រ និងកាប់ដីដំបូក។ ចំណែករបបអាហារអង្គការឲ្យហូបតែបបរ មិនដែលឲ្យហូបបាយឡើយ។ មានថ្ងៃមួយអង្គការចាត់តាំងម្ដាយរបស់ខ្ញុំឲ្យទៅរស់នៅព្រៃផ្កា ដោយអង្គការបាននិយាយថា «ធ្វើនំបញ្ចុកជប់លៀងថ្ងៃទី៣០នៅក្នុងព្រៃផ្កា» តែមិនទាន់ដល់ថ្ងៃទី៣០ផង ពេលខ្ញុំកំពុងដេញចាប ស្រាប់តែមានគ្រាប់ផ្លោងហោះលើក្បាល ទៅធ្លាក់ក្នុងព្រៃផ្កា គឺជាកន្លែងដែលអង្គការជម្លៀសម្ដាយរបស់ខ្ញុំទៅ។ ខ្ញុំនិងកងកុមារទាំងអស់បាននាំគ្នារត់ទៅរកម្ដាយ។ ពេលខ្ញុំរត់ទៅ

ដល់ព្រៃផ្កា ឃើញមានសាកសពមនុស្សស្លាប់ពាសពេញដី ហើយបន្តិចក្រោយមកខ្ញុំក៏បានជួបម្តាយរបស់ខ្ញុំវិញ។ ម្តាយរបស់ខ្ញុំក៏បាននាំខ្ញុំរត់ចេញពីព្រៃផ្កាឡើងមកលើវិញជាមួយប្រជាជនជាច្រើននាក់ទៀត។

ពេលធ្វើដំណើរតាមផ្លូវ ម្តាយរបស់ខ្ញុំបានលួចយកស្រូវដាក់លើរទេះទុកធ្វើស្បៀង។ នៅពេលយើងទៅដល់កន្លែងស្នាក់ ម្តាយរបស់ខ្ញុំក៏ជីករណ្តៅតូចមួយហើយយកស្រូវមកដាក់ក្នុងកន្ត្រង រួចហើយរុំដើម្បីបុកវែងយកអង្ករដាំបាយហូប។ គ្រួសាររបស់ខ្ញុំដេកនៅតាមផ្លូវអស់ជាច្រើនថ្ងៃ ចំណែកខ្ញុំនៅតូចដេកមិនបានប្រយ័ត្នក៏ត្រូវគោជាន់ចំជើង។ ជើងរបស់ខ្ញុំហើមដើរមិនរួចអស់មួយរយៈ។ បន្ទាប់មកគ្រួសារខ្ញុំធ្វើដំណើរបន្តទៅមុខរហូតដល់កោះធ្លៅ ក្នុងខេត្តកំពង់ស្ពឺ។ ខ្ញុំរស់នៅកោះធ្លៅប្រហែលជា២ខែ ម្តាយរបស់ខ្ញុំក៏សម្រេចចិត្តធ្វើដំណើរចុះមកក្រោមវិញដើម្បីងាយស្រួលត្រឡប់ទៅស្រុកកំណើត។

ក្រោយមក កងទ័ពវៀតណាមចូលរំដោះប្រជាជនកម្ពុជាចេញពីរបបខ្មែរក្រហម ទើបឪពុកម្តាយរបស់ខ្ញុំបាននាំខ្ញុំត្រឡប់មកស្រុកកំណើតនៅខេត្តតាកែវវិញ។ ពេលខ្ញុំមកដល់ស្រុកកំណើតដំបូង គឺគ្មានមនុស្សរស់នៅឡើយ។ នៅក្នុងភូមិមានសភាពស្ងាត់ជ្រងំ ហើយខ្ញុំនិងឪពុកម្តាយក៏ប្រកបរបរធ្វើស្រែចម្ការរហូតមក។



កង សេង ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ដល់ ចាន់ ណារិទ្ធ អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឆាយ ម៉ៅ ៖ អតីតកងទ័ពការពារព្រំដែនស្រុកគិរីវង្សនៅក្នុងរបបខ្មែរក្រហម

ធី គឹមហុង



រូបខាងស្ដាំ ៖ ឆាយ ម៉ៅ អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ដល់ ធី គឹមហុង បុគ្គលិកមជ្ឈមណ្ឌលដង្រះដង្រាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឆាយ ម៉ៅ អាយុ៦៥ឆ្នាំ មានស្រុកកំណើតនៅភូមិព្រៃឈើទាល ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ប៉ែន មុំ រីឯម្ដាយ ខ្ញុំមិនបានចាំឈ្មោះគាត់ឡើយ។ ខ្ញុំមានបងប្អូនចំនួន៨នាក់ ក្នុងនោះស្រីចំនួន៤នាក់ និងប្រុសចំនួន៤នាក់ ហើយខ្ញុំជាកូនទី២ក្នុងគ្រួសារ។ ខ្ញុំរៀបការប្រពន្ធឈ្មោះ កង សេង និងមានកូនចំនួន៥នាក់ ក្នុងនោះប្រុស២នាក់ និង ស្រី៣នាក់។

នៅឆ្នាំ១៩៦៩ ឪពុកម្ដាយរបស់ខ្ញុំបានដាក់ឲ្យខ្ញុំចូលរៀននៅសាលាវត្តឈើនាងផ្អែម ប៉ុន្តែខ្ញុំរៀនបានត្រឹមថ្នាក់ទី១២ចាស់ប៉ុណ្ណោះ។ គ្រូដែលបង្រៀនខ្ញុំមានឈ្មោះ ឌឹម ហើយជំនាន់នោះសិស្សរៀនជាមួយខ្ញុំមានប្រហែលជា៣០នាក់។ ខ្ញុំរៀនបានមួយឆ្នាំស្រាប់តែ

ស្រុកទេសមានសង្គ្រាម ខ្ញុំក៏ឈប់រៀន។ ក្រោយពីឈប់រៀន ទើបខ្ញុំដឹងដំណឹងថា លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែង។ វគ្គមានទាហានលន់នល់ក៏ចាប់ផ្តើមចូលក្នុងភូមិ។ ចំណែកអ្នកភូមិដែលគោរពស្រឡាញ់សម្តេចព្រះ នរោត្តម សីហនុ ក៏ចូលរួមជាមួយកងទ័ពរំដោះខ្មែរក្រហម។ ខ្ញុំនិងអ្នកភូមិបាននាំគ្នារត់ចូលខាងសម្តេចតា ប៉ុន្តែទាហានរបស់ លន់ នល់ បានយកកាំភ្លើងបាញ់ឡើងទៅលើ រួចគម្រាមថា «បើមិនចូលខាង លន់ នល់ ទេនឹងបាញ់សម្លាប់ចោល» ពេលឮបែបនេះប្រជាជនក៏ព្រមចុះចូលខាងទាហាន លន់នល់ ទាំងអស់គ្នា។ បន្ទាប់ពីចូលខាង លន់ នល់ ហើយ ទើបប្រជាជនអាចនៅធ្វើស្រែចម្ការបានធម្មតា។

នៅឆ្នាំ១៩៧១ ស្រាប់តែមានការទម្លាក់គ្រាប់បែកតាមយន្តហោះ។ តាមផ្ទះនីមួយៗប្រជាជនត្រូវជីកត្រង់សេលាក់ខ្លួនព្រោះខ្លាចគ្រាប់បែកធ្លាក់ចំ។ ត្រង់សេដែលខ្ញុំបានជីក មានទទឹង១ម៉ែត្រ ជម្រៅ២ទៅ៣ម៉ែត្រ ចំណែកម្ហូបអាហារគឺម្តាយរបស់ខ្ញុំបានត្រៀមទុករាល់ថ្ងៃ។ បងប្អូនឪពុកម្តាយខ្ញុំគ្រាន់តែឮយន្តហោះ គឺនាំគ្នារត់ចូលលាក់ខ្លួនក្នុងត្រង់សេ។

នៅឆ្នាំ១៩៧២ គ្រួសាររបស់ខ្ញុំ និងប្រជាជនក្នុងភូមិទាំងអស់បានភៀសខ្លួនទៅរស់នៅខេត្តកំពត។ ការភៀសខ្លួនមកខាងខេត្តកំពត ដោយសារស្រុកភូមិរបស់ខ្ញុំមានការទម្លាក់គ្រាប់បែកខ្លាំងក្លាពេកទើបប្រជាជនសម្រេចចិត្តចាកចេញពីផ្ទះសម្បែង។ ពេលមកដល់ខេត្តកំពតគ្រួសារខ្ញុំនិងប្រជាជនឯទៀតមិនមានផ្ទះសម្បែងរស់នៅទេ គ្រួសារខ្លះមានតង់កៅស៊ូសម្រាប់បាំងថ្ងៃនិងភ្លៀង ខ្លះប្រក់ស្បូវ ខ្លះទៀតសុំផ្ទះអ្នកស្រុករស់នៅបណ្តោះអាសន្ន។ អ្នកភូមិខ្ញុំដែលមានជំនាញសិប្បកម្មផ្នែកបត្តី ឈ្នាង ទ្រូតុ កៅអីបាននាំគ្នាធ្វើសម្ភារទាំងនេះប្តូរជាអង្ករ ម្ហូបអាហារ ពីអ្នកក្នុងខេត្តកំពត ដើម្បីជីវភាពប្រចាំថ្ងៃ។

នៅឆ្នាំ១៩៧៣ គ្រួសារខ្ញុំត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរស់នៅក្នុងខេត្តកំពត ប្រហែលជាមួយឆ្នាំ ប៉ុន្តែជាអកុសលឪពុកម្តាយរបស់ខ្ញុំមានជំងឺ ហើយស្លាប់ទាំងពីរនាក់។ ក្រោយពីឪពុកម្តាយខ្ញុំស្លាប់ទៅ ខ្ញុំនៅជុំជាមួយបងប្អូនខ្ញុំបីនាក់ ចំណែក៥នាក់ទៀតមិនដឹងបាត់ទៅណារហូតមកដល់សព្វថ្ងៃ។

បន្ទាប់មក នៅឆ្នាំ១៩៧៤ ខ្ញុំសម្រេចចិត្តចូលធ្វើជាកងទ័ពរំដោះ ឬហៅថាកងទ័ពស្រុក។ ខ្ញុំស្ម័គ្រចិត្តចូលដោយខ្លួនឯង និងមានមេកងឈ្មោះ ភុន។ ភុនគ្រប់គ្រងកងទ័ពប្រហែលជាជាង៣០នាក់។ កាលនោះខ្ញុំនៅក្មេងមិនសូវមានការយល់ដឹងទេ ដូច្នេះបងៗបង្រៀនខ្ញុំពីរបៀបដោះគ្រាប់កាំភ្លើង និងឲ្យខ្ញុំរៀនប្រើកាំភ្លើង។ ខ្ញុំនៅក្នុងអង្គភាពទ័ពបានរយៈពេល១ខែ មេកងឈ្មោះ ភុនបានបញ្ជូនខ្ញុំឲ្យទៅខាងកងពល នៅតំបន់១៣ ដែលមានមេកងពលឈ្មោះ លឿន។ លឿនបានបញ្ជូនខ្ញុំទៅវាយជាមួយទាហាន លន់ នល់ នៅខាងខេត្តតាកែវ ហើយក៏ទទួលបានជ័យជម្នះ។ ខ្ញុំបានឃើញកងទ័ពរំដោះខ្មែរក្រហមចងដៃទាហាន លន់ នល់ ជាជួរៗប៉ុន្តែមិនដឹងយកទៅណាឡើយ ហើយក៏មិនឃើញទាហាន លន់ នល់ ទាំងនោះវិលត្រឡប់មកវិញដែរ។

នៅឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ ពេលនោះខ្ញុំឈរជើងនៅក្នុងទីរួមខេត្តតាកែវ។ រហូតដល់ដើមឆ្នាំ១៩៧៦ អង្គការចាត់តាំងកងពលរបស់ខ្ញុំឲ្យចុះមកធ្វើស្រូវប្រាំង ប៉ុន្តែមិនទាន់បានប្រមូលផលផងមេកងពលក៏បញ្ជូនក្រុមខ្ញុំឲ្យទៅការពារតាមព្រំដែនវៀតណាម ស្ថិតក្នុងស្រុកគិរីវង្ស ខេត្តតាកែវ។ មេកងថ្មីរបស់ខ្ញុំនៅព្រំដែនវៀតណាមមានឈ្មោះ វឿន។ ខ្ញុំត្រូវរស់នៅការពារព្រំដែនរយៈពេលបីឆ្នាំ ដោយបើករបបអាហារ៣លើកក្នុងមួយខែ។

នៅចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមករំដោះប្រទេសកម្ពុជា ពេលនោះខ្ញុំរត់កាត់តាមព្រៃរហូតដល់ទំនប់សាន្ត ខេត្តតាកែវ។ ខ្ញុំបន្តដំណើរទៅស្ទឹងភេ ខេត្តកំពត រួចមកនៅខេត្តកំពង់ស្ពឺវិញ។ ការរត់គេចពីទាហានវៀតណាមរយៈ

ពេលយូរ ធ្វើឲ្យអស់កម្លាំង និងអត់អាហារ។ ដោយសារឃ្លានខ្លាំងពេក ខ្ញុំក៏លួចចូលភូមិដកដំឡូងហូប ប៉ុន្តែត្រូវទាហានវៀតណាមចាប់ខ្លួនបាន។ ទាហានវៀតណាមមិនបានធ្វើបាបខ្ញុំទេ គ្រាន់តែសួរពីប្រវត្តិរូប? មកពីណា? ធ្វើការអ្វីដែរ? បន្ទាប់មកក៏ឲ្យខ្ញុំត្រឡប់មកស្រុកកំណើតវិញ។

នៅឆ្នាំ១៩៨២ ខ្ញុំចូលធ្វើជាទាហានរបស់សម្ដេច ហ៊ុន សែន ប្រចាំខាងព្រៃសណ្ដែក ដែលមានមេកងឈ្មោះ គល់ ស៊ីម គឺជាប្រធានកងទ័ពស្រុក។ ខ្ញុំទទួលប្រាក់ខែចំនួន៥៩រៀលក្នុងមួយខែ។ នៅឆ្នាំ១៩៨៥ ខ្ញុំប្តូរទៅនៅខាងកងពលលេខ៨ ស្ថិតនៅភូមិអង្គ ខេត្តកំពត ដោយមានមេកងលេខ៨ឈ្មោះ ប៊ុល សារឿន។ បន្ទាប់មក ខ្ញុំផ្លាស់មកនៅខាងណាមសាប ខេត្តបន្ទាយមានជ័យ។ កាលនោះការធ្វើដំណើររបស់ខ្ញុំគឺតាមរថយន្តម៉ាកស៊ីល។ ខ្ញុំឈរជើងនៅណាមសាបរយៈពេល២ឆ្នាំ ស្រាប់តែមានជំងឺគ្រុនចាញ់ក៏ឡើងមកព្យាបាលនៅខេត្តបាត់ដំបង ប្រហែលជានៅឆ្នាំ១៩៨៧។ បន្ទាប់ពីជាពីជំងឺគ្រុនចាញ់ ខ្ញុំក៏ត្រឡប់មកស្រុកកំណើតធ្វើស្រែចម្ការវិញ។

រហូតមកដល់ឆ្នាំ១៩៩០ ខ្ញុំចេញទៅធ្វើកម្មករនៅខេត្តស៊ីសុផន ប្រទេសថៃ ហើយក៏បន្តទៅនៅជំរំទី៨ អូរតាង៉ុក។ ខ្ញុំចេញពីជំរំ អូតាង៉ុក ក៏ត្រឡប់មកស្រុកកំណើតធ្វើស្រែចម្ការ។ នៅឆ្នាំ១៩៩៧ ខ្ញុំឡើងមកនៅជំរំអូរល្ហុងបានរយៈពេលមួយឆ្នាំ ហើយចេញពីជំរំអូរល្ហុង ទើបខ្ញុំមករស់នៅឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ និងធ្វើជាប៉ូលិសបានរយៈពេល១០ឆ្នាំ។



ទេសភាពនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្នុងរដូវវស្សា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឆែម គិះ ៖ កុមារអង្គការ

**មេក ទិន**



ឆែម គិះ អាយុ៥៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឆែម គិះ ភេទស្រី អាយុ៥៩ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិរំដេង ឃុំខ្នារពោធិ៍ ស្រុកសូត្រនិគម ខេត្តសៀមរាប។ សព្វថ្ងៃខ្ញុំរស់នៅក្នុងភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខ្ញុំមានបងប្អូនចំនួន៥នាក់ ហើយខ្ញុំគឺជាកូនពៅក្នុងគ្រួសារ។ កាលពីកុមារភាពខ្ញុំមិនបានចូលរៀនសូត្រទេ ព្រោះគ្រួសារខ្ញុំមានជីវភាពខ្វះខាត ណាមួយប្រទេសកំពុងស្ថិតក្រោមការទម្លាក់គ្រាប់បែក ការប្រយុទ្ធគ្នារវាងកងទ័ពរំដោះខ្មែរក្រហម និងទាហានរបបសាធារណរដ្ឋខ្មែរ លន់ នល់។

នៅក្នុងរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំត្រូវបានបំបែកចេញពីគ្នាដោយឪពុកម្ដាយរបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅតាមកងចល័ត ឯបងៗត្រូវបានអង្គការចាត់តាំង ឲ្យទៅធ្វើការនៅកន្លែងផ្សេង ចំណែកខ្ញុំមានអាយុ១០ឆ្នាំអង្គការយកមកដាក់ក្នុងកងកុមារតែម្នាក់ឯង។ ពេលរស់នៅក្នុងកងកុមារ ខ្ញុំតែងតែយំនឹកម្ដាយឪពុក។ កុមារអង្គការដូចខ្ញុំត្រូវធ្វើការងារ កាប់ទន្ទ្រានខែត្រយកទៅធ្វើជីដាក់បន្លែ និងដាក់ស្រូវ។ បងជីដូនមួយរបស់ខ្ញុំ គឺជាប្រធានកងកុមារ ប៉ុន្តែគាត់កាចណាស់។ ពេលខ្ញុំសុំគាត់ទៅលេងផ្ទះម្ដងៗគាត់តែងតែស្តីឲ្យខ្ញុំ និងប្រាប់ខ្ញុំមិនឲ្យនៅយូរទេ ឲ្យខ្ញុំប្រញាប់មកធ្វើការវិញ។

ចំពោះរបបអាហារក្នុងសម័យខ្មែរក្រហម ខ្ញុំហូបមិនបានគ្រប់គ្រាន់ទេ ព្រោះមានតែបបររាវៗមួយកូនចានរកគ្រាប់អង្ករមិនឃើញសោះ។ ទោះបីជាហូបមិនឆ្អែតក៏ខ្ញុំមិនហ៊ានសុំបងជីដូនមួយ ខ្ញុំថែមដែរ ព្រោះគាត់កាច ហើយអង្គការតម្រូវឲ្យយើងហូបស្មើៗគ្នាទាំងអស់។ ខ្ញុំនិងកុមារទាំងអស់ ត្រូវបានអង្គការដាក់ឲ្យដេកជាមួយគ្នា ទាំងស្រី ទាំងប្រុសមិនប្រកាន់គ្នាឡើយ។ ក្រៅពីការងារកាប់ដើមទន្ទ្រានខែត្រ អង្គការបញ្ជូនកងកុមារនិងខ្ញុំឲ្យទៅលើកទំនប់ ជីកប្រឡាយនៅតំបន់ស្រែពោធិ៍។ ពេលទៅដល់ទីតាំងស្រែពោធិ៍ អង្គការចែកកងកុមាររបស់ខ្ញុំជាក្រុមៗ ដែលក្នុងមួយក្រុមមានកុមារចំនួន១០នាក់។ ក្នុងមួយក្រុម គឺអង្គការចែកឲ្យធ្វើយ៉ាងម៉េចមួយថ្ងៃរែកដីឲ្យបាន ៥ម៉ែត្រគុបឲ្យរួចរាល់ទើបបានសម្រាក។ ក្រុមខ្ញុំក្មេងៗ រូបរាងតូចៗ លើកដងដួលផងដោយសារតែភក់ច្រើន ស្ថិតដើរមិនរួច ចំណែកកុមារខ្លះទៀតក៏អស់កម្លាំងដួល

សន្ទប់ក្នុងពេលធ្វើការក៏មានដែរ។ ក្រោយពីលើកទំនប់ដីកប្រឡាយហើយ ខ្ញុំរួមទាំងក្មេងៗដទៃទៀតនាំគ្នាប្រមូលស្រូវ ដកស្ទូង ដាំដំឡូង ជាដើម។ ខ្ញុំត្រូវធ្វើការរហូតដល់កងទ័ពវៀតណាមចូលមករំដោះប្រទេស ទើបខ្ញុំរត់ទៅនៅជុំជាមួយគ្រួសារនៅផ្ទះវិញ។

នៅក្នុងឆ្នាំ១៩៩១ បងប្រុសរបស់ខ្ញុំដែលរស់នៅអន្លង់វែងបានវិលត្រឡប់មកលេងស្រុកកំណើត។ ពេលគាត់ត្រឡប់មកអន្លង់វែងវិញក៏នាំខ្ញុំមកនៅជាមួយគាត់។ ខ្ញុំមកដល់ដំបូងនៅទីនេះមានព្រៃក្រាស់ៗ ដើមឈើធំៗណាស់ ចំណែកការធ្វើដំណើរទៅមកគឺដោយថ្មើរជើងមិនទាន់មានផ្លូវធំៗសម្រាប់រថយន្តបើកបរនោះទេ។ បងប្រុសរបស់ខ្ញុំបានឲ្យខ្ញុំទៅរស់នៅជំរំលើភ្នំ។ ពេលនោះ ខ្ញុំបានលួចគេចចេញពីជំរំ និងតម្រួតថៃ ដើម្បីបានទៅធ្វើការងារស៊ីឈ្នួលឲ្យជនជាតិថៃ ដែលត្រូវការកម្លាំងទៅប្រមូលកាត់ ឬដកដំឡូង។ ខ្ញុំរស់នៅក្នុងជំរំលើភ្នំដងរែកបានមួយរយៈតាម៉ុក ក៏បានប្រកាសឲ្យប្រជាជនចុះមករស់នៅខាងក្រោមវិញ។ ពេលចុះពីភ្នំដំបូងៗ បងប្រុសខ្ញុំឲ្យខ្ញុំទៅនៅជាមួយបងស្រីខ្ញុំឈ្មោះ ឆែម ឡៃ។ ក្រោយមក ខ្ញុំក៏មានគ្រួសារទើបបែកចេញពីបងស្រី ហើយមកនៅលើដីដែលប្រធានភូមិចែកឲ្យរហូតមកដល់សព្វថ្ងៃនេះ។



ប្ដីរបស់ ឆែម គិះ កំពុងចាំងដើមឈើទុកធ្វើសសរផ្ទះ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្ទះរបស់ ឆែម គិះ ស្ថិតនៅក្នុងភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៉ែច ប៉ាន់ ៖ ប្រធានសហករណ៍តាម៉ៅជើងក្នុងរបបខ្មែរក្រហម

វន ប៊ុណ្ណា



ប៉ែច ប៉ាន់ អាយុ៧៩ឆ្នាំ រស់នៅភូមិទួលគ្រួស ឃុំទន្ទឹង ស្រុកមេមត់ ខេត្តកំពង់ចាម ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ដល់ វន បុណ្ណ អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកោះថ្ម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៉ែច ប៉ាន់ ភេទប្រុស អាយុ៧៩ឆ្នាំ កើតនៅភូមិទួលគ្រួស ឃុំទន្ទឹង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិតាម៉ៅជើង ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ កាលពីកុមារភាពខ្ញុំបានរៀនតិចតួចប៉ុណ្ណោះ ប៉ុន្តែមិនបានរៀននៅក្នុងសាលាទេ គឺរៀននៅក្នុងវត្តកន្ទុត។ ខ្ញុំមានបងប្អូនចំនួន៦នាក់ ហើយសព្វថ្ងៃនៅរស់រានមានជីវិតតែ២នាក់ប៉ុណ្ណោះ គឺប្រុសទាំងពីរនាក់។ ខ្ញុំមានប្រពន្ធ២នាក់ គឺប្រពន្ធទីមួយមានឈ្មោះ ម៉ក់ កន្ទុន បានស្លាប់នៅក្នុងរបបខ្មែរក្រហម ឯប្រពន្ធទីពីរមានឈ្មោះ អ៊ាង សាគេន។ ខ្ញុំមានកូនចំនួន៥នាក់ ប៉ុន្តែស្លាប់អស់ម្នាក់ នៅសល់៤នាក់ គឺប្រុស២នាក់ និងស្រី២នាក់។ ខ្ញុំមានឪពុកឈ្មោះ ប៉ែច បានស្លាប់តាំងពីសង្គមចាស់ និងម្តាយរបស់ខ្ញុំបានស្លាប់ពេលឆ្លងទន្លេនៅសង្គមចាស់។

នៅអំឡុងឆ្នាំ១៩៧០ មានយន្តហោះមកទម្លាក់គ្រាប់បែកស្ទើរតែគ្រប់ភូមិ ខណៈពេលនោះប្រជាជនបានរត់គេចខ្លួនពីភូមិមួយទៅភូមិមួយទៀត ហើយខ្លះទៀតរត់ចូលលាក់ខ្លួនក្នុងរណ្តៅត្រង់សេ។ នៅពេលយន្តហោះឈប់ទម្លាក់គ្រាប់ ទើបប្រជាជននៅក្នុងភូមិបានចេញពីរណ្តៅត្រង់សេ និងត្រឡប់មកធ្វើស្រែចម្ការវិញ។ កាលនោះ ប្រជាជនបាននាំគ្នាធ្វើស្រែចម្ការដោយប្រវាស់ដៃគ្នា លើកលែងតែការហូបចុក គឺហូបតាមផ្ទះរៀងៗខ្លួន។ ក្រោយមក ស្រាប់តែមានយន្តហោះមកទម្លាក់គ្រាប់បែកម្តងទៀត បណ្តាលឲ្យប្រជាជននៅក្នុងភូមិទួលគ្រួសមួយចំនួនត្រូវគ្រាប់ស្លាប់។ កាលនោះ មានកងទ័ពវៀតកុង (វៀតណាមខាងជើង) ចូលមករស់នៅក្នុងទឹកដីខ្មែរ ទើបទាហានអាមេរិកាំងមកទម្លាក់គ្រាប់បែកលើកងទ័ពវៀតកុងទាំងនោះ។ ពេលនោះសង្គ្រាមកើតឡើងរវាងទាហានអាមេរិកាំង និងកងទ័ពវៀតកុង។ កងទ័ពវៀតកុងបានរស់នៅក្នុងព្រៃតាមបណ្តោយព្រំប្រទល់កម្ពុជា និងវៀតណាម។ បន្ទាប់ពីទាហានអាមេរិកាំងទម្លាក់គ្រាប់បែករួច កងទ័ពវៀតកុងគេចខ្លួនចូលក្នុងទឹកដីខ្មែរកាន់តែជ្រៅ។ ពេលយប់កងទ័ពវៀតកុង ដើរចូលក្នុងភូមិ ប៉ុន្តែខ្ញុំមិនបានដឹង

ថា កងទ័ពវៀតកុងមករកអ៊ីទេ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញឲ្យមករស់នៅតាមទីជនបទ។ ពេលនោះប្រជាជនដែលខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ បានមករស់នៅក្នុងភូមិតាម៉ៅជើង ឃុំជាំតាម៉ៅ ស្រុកមេមត់ និងមួយចំនួនទៀតមករស់នៅភូមិទួលក្រួស ដើម្បីធ្វើស្រែចម្ការ។ នៅពេលយប់ កងឈ្លបខ្មែរក្រហមចាំឃ្លាំមើលថា តើមានប្រជាជនណាធ្វើខុសវិន័យរបស់អង្គការ កងឈ្លបរបស់ខ្មែរក្រហមនឹងយកបុគ្គលនោះទៅសម្លាប់ចោល។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានសម្លាប់មេភូមិ មេឃុំ និងអ្នកបេះដូងមួយចំនួនចោល ដោយមូលហេតុថា អ្នកទាំងអស់នោះនឹងនាំមកនូវបញ្ហាដល់ខ្លួននៅពេលខាងមុខ។ បន្ទាប់មក ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានសហករណ៍នៅក្នុងភូមិទួលក្រួស។ នៅពេលខ្ញុំធ្វើជាប្រធានសហករណ៍ ប្រជាជននៅក្នុងភូមិទួលក្រួសទាំងអស់បានធ្វើការងាររួម ហូបរួម ប៉ុន្តែមិនទាន់ជម្លៀសចេញពីភូមិទួលក្រួសទេ។ ក្រោយមក ទើបខ្មែរក្រហមជម្លៀសខ្ញុំ និងប្រជាជនចេញពីភូមិទួលក្រួស ហើយពេលនោះប្រពន្ធរបស់ខ្ញុំដែលទើបឆ្លងទន្លេរួច បានស្លាប់ដោយសារគ្មានបាយហូបគ្រប់គ្រាន់ និងជំងឺ។ ចាប់តាំងពីពេលនោះមក ខ្ញុំឈប់ធ្វើជាប្រធានសហករណ៍ទៀតហើយ ព្រោះខ្មែរក្រហមជម្លៀសខ្ញុំចេញពីភូមិទួលក្រួសឲ្យទៅនៅភូមិតាម៉ៅជើង។ ប្រជាជននៅភូមិតាម៉ៅជើង ត្រូវបានខ្មែរក្រហមចាប់យកទៅកសាង និងវាយចោលរួមទាំងមេភូមិឲ្យតែដឹកនាំធ្វើខុសគោលការណ៍របស់អង្គការ។

មួយរយៈក្រោយមក ខ្មែរក្រហមជម្លៀសខ្ញុំចេញពីភូមិតាម៉ៅជើងឲ្យទៅនៅភូមិស្រែរនាម ឃុំយរ៉ឹម ស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងទៅភូមិស្រែរនាមដោយគ្មានគ្រួសារ សាច់ញាតិបងប្អូនទៅជាមួយទេ គឺខ្ញុំទៅតែម្នាក់ឯងជាមួយអ្នកភូមិដទៃផ្សេងទៀត។ ខ្ញុំចូលកងចល័ត និងធ្វើស្រែចម្ការនៅភូមិស្រែរនាមអស់រយៈពេល២ខែ។ ចំណែកឯការហូបចុកវិញគឺខ្ញុំហូបបាយ ហើយមានថ្ងៃខ្លះខ្ញុំហូបបបរ។ មិនបានប៉ុន្មានផង ខ្មែរក្រហមក៏ជម្លៀសខ្ញុំចេញពីភូមិស្រែរនាមឲ្យឡើងទូកធ្វើដំណើរតាមដងទន្លេជាមួយប្រជាជនដទៃទៀតទៅស្រុកចំការលើ ខេត្តកំពង់ចាម។ ពេលធ្វើដំណើរតាមផ្លូវ ខ្ញុំប្រទះឃើញមនុស្សស្លាប់តាមផ្លូវច្រើនណាស់ ដោយខ្លះស្លាប់ដោយសារអត់បាយ និងស្លាប់ដោយសារកងទ័ពបាញ់។ ពេលខ្ញុំទៅដល់ឃុំបុសខ្នុរ ស្រុកចំការលើ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើស្រែចម្ការដូចនៅខាងក្រចេះដែរ។ នៅបុស្សខ្នុរបានមួយរយៈ ខ្មែរក្រហមក៏បញ្ជូនខ្ញុំឲ្យទៅនៅឃុំស្វាយទាប និងនគរបាជ័យ នៅខេត្តកំពង់ចាមវិញ។ នៅទីនោះខ្មែរក្រហមឲ្យខ្ញុំហូបបាយរួម ។ ខ្ញុំរស់នៅទីនោះបានរយៈពេលប្រមាណ២ខែ ក៏ទទួលបានដំណឹងថា របបខ្មែរក្រហមបានដួលរលំហើយ។ ពេលនោះខ្ញុំបានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ។ ពេលធ្វើដំណើរតាមផ្លូវ ខ្ញុំប្រទះឃើញមានសាកសពមនុស្សស្លាប់ច្រើនណាស់។ ខ្ញុំដើរតាមផ្លូវ ហត់ត្រង់កន្លែងណាគឺខ្ញុំឈប់សម្រាកនៅកន្លែងនោះ។ ពេលមកដល់ភូមិកំណើតវិញ ខ្ញុំគ្មានស្រូវអង្ករហូបទេ ទើបខ្ញុំដើរទៅរើសកួរស្រូវនៅភូមិក្តុល ឃុំទន្លូង ស្រុកមេមត់ ដោយដេកនៅទីនោះរយៈពេល២ទៅ៣ថ្ងៃ ទើបខ្ញុំត្រឡប់មកភូមិតាម៉ៅជើងវិញ។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្រពន្ធទីពីរ និងបានរស់នៅជាមួយគ្នារហូតមកដល់សព្វថ្ងៃ។



ប៉ិច ប៉ាន់ ធ្វើកាផាលក់ដើម្បីយកប្រាក់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សូ លន ៖ កងចល័តក្នុងរបបខ្មែរក្រហម

**ចាន់ ណារិទ្ធ**



*សូ លន អាយុ៧០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ផ្តល់បទសម្ភាសន៍ដល់ ចាន់ ណារិទ្ធ អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ សូ លន ភេទស្រី អាយុ៧០ឆ្នាំ សព្វថ្ងៃមានមុខរបរធ្វើចម្ការ។ ខ្ញុំមានស្រុកកំណើតនៅភូមិត្រពាំងទន្ទេ ឃុំក្រពុំឈូក ស្រុកកោះអណ្តែត ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ សូ វ៉ាត និងម្តាយឈ្មោះ ញូស ពាច។ ឪពុកម្តាយខ្ញុំបានស្លាប់ដោយសារជំងឺ។ ខ្ញុំមានបងប្អូនចំនួន៥នាក់ គឺប្រុស២នាក់ និង ស្រី៣នាក់។ បងប្អូនខ្ញុំចំនួន៤នាក់បានស្លាប់អស់ហើយ គឺនៅសល់តែខ្ញុំម្នាក់ឯងសព្វថ្ងៃ ។ ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ ស៊ុត ម៉ាន អាយុ៦៦ឆ្នាំ សព្វថ្ងៃប្រកបមុខរបរធ្វើចម្ការ និងចិញ្ចឹមគោ។ ខ្ញុំមានកូន៤នាក់ គឺប្រុស២នាក់ និង ស្រី២នាក់។ កូនរបស់ខ្ញុំមានគ្រួសារអស់ហើយ ហើយ សព្វថ្ងៃខ្ញុំរស់នៅជាមួយកូនពៅ។

កាលពីវ័យកុមារ ខ្ញុំចូលរៀនបានត្រឹមថ្នាក់ទី៩ (ចាស់) នៅសាលារៀនក្នុងវត្តព្រៃម្លូរ ដែលមានទីតាំងស្ថិតនៅភូមិព្រៃម្លូរ ឃុំក្រពុំឈូក ស្រុកកោះអណ្តែត ខេត្តតាកែវ។ គ្រូដែលបង្រៀនខ្ញុំឈ្មោះ គ្រូតា គ្រូអ៊ុន គ្រូសារិន និង គ្រូផែន។ មូលហេតុដែលខ្ញុំ

ឈប់រៀន ដោយសារតែពេលនោះកងទ័ព លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ហើយសិស្សខ្លះនាំគ្នាប្រឆាំងតវ៉ា និងចាប់ផ្តើមវាយគ្រូបង្រៀន។ នៅពេលម្តាយខ្ញុំដឹងដំណឹងខាងលើនេះក៏ឲ្យខ្ញុំឈប់រៀន។ កាលពីក្មេង ខ្ញុំមិនសូវចង់រៀនប៉ុន្មានទេ ប៉ុន្តែដោយសារមានការជំរុញពីឪពុកម្តាយ ទើបខ្ញុំចូលរៀន។

បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅឆ្នាំ១៩៧០ ខ្ញុំរស់នៅជាមួយឪពុកម្តាយខ្ញុំជាធម្មតា ចំណែកប្រជាជនមួយចំនួននៅក្នុងភូមិចាប់ផ្តើមតស៊ូ តាមទារឲ្យសម្តេចព្រះ នរោត្តម សីហនុ ត្រឡប់មកកាន់អំណាចវិញ។ ពេលនោះ បងៗរបស់ខ្ញុំក៏បានចូលរួមក្នុងការតស៊ូនេះដែរ។ បន្ទាប់មកក៏មានការបាញ់សម្លាប់ប្រជាជននៅក្នុងភូមិ។ មិនទាន់បានប៉ុន្មានផងក៏ស្រាប់តែលេចវត្តមានកងទ័ពយួនធីវគី (វៀតណាមខាងត្បូង) ចូលមកស្រុកភូមិរបស់ខ្ញុំ។ នៅពេលឃើញស្រីណាស្អាតៗនៅក្នុងភូមិ កងទ័ពធីវគីបានចាប់ស្រីនោះយកទៅរំលោភនៅបន្ទាយ។ ដូច្នេះឲ្យតែដឹងថា ទ័ពធីវគីចូលមក ស្រីៗនៅក្នុងភូមិនាំគ្នារត់ពួន ខ្លះលាបធ្យូងឲ្យមើលទៅឃើញអាក្រក់។ មិនត្រឹមតែចាប់ស្រីៗទេ កងទ័ពយួនធីវគីថែមទាំងដើរប្រមូលសម្ភាររបស់របរអ្នកភូមិថែមទៀតផង។ ដោយមានការឈឺចាប់ពេលដែលបាត់បង់កូនស្រី បាត់បង់របស់របរដែលខ្លួនស្រឡាញ់ អ្នកភូមិក៏នាំគ្នារត់ចូលព្រៃម៉ាគីដើម្បីចុះចូលជាមួយកងទ័ពខ្មែរក្រហម វាយផ្តួលរំលំរបប លន់ នល់។

លុះដល់ឆ្នាំ១៩៧២ ក៏ចាប់ផ្តើមមានយន្តហោះរបស់ លន់ នល់ ហោះមកទម្លាក់គ្រាប់នៅជាប់ភូមិរបស់ខ្ញុំ ដូច្នេះផ្ទះរបស់ប្រជាជនសុទ្ធតែមានរណ្តៅត្រង់សេសម្រាប់ការពារខ្លួន។ ខ្ញុំធ្លាប់ឃើញយន្តហោះទម្លាក់គ្រាប់បែកចំប្រជាជន៤នាក់ដែលកំពុងតែធ្វើស្រែ បណ្តាលឲ្យស្លាប់នៅវាលស្រែតែម្តង។

នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមរំដោះប្រទេសទាំងស្រុងពីរបប លន់ នល់ ពេលនោះខ្ញុំនៅជាមួយឪពុកម្តាយនៅឡើយ និងមិនទាន់ចេញពីភូមិទេ។ ចំណែកខ្មែរក្រហមចាប់ផ្តើមប្រមូលប្រជាជនឲ្យហូបបាយរួម និងប្រើប្រជាជនឲ្យធ្វើស្រែចម្ការ កាប់ដីដំបូក និងជីកប្រឡាយ។ នៅពេលនោះ ខ្ញុំអាយុប្រមាណ២២ឆ្នាំ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចូលធ្វើការក្នុងកងចល័តនារី និងត្រូវបំពេញការងារ ដូចជារែកដី ជីកប្រឡាយ និងដកស្ទូង។ ចំណែកអាហារហូបចុករបស់ពួកខ្ញុំគឺហូបតែបបររាវៗ ចំណែករបបបាយទាល់តែដល់រដូវច្រូតកាត់ម្តងៗទើបខ្មែរក្រហមឲ្យហូប។ នៅពេលខ្ញុំឈឺម្តងៗ ពេទ្យមានថ្នាំបុរាណដាំឲ្យខ្ញុំផឹក។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមថ្នាក់លើបានចាប់បង្ខំឲ្យខ្ញុំរៀបការ នៅក្នុងចំណោមបុរសនារី១៦គូផ្សេងៗទៀត។ បន្ទាប់ពីរៀបការរួច ខ្មែរក្រហមបានប្រើខ្ញុំឲ្យទៅធ្វើស្រែ ចំណែកប្តីរបស់ខ្ញុំ ខ្មែរក្រហមប្រើឲ្យទៅឃ្វាលគោ។

នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមចាប់ប្រជាជនទៅសម្លាប់ ដោយចោទប្រកាន់ថាជាប់ពាក់ព័ន្ធជាមួយវៀតណាម ជាគ្រូបង្រៀន សិស្សនិស្សិត បញ្ញវន្ត និងជាប់ពាក់ព័ន្ធនៅក្នុងជួរមន្ត្រីរាជការ និងរដ្ឋការពីសង្គមចាស់។ ពេលនោះខ្មែរក្រហមបានយកបងប្អូនខ្ញុំ២នាក់ទៅសម្លាប់ដែរ។

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលមករំដោះ ហើយបានឲ្យពួកខ្ញុំត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន។ ខ្ញុំបានមករស់នៅកំពង់ទឹកមួយរយៈ ក៏ត្រឡប់មករស់នៅភូមិត្រពាំងទន្លេ ស្រុកកំណើតរបស់ខ្ញុំវិញ។ ពេលដែលមកដល់ត្រពាំងទន្លេ ខ្ញុំ និងក្រុមគ្រួសារក៏នាំគ្នាប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ បន្ទាប់មក បងរបស់ខ្ញុំក៏ហៅខ្ញុំឲ្យមករស់នៅភូមិក្រពើពីរ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយប្រកបមុខរបរធ្វើស្រែចម្ការ និងចិញ្ចឹមគោរហូតមកដល់សព្វថ្ងៃ។

# ស្នួង ឆេង ៖ កងនារីភូមិតាម៉ៅកើតក្នុងសម័យខ្មែរក្រហម

ទី ស៊ីថា



ស្នួង ឆេង អាយុ៨៧ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិតាម៉ៅកើត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស្នួង ឆេង ភេទស្រី អាយុ៨៧ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិតាម៉ៅកើត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ ស្នួង និងម្តាយឈ្មោះ ហេង។ ឪពុកម្តាយខ្ញុំស្លាប់នៅក្នុងសម័យប៉ុល ពត ដោយសារជំងឺ។ ខ្ញុំមានបងប្អូនស្រីចំនួន២នាក់ ហើយខ្ញុំគឺជាកូនពៅ។ ខ្ញុំមានប្តីឈ្មោះ ស៊ុន និងមានកូនចំនួន៨នាក់ គឺប្រុស៥នាក់និងស្រី៣នាក់ ប៉ុន្តែកូនខ្ញុំ៣នាក់ បានស្លាប់ ក្នុងនោះមានកូនច្បងឈ្មោះ ស៊ុនទី ភេទប្រុស អាយុ១៥ឆ្នាំ ធ្វើពេទ្យនៅមេមត់ស្លាប់ក្នុងសម័យខ្មែរក្រហម។ កូនបន្ទាប់ស្លាប់នៅអាយុ១ខួប ដោយសារជំងឺ ហើយមួយទៀតស្លាប់ដោយសារធ្លាក់ពីលើម៉ូតូ នៅអាយុ៣២ឆ្នាំ។

នៅជំនាន់សង្គ្រាម ខ្ញុំនៅតូចមិនបានរៀនសូត្រទេ។ ខ្ញុំនៅជួយឃ្វាលគោ និងក្របី ដើម្បីសម្រាលការងារឪពុកម្តាយ។ ពេលទំនេរពីឃ្វាលគោ ខ្ញុំតែងតែទៅស៊ីឈ្នួលប្រូតស្រូវក្នុងមួយថ្ងៃទទួលបានប្រាក់១៥រៀល ចំណែកមនុស្សប្រុសបាន២០រៀល ព្រោះមនុស្សប្រុសវែកកណ្តាប់ ប្រើកម្លាំងច្រើនជាងស្រី។ លុះខ្ញុំអាយុ១២ឆ្នាំ ទើបទៅស៊ីឈ្នួលឆ្ការព្រៃធ្វើផ្លូវទុកឲ្យឡានបើកបរ ដោយក្នុងមួយថ្ងៃទទួលបានប្រាក់៥រៀល។ ពេលខ្លះខ្ញុំទៅដាំសណ្តែកក្នុងមួយថ្ងៃក៏ទទួលបានប្រាក់៥រៀលដែរ ចំណែកប្រុសៗទទួលបាន១០រៀល ដោយសារត្រូវគាស់គុម្ពសណ្តែក និងត្រូវប្រើកម្លាំងខ្លាំង។ នៅពេលនោះប្រជាជនប្រកបមុខរបរធ្វើស្រែចម្ការ និងដាំដំណាំ។

នៅក្នុងឆ្នាំ១៩៧០ពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ប្រជាជនក្នុងភូមិមិនបានដឹងទេ ប៉ុន្តែមេភូមិបានផ្តល់ដំណឹងថា មានប្រជុំនៅស្រុកមេមត់។ ពេលនោះប្តីខ្ញុំ និងប្រជាជនក្នុងភូមិមួយចំនួនទៀតបានធ្វើដំណើរដោយថ្មើរជើងតាំងពីទៀបភ្លឺ ហើយព្រឹកព្រលឹមក៏ទៅដល់មេមត់។ ពេលទៅដល់ ប្តីរបស់ខ្ញុំឃើញប្រជាជនកំពុងធ្វើបាតុកម្មនៅមេមត់ ដោយមានគប់ដុំថ្ម ដេញវាយគ្នា ដើម្បីទាមទារឲ្យសម្តេចព្រះ នរោត្តម សីហនុ យាងមកគ្រប់គ្រងប្រទេសវិញ។ ប្តីរបស់ខ្ញុំត្រឡប់មកពីស្រុក

មេមត់នៅពេលយប់ ហើយខ្ញុំបានប្រាប់គាត់ឲ្យឡើងទៅពួននៅលើដើមគរ ព្រោះមានមនុស្សមកតាមរកប្តីរបស់ខ្ញុំ រហូតទាល់តែសភាពការណ៍ស្ងប់ស្ងាត់ទើបខ្ញុំឲ្យប្តីរបស់ខ្ញុំចុះមកនៅលើផ្ទះវិញ។ កន្លះខែក្រោយមក មានទាហាន លន់ នល់ ដើររកមនុស្សប្រុសតាមផ្ទះដើម្បីចាប់យកទៅធ្វើជាទាហាន។ អំឡុងពេលនោះ ខ្ញុំបានប្រាប់ប្តីរបស់ខ្ញុំឲ្យទៅពួននៅតាមព្រៃជិតៗភូមិ រហូតទាល់តែទាហាន លន់ នល់ ចាកចេញ ទើបខ្ញុំហៅប្តីឲ្យចូលមកក្នុងភូមិវិញ។ ពេលនោះ ទោះបីប្រទេសកំពុងមានបាតុកម្ម ប៉ុន្តែប្រជាជននៅធ្វើស្រែចម្ការ និងប្រកបមុខរបរចិញ្ចឹមជីវិតធម្មតា។

នៅឆ្នាំ១៩៧៣ ពេលដែលមានការទម្លាក់គ្រាប់បែក ប្រជាជននៅក្នុងភូមិរស់នៅលំបាកវេទនាខ្លាំងណាស់ ព្រោះត្រូវរត់គេចគ្រាប់ ហើយលាក់ខ្លួននៅតាមរណ្តៅត្រង់សេ។ រណ្តៅត្រង់សេធំអាចដាក់គ្រែបានចំនួន១ទៅ២គ្រែ ហើយមានជម្រៅជ្រៅ លិចក្បាលអាចដើរទៅមកបាន។ ប្រជាជនរស់នៅក្នុងភូមិមានការភ័យខ្លាច ហើយពិបាកក្នុងការធ្វើស្រែចម្ការ។ ពេលនោះ ទាហានអាមេរិកាំងក៏មកទម្លាក់គ្រាប់លើកងទ័ពវៀតកុង (វៀតណាមខាងជើង) ដែលលាក់ខ្លួននៅជាយៗភូមិ ជាហេតុធ្វើឲ្យប្រជាជនខ្មែរខ្លះរងរបួស និងស្លាប់ដែរ។ ថ្ងៃមួយ ខ្ញុំឃើញទាហានអាមេរិកាំងបើករថក្រោះ៣ទៅ៤គ្រឿង កាត់តាមភូមិ សំដៅទៅវាលស្រែដើម្បីដេញកងទ័ពវៀតកុង។ នៅពេលនោះ ខ្ញុំមានកូន៤នាក់ហើយ គឺប្រុស២នាក់ និងស្រី២នាក់។

ចូលមកដល់ឆ្នាំ១៩៧៤ ខ្មែរក្រហមចាប់ផ្តើមរៀបចំប្រជាជនឲ្យធ្វើការងារប្រវាស់ដៃគ្នា ហើយបានផលស្រូវចែកគ្នាទៅតាមចំនួនមនុស្សធ្វើការ។ ប្រជាជននៅក្នុងភូមិធ្វើស្រែរួមគ្នា ហើយច្រូតស្រូវយកកណ្តាប់ទៅដាក់នៅកន្លែងតែមួយ។ រហូតបោកបែនស្រូវរួច ទើបប្រធានកងយកស្រូវទៅចែកគ្នាទៅតាមសមាជិកដែលចូលរួមធ្វើការងារ គិតជាថាំងឬរទេះគោ ដោយក្នុងមួយរទេះគោមាន២៥ថាំង។

នៅឆ្នាំ១៩៧៥ ខ្ញុំឃើញមានប្រជាជនជាច្រើនត្រូវបានខ្មែរក្រហមជម្លៀសមកពីភ្នំពេញ ឲ្យមករស់នៅជាមួយប្រជាជនក្នុងភូមិតាម៉ៅកើត។ ខ្មែរក្រហមចាត់តាំងឲ្យប្រជាជនជម្លៀសមកថ្មីទាំងនោះទៅនៅជាមួយប្រជាជននៅក្នុងភូមិតាម៉ៅកើត ដោយផ្ទះខ្លះឲ្យប្រជាជនជម្លៀសថ្មីនៅចំនួនមួយគ្រួសារ ខ្លះទៀតឲ្យនៅពីរគ្រួសារ។ ប្រជាជនជម្លៀសមកថ្មី និងប្រជាជនចាស់ ធ្វើការងារដូចគ្នា។ កាលនោះ ខ្មែរក្រហមឲ្យកូនរបស់ខ្ញុំអាយុ១២ឆ្នាំទៅរៀននៅសាលាថ្នល់ទទឹង ដោយគ្រូបង្រៀនសិស្សចាប់ពីម៉ោង៧ព្រឹក។ កូនរបស់ខ្ញុំទៅរៀនតាំងពីព្រឹករហូតម៉ោង១១ ទើបត្រឡប់មកផ្ទះវិញ។ បន្ទាប់មក កូនរបស់ខ្ញុំត្រូវត្រឡប់ទៅឃ្វាលគោ និងក្របី។ គ្រូបង្រៀនកូនរបស់ខ្ញុំឈ្មោះ គ្រូវឿន ស្លាប់កាលពី៤ឆ្នាំមុនដោយសារចាស់ជរា។ កូនរបស់ខ្ញុំឈប់រៀននៅអាយុ១៥ឆ្នាំ ព្រោះកម្មាភិបាលឃុំមកស្នើកូនរបស់ខ្ញុំឲ្យធ្វើពេទ្យនៅស្រុកមេមត់។ ពេលទៅធ្វើពេទ្យនៅមេមត់ កូនរបស់ខ្ញុំបានមកលេងផ្ទះចំនួន២ដង គឺ លើកទីមួយ) មករកដើមផ្កាយកទៅដាំ លើកទី២) មកមើលប្អូនឈឺ និងហាមមិនឲ្យប្អូនហូបអាហារផ្តេសផ្តាស ខ្លាចលាប់ជំងឺ បន្ទាប់ពីនោះមក កូនរបស់ខ្ញុំបាត់ដំណឹងរហូត។ ចំណែកកូនស្រីខ្ញុំទីពីរឈ្មោះ លី អាយុ១៣ឆ្នាំ ធ្វើការងារក្នុងកងចល័តភូមិតាម៉ៅកើត និងមិនដែលមកដេកនៅផ្ទះជាមួយឪពុកម្តាយទេ។ អង្គការចាត់តាំង លី ឲ្យទៅធ្វើការងារច្រូត ដកស្ទូង នៅភូមិណា គឺ លី សម្រាកនៅភូមិនោះតែម្តង។ ទោះបី លី ធ្វើការងារនៅកងចល័តនៅជិតៗភូមិរយៈពេលមួយឆ្នាំក៏ដោយ ក៏គាត់មកលេងផ្ទះបានតែពីរដងតែប៉ុណ្ណោះ ហើយបើទៅធ្វើការងារឆ្ងាយពីភូមិ គាត់មិនបានមកលេងផ្ទះទេ។ ខ្ញុំបានទទួលដំណឹងកូនរបស់ខ្ញុំពីអ្នកស្គាល់គ្នានៅក្នុងភូមិ នៅពេលកងចល័តកូនរបស់ខ្ញុំនៅភូមិជាំតាម៉ៅ ហើយត្រូវបានអង្គការចល័តទៅធ្វើការងារនៅទីកន្លែងផ្សេងៗ។

ប្តីរបស់ខ្ញុំធ្វើជាមេសហករណ៍ដើររកបន្លែ អង្ករ ប្រហុក សម្រាប់ឲ្យចុងភៅដាំស្លឲ្យប្រជាជនហូបរួម ព្រមទាំងនៅគ្រប់គ្រងកន្លែងដាំបាយ និងធ្វើម្ហូបនៅ

សហករណ៍។ ខ្មែរក្រហមចាត់តាំងចុងភៅឲ្យឆ្លាស់វេនគ្នាដាំបាយ និងធ្វើម្ហូប ហើយបន្ទាប់ពីដាំបាយធ្វើម្ហូបរួច ពេលថ្ងៃទំនេរត្រូវធ្វើការងារស្រែចម្ការ ដូចប្រជាជនទូទៅដែរ។ ចំណែកខ្ញុំធ្វើជានារីភូមិ ដោយកាលនោះនៅក្នុងមួយភូមិៗ មេភូមិត្រូវជ្រើសរើសយកនារី៣នាក់។ ខ្ញុំយាយលី និងបងស្រីខ្ញុំឈ្មោះ ស៊ឹម ត្រូវបានមេភូមិជ្រើសរើសឲ្យធ្វើជានារីភូមិ។ យាយលីស្លាប់ដោយសារចាស់ជរា ប្រមាណ៧ឆ្នាំមុន ចំណែកបងស្រីខ្ញុំឈ្មោះ ស៊ឹម អាយុ៨៩ឆ្នាំហើយសព្វថ្ងៃនេះ។ ខ្មែរក្រហមបានចាត់តាំងខ្ញុំ យាយលី និងបងស្រីរបស់ខ្ញុំឲ្យទៅរៀននៅមេម៉ង ហើយបានជួបជាមួយមនុស្សរាប់ពាន់នាក់សុទ្ធតែស្រីៗ។ ខ្មែរក្រហមបានបង្រៀនខ្ញុំរយៈពេល៣ទៅ៤ថ្ងៃក្នុងគោលបំណងដើម្បីកុំឲ្យខ្ញុំបែកចិត្តពីអង្គការថ្នាក់លើ។

នៅពេលត្រឡប់មកផ្ទះវិញ ខ្ញុំបានធ្វើស្រែចម្ការធម្មតា រហូតដល់ថ្ងៃដែលខ្មែរក្រហមកោះហៅទៅប្រជុំ ទើបខ្ញុំដើរប្រាប់ប្រជាជនក្នុងភូមិឲ្យទៅប្រជុំតាមបទបញ្ជារបស់ខ្មែរក្រហម។ ខ្មែរក្រហមជម្លៀសប្រជាជននៅក្នុងភូមិភូមិដាំតាម៉ៅកើតចំនួនពីរលើក។ ដំបូង ខ្មែរក្រហមជម្លៀសប្តីរបស់ខ្ញុំជាមួយមេឃុំដាទៅចម្ការក្រូច ក្នុងស្រុកស្នួល ខេត្តក្រចេះ ហើយប្រហែលជាកន្លះខែក្រោយមក ទើបខ្មែរក្រហមជម្លៀសខ្ញុំទៅនៅភូមិអំពុក ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ តាមក្រោយ។ ខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើស្រែចម្ការជាមួយប្រជាជនភូមិអំពុក ពេលនោះ មានអ្នកភូមិដែលដឹងដំណឹងពីប្តីរបស់ខ្ញុំបានមកប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅចម្ការក្រូច (ទំនប់ថ្គង់) ក្នុងស្រុកស្នួល ខេត្តក្រចេះហើយ។ បន្ទាប់មក ខ្មែរក្រហមជម្លៀសខ្ញុំបន្តទៅភូមិកោះរងាវ ឃុំកំពង់ក្របី ស្រុកសំបូរ ខេត្តក្រចេះ។ ខ្ញុំធ្វើការងារប្រូតកាត់នៅទីនោះបានមួយខែកន្លះ ក៏ទទួលដំណឹងថា ប្រទេសជាតិត្រូវបានរំដោះ ហើយប្រជាជនដែលនៅក្នុងភូមិស្រុកណាអាចត្រឡប់ទៅភូមិឃុំស្រុកនោះវិញ។ ខ្ញុំបានជិះកាណូតពីភូមិកោះរងាវ មកថ្មគ្រែ ហើយជិះកាណូតពីថ្មគ្រែមកស្រុកស្ទឹងត្រង់។ នៅស្រុកស្ទឹងត្រង់មានឡានចាំដឹកប្រជាជន ប៉ុន្តែពេលនោះ ខ្មែរក្រហមក្លែងបន្លំខ្លួនដឹកប្រជាជនយកទៅសម្លាប់ចោលអស់ជាច្រើននាក់ដែរ។ ខ្ញុំបានដើរទៅភូមិបុស្ស ឃុំបារាយណ៍ ហើយរស់នៅទីនោះបានរយៈពេលមួយខែ។

បន្ទាប់មកខ្ញុំបានធ្វើដំណើរត្រឡប់មកផ្ទះនៅស្រុកកំណើតវិញ ដោយដេកតាមផ្លូវរយៈ ពេល៣យប់ទើបមកដល់ភូមិតាម៉ៅ។ ពេលមកដល់ភូមិ ខ្ញុំឃើញផ្ទះខ្ញុំឆេះអស់ហើយ ដូច្នេះខ្ញុំក៏ចាប់ផ្តើមកាប់ឆ្ការព្រៃសង់ផ្ទះស្នាក់នៅ ហើយមួយឆ្នាំក្រោយមកទើបខ្ញុំអាចធ្វើស្រែចម្ការបានធម្មតាវិញ។ សព្វថ្ងៃ ខ្ញុំរស់នៅម្នាក់ឯង និងប្រកបរបរធ្វើឈ្នាង, កន្ត្រង់ប្រហុក កាផា និងចង្អេរលក់ ដើម្បីចញ្ចឹមជីវិត។



សព្វថ្ងៃ ស្នួង ឆេង ភេទស្រី អាយុ៨៧ឆ្នាំ រស់នៅម្នាក់ឯង និងប្រកបរបរធ្វើឈ្នាង ដើម្បីចញ្ចឹមជីវិត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សព្វថ្ងៃ ស្នួង ឆេង ភេទស្រី អាយុ៨៧ឆ្នាំ រស់នៅម្នាក់ឯង និងប្រកបរបរធ្វើកាផា ដើម្បីចញ្ចឹមជីវិត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស្ហួន ឃឿយ ៖ កងទ័ពខ្មែរក្រហមប្រចាំតំបន់សៀមរាប និងឧត្ដរមានជ័យ

**មេក វីន**



*ស្ហួន ឃឿយ អាយុ៦៧ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ស្ហួន ឃឿយ ភេទប្រុស អាយុ៦៧ឆ្នាំ មានទីកន្លែងកំណើតនៅភូមិសំរោង ឃុំចន្ទាស់ដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិទួលប្រាសាទ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

កាលពីកុមារភាពខ្ញុំពុំបានចូលរៀនសូត្រដូចក្មេងៗដទៃទៀតនោះទេ ដោយសារតែគ្រួសារខ្ញុំមានជីវភាពខ្វះខាត ម្យ៉ាងទៀតខ្ញុំធំឡើងនៅក្នុងអំឡុងស្រុកមានសង្គ្រាម។ សូម្បីតែបងៗរបស់ខ្ញុំក៏មិនបានសិក្សារៀនសូត្រដែរ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ ហើយខ្ញុំគឺជាកូនទី៥នៅក្នុងគ្រួសារ។ ឪពុកម្ដាយខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ សម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។

នៅឆ្នាំ១៩៧០ បន្ទាប់ពីលន់នល់ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ ខ្ញុំទើបមានអាយុ១៤ឆ្នាំ ក៏ស្ម័គ្រចិត្តចូលធ្វើកងទ័ពរំដោះខ្មែរក្រហម។ បន្ទាប់ពីខ្ញុំចូលធ្វើជាកងទ័ពរំដោះខ្មែរក្រហមរួចហើយ ខ្ញុំត្រូវហ្វឹកហាត់ពីយុទ្ធសាស្ត្រធ្វើសង្គ្រាមអស់រយៈពេល៣ខែ ទើបចេញទៅវាយនៅសមរភូមិមុខ។ ដំបូងខ្ញុំមិនទាន់ស្គាល់អ្នកធ្វើការនៅក្នុងជួរកងទ័ពទេ ប៉ុន្តែបងៗអ្នកស្ម័គ្រចិត្តចូលមុនខ្ញុំបង្ហាញការស្រឡាញ់រាប់អានខ្ញុំដូចបងដូចប្អូនដែរ។ ខ្ញុំនៅតូច ហេតុនេះខ្ញុំស្ពាយកាំភ្លើងអូសដី។ ខ្ញុំទៅតាមការចាត់តាំង

របស់អង្គភាពទ័ព ព្រោះរំពឹងថាការតស៊ូរបស់ខ្ញុំ ដើម្បីការពារទឹកដីខ្មែរ។ មុខសញ្ញាដែលខ្ញុំត្រូវវាយ គឺនៅសមរភូមិខេត្តសៀមរាប ឆ្ពោះទៅខេត្តឧត្តរមានជ័យ។ ខ្សែត្រៀម និងទីតាំងឈរជើងរបស់ខ្ញុំគឺនៅក្នុងខេត្តសៀមរាប និងឧត្តរមានជ័យតែម្តង គឺមិនបានទៅខេត្តឆ្ងាយៗឡើយ។ មុនពេលចេញទៅវាយតទល់នឹងទាហាន លន់ នល់ គឺកងស៊ើបការណ៍សម្ងាត់តែងតែចេញទៅស៊ើបការណ៍បន្ទាយទាហាន លន់ នល់ ដើម្បីឲ្យស្គាល់ច្បាស់ទើបនាំកងទ័ពចេញទៅវាយ។

អំឡុងពេលវាយប្រយុទ្ធគ្នាម្តងៗ ភាគីទាំងសងខាងតែងតែមានអ្នកស្លាប់ និងអ្នករបួសដូចគ្នា។ កងពលខ្ញុំមានកម្លាំងចំនួន៧០០នាក់។ ការហូបចុករបស់ខ្ញុំមិនមានការខ្វះខាតឡើយ គឺអង្គភាពទ័ពផ្តល់ស្បៀងឲ្យហូបគ្រប់គ្រាន់។ ខ្ញុំស្ថិតនៅក្នុងខ្សែត្រៀមប្រយុទ្ធតទល់ជាមួយទាហាន លន់ នល់ អស់រយៈពេល៥ឆ្នាំទើបអាចផ្តួលរំលំរបបសាធារណរដ្ឋខ្មែរបានទាំងស្រុង។ បន្ទាប់ពីទទួលបានជ័យជម្នះ ខ្ញុំរំពឹងថានឹងត្រឡប់មកផ្ទះសម្បែង ជួបជុំឪពុកម្តាយបងប្អូនមីងមាវិញ ប៉ុន្តែខ្ញុំមិនបានត្រឡប់មកជួបជុំគ្រួសារដូចការរំពឹងទុកភ្លាមៗនោះទេ។ រហូតដល់មានការប្រារព្ធធ្វើពិធីបុណ្យនៅប្រាសាទអង្គរវត្តរយៈពេល៧យប់៧ថ្ងៃ ទើបខ្ញុំបានជួបជាមួយម្តាយឪពុក បងប្អូន ដោយសារតែពេលនោះគាត់បានមកលេងប្រាសាទអង្គរវត្តដែរ។

ក្រោយពីបានជួបជុំគ្រួសារមិនបានប៉ុន្មានផង ថ្នាក់លើដាក់បញ្ជាឲ្យខ្ញុំត្រឡប់ទៅឈរជើងនៅតាមមុខសញ្ញារៀងៗខ្លួនវិញ។ ចាប់តាំងពេលនោះ ខ្ញុំលែងបានដឹងពីសុខទុក្ខក្រុមគ្រួសារខ្ញុំទៀតហើយ។ ចំណែកសមាជិកក្នុងអង្គភាពទ័ពរបស់ខ្ញុំដែលមានចំនួន៥០០នាក់ ត្រូវបានមេបញ្ជាការបញ្ជូនទៅលើកទំនប់បឹងស្នោរ ខេត្តឧត្តរមានជ័យ។ ក្រោយមកអង្គភាពដាក់បញ្ជាឲ្យអង្គភាពរបស់ខ្ញុំទៅឈរជើងនៅតាមភូមិ ដើម្បីដឹកនាំប្រជាជនធ្វើការលើកទំនប់ដីកប្រឡាយ ធ្វើស្រែ ដាំដំណាំ បង្កបង្កើនផលជូនអង្គការ។ ចំពោះរបបអាហារក្នុងតំបន់របស់ខ្ញុំគឺមិនមានការខ្វះខាតឡើយ រួមទាំងកងទ័ពទទួលបានអាហារហូបចុកគ្រប់គ្រាន់។ ភូមិភាគដែលខ្ញុំរស់នៅគឺមិនមានការពិបាកនោះទេ ការកាប់សម្លាប់ វាយធ្វើបាបប្រជាជនក៏ខ្ញុំមិនដែលបានជួបប្រទះដែរ។ ខ្ញុំរស់នៅធ្វើការជាមួយប្រជាជនក្នុងខេត្តសៀមរាប ឧត្តរមានជ័យ រហូតដល់កងទ័ពវៀតណាមវាយចូលមកនៅដើមឆ្នាំ១៩៧៩ ទើបអង្គភាពខ្ញុំ និងប្រជាជនមួយចំនួននាំគ្នារត់ឡើងទៅភ្នំដងរែក។

អំឡុងពេលធ្វើដំណើរឡើងទៅភ្នំដងរែក អង្គភាពទ័ពរបស់ខ្ញុំត្រូវរៀបចំកម្លាំងជាពីរ គឺ ១) កងទ័ពដែលមានប្រពន្ធកូន ត្រូវធ្វើដំណើរឡើងភ្នំមុន និង ២) កងទ័ពដែលមិនមានប្រពន្ធកូន គឺត្រូវនៅចាំការពារប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាម។ ខ្ញុំស្ថិតក្នុងកងទ័ពដែលមិនមានគ្រួសារ ហេតុនេះត្រូវនៅបន្តប្រយុទ្ធជាមួយកងទ័ពវៀតណាមអស់ជាច្រើនឆ្នាំ។ អំឡុងពេលដែលប្រយុទ្ធគ្នាធ្វើឲ្យខ្ញុំត្រូវរបួស ហើយកងទ័ពក៏បញ្ជូនខ្ញុំទៅព្យាបាលនៅពេទ្យស្ថិតនៅលើភ្នំដងរែក។ បន្ទាប់ពីខ្ញុំសម្រាកព្យាបាលរបួសបានមួយរយៈ ខ្ញុំក៏បានជាសះស្បើយ មេបញ្ជារបស់ខ្ញុំក៏បានរៀបការប្រពន្ធឲ្យខ្ញុំ។ ប្រពន្ធរបស់ខ្ញុំធ្វើការនៅក្នុងមន្ទីរពេទ្យ ហើយយើងទាំងពីរនាក់បានរស់នៅជាមួយគ្នារហូតមកដល់បច្ចុប្បន្ន។



សួន ឃឿយ កំពុងបិតផ្តៅដើម្បីធ្វើសម្ភារប្រើប្រាស់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហែម ភណ្ឌ័៖ អតីតកងនារីផលិតអំបិល

**ចាន់ ណារិទ្ធ**



ហែម ភណ្ឌ័ អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ ចាន់ ណារិទ្ធ អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហែម ភណ្ឌ័ ភេទស្រី អាយុ៦៥ឆ្នាំ សព្វថ្ងៃគឺជាមេភូមិក្រពើពីរក្រោម។ ខ្ញុំមានស្រុកកំណើតនៅភូមិទឹកអំបិល ឃុំល្មៀង ស្រុកសំរោង ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ហែម សែ និងម្តាយឈ្មោះ ចិន ផាន។ ឪពុកម្តាយខ្ញុំបានស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូន៧នាក់ ក្នុងនោះប្រុស៣នាក់ និងស្រី៤នាក់។ ចំណែកខ្ញុំគឺជាកូនទីមួយនៅក្នុងគ្រួសារ។ ខ្ញុំបានរៀបការប្តីឈ្មោះ អែម អឿន សព្វថ្ងៃអាយុ៧១ឆ្នាំ ប្រកបមុខរបរធ្វើចម្ការ និងចិញ្ចឹមគោ។ ខ្ញុំមានកូន៤នាក់ គឺប្រុស៣នាក់ និងស្រី១នាក់ ហើយកូនរបស់ខ្ញុំសុទ្ធតែរៀបការអស់ហើយ ។

កាលពីកុមារ ខ្ញុំបានចូលរៀនថ្នាក់ទី១២ (សង្គមចាស់) នៅសាលារ៉ូម ស្ថិតក្នុងឃុំល្មៀង ស្រុកសំរោងខេត្តតាកែវ។ ពេលនោះឪពុកម្តាយខ្ញុំ បានជំរុញឲ្យខ្ញុំចូលរៀន។ ខ្ញុំចូលរៀននៅឆ្នាំ១៩៦៩ ហើយក៏ឈប់រៀនវិញនៅឆ្នាំ១៩៧០ ពេលដែលទាហាន លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ។

នៅឆ្នាំ១៩៧០ ពេលដែលទាហាន លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅក្នុងភូមិរបស់ខ្ញុំចាប់ផ្តើមមានការបាញ់ប្រោះ

ដាក់គ្នា និងវាយតប់គ្នា។ នៅចន្លោះពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧២ ប្រជាជនត្រូវបានជម្លៀសឲ្យទៅរស់នៅផ្លូវជាតិលេខ៣ ព្រោះនៅទីនោះមានការប្រយុទ្ធគ្នា។ មិនយូរប៉ុន្មានប្រជាជនក៏នាំគ្នាធ្វើបាតុកម្មទាមទារឲ្យសម្តេចព្រះ នរោត្តម សីហនុ ត្រឡប់មកកាន់អំណាចវិញ។ ប្រជាជនដែលបានចូលរួមធ្វើបាតុកម្មភាគច្រើនត្រូវបានទាហាន លន់ នល់ បាញ់សម្លាប់។ ទាហាន លន់ នល់ បាញ់សម្លាប់ប្រជាជនដោយមិនញញើតដៃឡើយ ព្រោះដោយមានបញ្ជាពីថ្នាក់លើ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅរស់នៅផ្លូវជាតិលេខ៣ បានប្រមាណជិតមួយឆ្នាំក៏ត្រឡប់មករស់នៅស្រុកកំណើតវិញ។

នៅឆ្នាំ១៩៧៤ ខ្ញុំបានចូលធ្វើជាកងនារីខ្មែរក្រហម ប៉ុន្តែពេលប្រធានកងខ្មែរក្រហមឃើញខ្ញុំតូចពេកក៏ឲ្យខ្ញុំចូលខាងមន្ទីរនីរសារវិញ។ តួនាទីជានីរសាររបស់ខ្ញុំ គឺត្រូវរត់សំបុត្រពីអង្គភាពមួយទៅអង្គភាពមួយទៀត។

នៅឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហម ទទួលជ័យជម្នះលើរបប លន់ នល់ ពេលនោះអង្គភាពរបស់ខ្ញុំបានឡើងមកឈរជើងនៅចំណុចចោមចៅនៅផ្លូវជាតិលេខ៤។ ពេលចូលដល់ទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមដេញផ្សងៗចាប់ផ្តើមជម្លៀសប្រជាជនចេញពីផ្ទះសម្បែង ព្រោះកងទ័ពខ្មែរក្រហមត្រូវការបោសសម្អាតអ្នកដែលពាក់ព័ន្ធជាមួយរបប លន់ នល់។ ពេលនោះអង្គភាពរបស់ខ្ញុំចូលក្នុងក្រុងភ្នំពេញបានតែមួយថ្ងៃ ក៏ដកមកឈរជើងផ្សារស្ពឺវិញ។ ពេលនោះកងទ័ពខ្មែរក្រហមជម្លៀសប្រជាជនជាច្រើនទៅខេត្តកំពង់ស្ពឺ តាកែវ និងកំពត។ ខ្ញុំផ្លាស់មករស់នៅខាងផ្សារស្ពឺបានមួយរយៈ ខ្មែរក្រហមក៏ផ្លាស់អង្គភាពរបស់ខ្ញុំឲ្យមករស់នៅស្រែអំបិល ស្ថិតនៅក្នុងខេត្តកំពតវិញ។ ខ្មែរក្រហមបានចាត់តាំងក្រុមនារីផលិតអំបិល ដែលមានប្រធានក្រុមដឹកនាំឈ្មោះ ធី នៅតំបន់៣៣ ។ ខ្ញុំបានចូលក្រុបខណ្ឌរដ្ឋរបស់ខ្មែរក្រហមផ្នែកផលិតអំបិល។ ក្រុមរបស់ខ្ញុំផលិតអំបិលក្នុងខេត្តកំពតរហូតដល់ឆ្នាំ១៩៧៩។ ការងារដែលខ្ញុំបំពេញជូនអង្គការរាល់ថ្ងៃ គឺពេលថ្ងៃផលិតអំបិល និងពេលយប់កាន់កាំភ្លើងយាមនៅតាមឆ្នេរសមុទ្រ។ ចំពោះអាហារហូបចុក គឺខ្ញុំបានហូបគ្រប់គ្រាន់មិនដែលខ្វះខាតឡើយ ដោយក្នុងមួយថ្ងៃ អង្គភាពឲ្យហូបពីពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច។ នៅខែប្រាំងកងនារីរបស់ខ្ញុំចាប់ផ្តើមសម្អាតទីធ្លា ហើយខែវស្សាចាប់ផ្តើមបូមទឹកដាក់ស្រែ ហើយពេលទទួលបានអំបិល យើងក៏នាំគ្នារែកទាំងយប់ទាំងថ្ងៃដាក់ឃ្លាំង។ ប្រសិនបើមានអ្នកឈឺ គឺមានអង្គភាពពេទ្យនៅប្រចាំការផ្តល់ជួយពិនិត្យ និងបើកថ្នាំឲ្យលេប។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយចូលមក ពេលនោះអង្គភាពស្រែអំបិលរបស់ខ្ញុំនាំគ្នារត់ចូលទឹកដីថៃ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៩។ ក្រោយមកអង្គភាពរបស់ខ្ញុំក៏ចុះមករស់នៅថ្មដា ប៉ុន្តែបានមួយរយៈក៏រត់ចូលថៃម្តងទៀតដោយសារសង្គ្រាមមិនទាន់ចប់។ ពេលដែលស្ងាត់សង្គ្រាម ខ្ញុំបានមករស់នៅថ្មដាវិញ។

នៅឆ្នាំ១៩៩១ ខ្ញុំបានចុះមករស់នៅភូមិក្រពើពីរ ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ រហូតមកដល់បច្ចុប្បន្ន។ សព្វថ្ងៃ ក្រៅពីធ្វើជាមេភូមិ ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។


ទេសភាពនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្នុងរដូវវស្សា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខេង សាអ៊ិត ៖ កងចល័តរបស់អង្គការ

**ណឹម ស្រីណែត**



ខេង សាអ៊ិត អាយុ៦១ឆ្នាំ កើតនៅភូមិខត្តម ឃុំព្រែកក្របៅ ស្រុកពាមជរ ខេត្តព្រៃវែង។ បច្ចុប្បន្នរស់នៅភូមិព្រែកធំ ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ខេង សាអ៊ិត ភេទស្រី អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅភូមិខត្តម ឃុំព្រែកក្របៅ ស្រុកពាមជរ ខេត្តព្រៃវែង។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិព្រែកធំ ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង។ កាលពីសង្គមចាស់ ឪពុករបស់ខ្ញុំធ្វើជាទាហាន លន់ នល់។ ខ្ញុំមានបងប្អូនចំនួន១០នាក់ ក្នុងនោះប្រុស៣នាក់ និងស្រី៧នាក់។

បន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះលើរបប លន់ នល់ នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានប្រមូលទ្រព្យសម្បត្តិ លុយកាក់ និងសម្ភារផ្សេងៗដាក់ចូលក្នុងរោងសហករណ៍រួម មិនឲ្យប្រើប្រាស់ជាឯកជនឡើយ។ អង្គការចាប់ផ្ដើមបែងចែកការងារប្រចាំថ្ងៃឲ្យប្រជាជនធ្វើ។ ឪពុករបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យរកបង្កង និងដាក់លបយកបង្កង។ ចំណែកម្ដាយរបស់ខ្ញុំធ្វើការក្នុងរោងបាយរបស់អង្គការ ព្រោះអង្គការរៀបចំឲ្យប្រជាជនធ្វើការងាររួមគ្នា ហូបរួមគ្នា និងស្នាក់នៅរួមគ្នាពី៥នាក់ ទៅ៦នាក់។

ពេលនោះ ខ្ញុំទើបតែមានអាយុ១២ឆ្នាំ ត្រូវបានអង្គការចាត់តាំងឲ្យទៅឃ្វាលគោ និងស្នាក់នៅជាមួយកុមារៗផ្សេងៗទៀត។ ពេលនោះ អង្គការឲ្យទៅរៀននៅជិតក្រោលគោ ហើយក្រោយពីរៀនចប់ អង្គការបានប្រើឲ្យកុមារកើបអាចម៍គោ និងជញ្ជូនខសដាក់រោងបាយ។

នៅចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ខ្ញុំធំពេញរូបពេញរាង ហេតុនេះអង្គការបញ្ជូនខ្ញុំឲ្យទៅធ្វើការក្នុងកងចល័តឃុំស្វាយភ្លោះ ស្រុកពាមជរ ខេត្តព្រៃវែង។ ខ្ញុំត្រូវធ្វើការការងារក្នុងកងចល័ត ដូចជា ដកស្ទូង ជីកប្រឡាយ លើកទំនប់ ទាំងយប់ទាំងថ្ងៃ ហើយដេកមិនបានគ្រប់គ្រាន់ទេ។ ចំណែករបបអាហារ អង្គការផ្ដល់ឲ្យខ្ញុំតែបបរលាយជាមួយពោត និងដើមចេក។ ការហូបមិនបានគ្រប់គ្រាន់ និងធ្វើការងារហួសកម្លាំង ធ្វើឲ្យខ្ញុំមានជំងឺគ្រុនចាញ់ រាកមូល គ្មានថ្នាំព្យាបាល។ ចំណែកអ្នកខ្លះធ្លាក់ខ្លួនឈឺ និងបាត់បង់ជីវិតជាច្រើន ប៉ុន្តែអង្គការបែរជាចោទខ្ញុំនិងអ្នកទាំងនោះថាធ្វើពុត ហើយយកទៅរៀនសូត្រ។

នៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមចូលមករំដោះប្រទេសប្រជាជនកម្ពុជាចេញពីរបបខ្មែរក្រហម។ ពេលនោះ ប្រជាជនមានការច្របូកច្របល់ជាខ្លាំង ចំណែកគ្រួសាររបស់ខ្ញុំដែលភិតភ័យក៏នាំគ្នារត់គេចពីភូមិឆ្ពោះទៅទិសខាងកើត។ ខ្ញុំឃើញកងទ័ពវៀតណាមបាចត្រាក់ពីលើអាកាស ដែលមានអត្ថន័យថា «បងប្អូនជនរួមជាតិទាំងអស់ កុំភ័យខ្លាចអី អង្គការរណសិរ្សមករំដោះបងប្អូនខ្មែរយើងហើយ»។ ក្រោយពីរបបខ្មែរក្រហមដួលរលំ គ្រួសារខ្ញុំក៏ត្រឡប់មកស្រុកកំណើតរស់នៅជុំគ្នា និងប្រកបមុខរបរធ្វើស្រែចម្ការសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរហូតមកដល់បច្ចុប្បន្ន។

# ការិយាល័យព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!















# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលបានការសរសើរទៅលើកិច្ចសហការអង្គការជាដៃគូក្នុងការជំរុញការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្នុងដាក់តាំងពិព័រណ៍ស្តីពីស្លាដែសិស្សថ្នាក់ទី១២នៃវិទ្យាល័យ ហ៊ុន សែន ស្គន់ និងពិធីបើកបវេសនកាលឆ្នាំសិក្សា២០២៣-២០២៤

**សាំង ចាន់ធូ**







នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តាំងពិព័រណ៍នៅវិទ្យាល័យស្គន់ ដែលពិព័រណ៍នេះបែងចែកជា៣ផ្នែក រួមមាន៖ ពិព័រណ៍រូបថតអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ចំនួន៨០ផ្ទាំង, ការចាក់បញ្ចាំងវីដេអូឯកសារ និងការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» រួមជាមួយទស្សនាវដ្តីស្វែងរកការពិត បោះពុម្ពលេខពិសេស ឆ្នាំ២០២៣ សម្រាប់ចុះផ្សាយរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីខ្មែរក្រហមនៅខេត្តកំពង់ចាម។ (លី ដេវិត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អស់រយៈពេលជិត៣ឆ្នាំ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ត្រូវបានដាក់ឲ្យដំណើរការ និងដើរតួនាទីជាមជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំសម្រាប់សិស្ស-និស្សិត អ្នកស្រាវជ្រាវ និងសាធារណជនជាពិសេសអ្នកដែលរស់នៅក្នុងខេត្តកំពង់ចាម។ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបន្តអនុវត្តកិច្ចការងារស្នូលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅតាមមូលដ្ឋាន ក្នុងការចងក្រងឯកសារ អប់រំ និងផ្សព្វផ្សាយឯកសារស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ក្នុងឆ្នាំ២០២៣នេះ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបានធ្វើការផ្សព្វផ្សាយ និងអប់រំប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈកម្មវិធីអប់រំបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)







នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តាំងពិព័រណ៍នៅវិទ្យាល័យស្គន់ ដែលពិព័រណ៍នេះបែងចែកជា៣ផ្នែក រួមមាន៖ ពិព័រណ៍រូបថតអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន៨០ផ្ទាំង, ការចាក់បញ្ចាំងវីដេអូឯកសារ និងការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» រួមជាមួយទស្សនាវដ្តីស្វែងរកការពិត បោះពុម្ពលេខពិសេស ឆ្នាំ២០២៣ សម្រាប់ចុះផ្សាយរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីខ្មែរក្រហមនៅខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយមានការចូលរួមពីសិស្សានុសិស្សជាច្រើនមកពីវិទ្យាល័យនានាក្នុងខេត្តកំពង់ចាម។

វិទ្យាល័យ ហ៊ុន សែន ស្គន់ ដែលជាវិទ្យាល័យដ៏ចំណាស់មួយបង្កើតនៅឆ្នាំ១៩៦៣ ស្ថិតនៅក្នុងចំណោមវិទ្យាល័យដែលផ្តល់កិច្ចសហការក្នុងការអនុញ្ញាតឲ្យសិស្ស ដែលរៀនថ្នាក់ទី១២ ចូលរួមកម្មវិធីអប់រំស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩) របស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ លោក ខូវ ណារិន នាយករងវិទ្យាល័យ ហ៊ុន សែន ស្គន់បានលើកឡើងថា «កម្មវិធីអប់រំស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម គឺពិតជាមានសារសំខាន់សម្រាប់សិស្សានុសិស្សរៀនថ្នាក់ទី១២ ដើម្បីបង្កើនចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជា ដែលបន្តជាការត្រៀមលក្ខណៈរួចជាស្រេចក្នុងការប្រឡងមធ្យម-សិក្សាទុតិយភូមិ»។ ឆ្លៀតឱកាសនោះ លោក ខូវ ណារិន បញ្ជាក់អំពីលទ្ធផលដែលសិស្សថ្នាក់ទី១២ ទទួលបានក្នុងការប្រឡងមធ្យមសិក្សាទុតិយភូមិនាពេលថ្មីៗនេះថា៖ «លទ្ធផលនៃការប្រឡងរបស់សិស្សថ្នាក់ទី១២នាពេលនេះ គឺយើងមានការពេញចិត្ត ពីព្រោះសិស្សចំនួន៤នាក់ ទទួលបាននិទ្ទេស A

ដែលជាការកើនឡើងចំនួន និងជាកំណត់ត្រារបស់វិទ្យាល័យដែលសិស្សអាចទទួលបាននិទ្ទេស A សរុបចំនួន៤នាក់។ នេះគឺជាមោទកភាពសម្រាប់វិទ្យាល័យយើងខ្ញុំ។ លោក ខូវ ណារិន បន្ថែមថា តំណាងវិទ្យាល័យ ហ៊ុន សែន ស្គន់ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការដៃគូ ដូចជា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលតែងតែបង្កើតកម្មវិធីអប់រំបន្ថែមក្នុងការដឹកនាំសិស្សថ្នាក់ទី១២ ទៅទស្សនកិច្ចសិក្សាផ្ទាល់ជាក់ស្តែងនៅទីតាំងប្រវត្តិសាស្ត្រ នេះគឺជាការជំរុញដល់ការយល់ដឹងរបស់សិស្សបន្ថែមទៀត»។

ជាមួយកិច្ចសហការកន្លងមក មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលបានការស្នើសុំចូលរួមការដាក់តាំងពិព័រណ៍ស្តីពីស្នាដៃសិស្សថ្នាក់ទី១២នៃវិទ្យាល័យ ហ៊ុន សែន ស្គន់ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣នេះ ដែលជាថ្ងៃបើកបវេសនកាលឆ្នាំសិក្សា២០២៣-២០២៤។ កម្មវិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី និងពិព័រណ៍ស្នាដៃសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុនសែន ស្គន់មានការអញ្ជើញចូលរួមជាគណៈអធិបតីរបស់លោក ឆាយ វ៉ាន់ស៊ី ប្រធានក្រុមប្រឹក្សាស្រុក និងលោក អួត ឈាងលី អភិបាលនៃគណៈអភិបាលស្រុកជើងព្រៃ ព្រមទាំងមានការចូលរួមរបស់លោកគ្រូ/អ្នកគ្រូ និងសិស្សានុសិស្ស។ ក្នុងឱកាសនេះ លោកអភិបាលស្រុក បានអានសារលិខិតរបស់សម្តេចបវរធិបតីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបានផ្តាំផ្ញើដល់សិស្សានុសិស្សត្រូវយកចិត្តទុកដាក់ខិតខំរៀនសូត្រជៀសឆ្ងាយពីគ្រឿងញៀន និងអំពើខុសច្បាប់ទាំងឡាយ ដើម្បីក្លាយខ្លួនជាយុវជនល្អសម្រាប់គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។

ក្នុងនាមជាអង្គការដៃគូរបស់វិទ្យាល័យ ហ៊ុន សែន ស្គន់ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានចូលរួមចំណែករៀបចំពិព័រណ៍របស់ខ្លួនដែលបែងចែកជា៣ផ្នែក រួមមានៈ ពិព័រណ៍រូបថតអំពីប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ចំនួន៨០ផ្ទាំង, ការចាក់បញ្ចាំងវីដេអូឯកសារ និងការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ រួមជាមួយទស្សនាវដ្តីស្វែងរកការពិត បោះពុម្ពលេខពិសេស ឆ្នាំ២០២៣ សម្រាប់ចុះផ្សាយសាច់រឿងរបស់អ្នករស់រានមានជីវិតពីខ្មែរក្រហមនៅខេត្តកំពង់ចាម។ បន្ថែមលើនេះទៀត មជ្ឈមណ្ឌលឯកខេត្តកំពង់ចាម រៀបចំដាក់តាំងបង្ហាញសៀវភៅបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ សិស្សសរុបជិត៥០០នាក់ ចូលទស្សនាពិព័រណ៍ និងអានសៀវភៅដែលត្រូវបានដាក់តាំងបង្ហាញ។ ជាការកត់សម្គាល់នៅក្នុងការដើរទស្សនាពិព័រណ៍ និងអានសៀវភៅនេះ សិស្សជាច្រើនចាប់អារម្មណ៍ និងអានសៀវភៅដែលទើបតែត្រូវបានបោះពុម្ពជាពិសេសនាពេលថ្មីៗនេះ មានចំណងជើងថា «ជីវិតម្តាយខ្ញុំ កែវ ណាន»។

ក្នុងអំឡុងពេលដើរចូលទស្សនាផ្នែកពិព័រណ៍រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម សិស្សឈ្មោះ ឡូន ពេជ្រ រៀនថ្នាក់ទី១២ នៅឆ្នាំ



នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តាំងពិព័រណ៍នៅវិទ្យាល័យស្គន់ ដែលពិព័រណ៍នេះបែងចែកជា៣ផ្នែក រួមមានៈ ពិព័រណ៍រូបថតអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន៨០ផ្ទាំង, ការចាក់បញ្ចាំងវីដេអូឯកសារ និងការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» រួមជាមួយទស្សនាវដ្តីស្វែងរកការពិត បោះពុម្ពលេខពិសេស ឆ្នាំ២០២៣ សម្រាប់ចុះផ្សាយរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីខ្មែរក្រហមនៅខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សិក្សាថ្មី២០២៣-២០២៤នេះ បង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា ៖ «ខ្ញុំមានអារម្មណ៍សប្បាយរីករាយ នៅពេលដែលឃើញសិស្សទាំងអស់ចូលរួមការបើកបវេសនកាលឆ្នាំសិក្សាថ្មី និងទស្សនាការដាក់តាំងពិព័រណ៍ស្នាដៃរបស់សិស្ស និងការដាក់តាំងសៀវភៅ និងរូបភាពប្រវត្តិសាស្ត្ររៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមៗ នេះគឺជាលើកទីមួយដែលមានការដាក់តាំងពិព័រណ៍ និងសៀវភៅប្រវត្តិសាស្ត្រនៅក្នុងវិទ្យាល័យ»។

សិស្សម្នាក់ទៀតឈ្មោះ ចិន ចរិយា រៀនថ្នាក់ទី១២ ឆ្នាំសិក្សាថ្មី២០២៣-២០២៤នេះ និយាយថា៖ «ខ្ញុំមានអារម្មណ៍រំភើប និងថ្មីចំពោះការដាក់តាំងពិព័រណ៍យ៉ាងសម្បូរបែប ដែលមានទាំងការដាក់បង្ហាញស្នាដៃ និងសមិទ្ធផលសិស្សថ្នាក់ទី១២ និងការដាក់តាំងរូបថតប្រវត្តិសាស្ត្រ, ការដាក់បង្ហាញសៀវភៅ និងការចាក់បញ្ចាំងវីដេអូឯកសារៗ ជាចុងក្រោយ ខ្ញុំសូមឲ្យមានការដាក់តាំងពិពណ៌បែបនេះបន្តទៀតជារៀងរាល់ឆ្នាំ»។







នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម តាំងពិព័រណ៍នៅវិទ្យាល័យស្គន់ ដែលពិព័រណ៍នេះបែងចែកជា៣ផ្នែក រួមមាន៖ ពិព័រណ៍រូបថតអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន៨០ផ្ទាំង, ការចាក់បញ្ចាំងវីដេអូឯកសារ និងការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» រួមជាមួយទស្សនាវដ្តីស្វែងរកការពិត បោះពុម្ពលេខពិសេស ឆ្នាំ២០២៣ សម្រាប់ចុះផ្សាយរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីខ្មែរក្រហមនៅខេត្តកំពង់ចាមៗ ។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស៊ីន សាលីន ៖ ខ្ញុំបាត់បងប្រុសម្នាក់ធ្លាប់ធ្វើពេទ្យក្នុងរបបខ្មែរក្រហម

ឈុំ រ៉ា

ខ្ញុំឈ្មោះ ស៊ីន សាលីន អាយុ ៥៧ឆ្នាំ កើតនៅភូមិតាម៉ៅកើត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ សែ ស៊ីន ត្រូវបានខ្មែរក្រហមសម្លាប់ និងម្តាយឈ្មោះ សួង ឆេង។ ខ្ញុំមានបងប្អូនចំនួន៨នាក់ស្លាប់៣នាក់ បច្ចុប្បន្ន នៅរស់ចំនួន៥នាក់ ក្នុងនោះមានស្រីចំនួន៣នាក់។ ខ្ញុំមានប្តី និងមានកូនចំនួន៥នាក់។



ស៊ីន សាលីន អាយុ៥៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិតាម៉ៅកើត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ (ឈុំ រ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីកុមារ ខ្ញុំបានចូលរៀនជាមួយក្មេងៗនៅរោងវែងមួយស្ថិតនៅចំកណ្តាលភូមិជិតកន្លែងសហករណ៍ ព្រោះភូមិខ្ញុំមិនមានសាលារៀនទេ។ ក្នុងមួយថ្ងៃខ្ញុំរៀនមួយម៉ោង ហើយមិនបានរៀនអ្វីច្រើនទេ គឺរៀនតែអក្សរ៥តួប៉ុណ្ណោះ ចំណែកគ្រូបង្រៀនមកពីកន្លែងផ្សេងៗ។ ពេលម៉ោង១០ព្រឹក ខ្មែរក្រហមវាយជួងឲ្យក្រុមខ្ញុំ និងក្មេងៗដទៃទៀតហូបអាហាររួចហើយត្រៀមចេញទៅឃ្វាលគោ។ នៅឆ្នាំ១៩៧៤ ប្រជាជននាំគ្នាធ្វើស្រែចម្ការប្រវាស់ដៃ និងបានផលចែកតាមសមាជិកគ្រួសារ។ ពេលនោះ យើងហូបបាយតាមផ្ទះរៀងខ្លួន រីឯរបស់របរមិនទាន់ប្រមូលដាក់រួមទេ។

នៅចុងឆ្នាំ១៩៧៤ ទើបប្រធានសហករណ៍ប្រកាសប្រាប់ប្រជាជននៅក្នុងភូមិប្រមូលរបស់របរតាមគ្រួសារនីមួយៗមកដាក់នៅកន្លែងសហករណ៍។ មានថ្ងៃខ្លះ ខ្ញុំបានហូបបាយ និងថ្ងៃខ្លះទៀតខ្ញុំហូបបបរ។ ខ្ញុំបានឮប្រធានសេដ្ឋកិច្ចក្នុងសហករណ៍និយាយថា ប្រជាជនរស់នៅក្នុងភូមិគឺឲ្យហូបបបរ ព្រោះទុកស្រូវអង្ករសម្រាប់នាំចេញទៅក្រៅ។

នៅខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនពីទីក្រុងភ្នំពេញឲ្យមករស់នៅភូមិតាម៉ៅកើត ក្នុងឃុំជាំតាម៉ៅ និងមួយចំនួនទៀតទៅរស់នៅភូមិផ្សេងៗក្នុងឃុំជាំតាម៉ៅដដែល។ ពេលនោះខ្ញុំនៅជាកុមារ ដូច្នេះពេលព្រឹកខ្ញុំត្រូវក្រោកឡើងទៅរើសអាចម៍គោ អាចម៍ក្របី សម្រាប់ធ្វើជីដាក់ស្រូវ ចំណែកថ្ងៃរសៀលខ្ញុំ និងកុមារប្រមាណ១០នាក់ ទៀតចេញទៅឃ្វាលគោ និងក្របី ទាល់ល្ងាចបាននាំគ្នាដេញក្របីត្រឡប់មកភូមិវិញ។ ចាប់តាំងពីពេលខ្មែរក្រហមជម្លៀសអ្នកភ្នំពេញមកនៅក្នុងភូមិ ខ្ញុំលែងបានរៀនសូត្រ ហើយគ្រូធ្លាប់បង្រៀនខ្ញុំកន្លងមកត្រូវបានខ្មែរក្រហមផ្លាស់ទៅកន្លែងផ្សេង។ ខ្ញុំធ្លាប់បានឃើញប្រជាជនមកពីភ្នំពេញមានសម្បុរសជ្រះ ខុសពីប្រជា-ជននៅមូលដ្ឋាន។ ដំបូងខ្មែរក្រហមបានបែងចែកប្រជាជនជម្លៀស ទាំងនោះនៅតាមផ្ទះ ហើយផ្ទះខ្ញុំមានអ្នកភ្នំពេញពីរគ្រួសារ។ អ្នកភ្នំពេញទាំងនោះស្លូតបូត ហើយមិនសូវចេះធ្វើស្រែដូចប្រជា-ជននៅក្នុងភូមិទេ។ ពីមួយថ្ងៃទៅមួយថ្ងៃ ប្រជាជនជម្លៀសទាំងនោះចេះធ្វើ

ការងារកាន់តែស្ទាត់ជំនាញៗ ក្នុងកងចល័តពេលនោះគឺមានប្រជាជនច្រើននាក់ត្រូវលើកប្រព័ន្ធភ្លឺស្រែនៅខាងលើភូមិតាម៉ៅ ហើយទំហំភ្លឺស្រែគឺធំជាងភ្លឺស្រែបច្ចុប្បន្ននេះបីដង។ ចំណែកកន្លែងដេក គឺមនុស្សប្រុស និងមនុស្សស្រីដេកនៅកន្លែងខុសគ្នាលើកលែងតែពេលទៅធ្វើការងារគឺកន្លែងជាមួយគ្នា។ នៅភូមិតាម៉ៅកើត ឃុំជាំតាម៉ៅ ខ្មែរក្រហមបានបែងចែកកម្លាំងជាបីប្រភេទ គឺ ១) កងកុមារ ២) កងចល័ត និង ៣) កងមនុស្សចាស់ ចំណែកខ្ញុំនៅក្នុងកងកុមារ។ ចំពោះកងចល័តមានមនុស្សចាប់ពី២០នាក់ ទៅ៣០នាក់ លើកប្រព័ន្ធភ្លឺស្រែចាប់ពីម៉ោងព្រឹក៧ ដល់ម៉ោង១១ ទើបឡើងហូបបាយនៅរោងសហករណ៍ភូមិតាម៉ៅកើតទាំងអស់គ្នា។ ពេលរសៀល ខ្ញុំធ្វើការចាប់ពីម៉ោង១ ដល់ម៉ោង៥ល្ងាច ទើបឈប់សម្រាក និងត្រឡប់មកសហករណ៍វិញ។ ចំពោះការហូបចុកក្នុងសហករណ៍មានពីរពេល គឺពេលថ្ងៃ និងពេលល្ងាច។

នៅពាក់កណ្តាលឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលមកដល់ក្នុងភូមិ ហើយចាប់ប្រជាជនទាំងអស់ដែលធ្លាប់ធ្វើការងារក្នុងរបប លន់ នល់ រួមជាមួយគ្រូបង្រៀន គ្រូពេទ្យ អ្នកធ្វើការងារក្នុងឃុំជាំតាម៉ៅ និងមន្ត្រីមួយចំនួនដែលខ្មែរក្រហមចាត់ទុកជាសត្រូវ។ អំឡុងពេលខ្មែរក្រហមចូលមកក្នុងភូមិ ខ្ញុំបានចេញពីផ្ទះទៅឃ្វាលគោនៅវាលស្រែ ហើយពេលត្រឡប់មកផ្ទះវិញ ម្តាយខ្ញុំបាននិយាយប្រាប់ខ្ញុំថា ឪពុកកូនត្រូវបានកងទ័ពខ្មែរក្រហមចាប់ចងស្លាបសេក យកទៅឃុំឃាំងនៅសាលាឃុំជាំតាម៉ៅ ព្រោះនៅឆ្នាំ១៩៧៥ ឪពុកខ្ញុំធ្វើជាប្រធានសហករណ៍ក្នុងភូមិតាម៉ៅកើត។ ប្រជាជននៅក្នុងភូមិតាម៉ៅកើតដែលត្រូវបានខ្មែរក្រហមចាប់ខ្លួន មានចំនួន៥នាក់ គឺឪពុករបស់ខ្ញុំឈ្មោះ សែស៊ីន, តាកុក, តាឆ្នួញ, តាអំ និង ពូសីងរី ឯភូមិតាម៉ៅជើងមានពូហឹនចំណែកនៅឃុំជាំតាម៉ៅ រួមមាន តា ឡាយ និង តាភូមិ។ មានមនុស្សជាច្រើនទៀតក៏ត្រូវបានចាប់ខ្លួនឃុំឃាំង បន្ទាប់មកខ្មែរក្រហមយកឡានមកដឹកអ្នកទាំងនោះទៅស្រុកស្នួល ខេត្តក្រចេះ។ ក្រោយពីឪពុកខ្ញុំត្រូវខ្មែរក្រហមចាប់ ទាំងគ្មានកំហុសបានរយៈពេល៣ខែខ្មែរក្រហមក៏បានជម្លៀសប្រជាជនដែលមកពីភ្នំពេញ និងប្រជាជនភូមិតាម៉ៅកើត ចេញទាំងអស់ ដោយអ្នកខ្លះធ្វើដំណើរដោយរទេះ និងខ្លះទៀតធ្វើដំណើរថ្មើរជើង ហើយចំពោះគ្រួសារខ្ញុំជិះរទេះ។ ពេលគ្រួសារខ្ញុំទៅដល់ភូមិកូនក្រពើ គឺជិតល្ងាចហើយ ដូច្នេះប្រធានក្រុមមកពីតំបន់ផ្សេងបានប្រាប់ប្រជាជនទាំងអស់ឈប់សម្រាកសិនចាំព្រឹកចាំបន្តដំណើរទៅមុខទៀត។ នៅភូមិកូនក្រពើ ឃុំជាំតាម៉ៅ យើងនាំគ្នាដេកតាមព្រៃ ដោយកាច់ស្លឹកឈើយកមកក្រាលដេកមួយយប់រង់ចាំរហូតដល់ព្រឹកឡើងទើបយើងចេញដំណើរទៅភូមិស្អាត ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំឈប់សម្រាកក្នុងផ្ទះប្រជាជននៅភូមិស្អាត ប៉ុន្តែផ្ទះដែលខ្ញុំ និងគ្រួសារស្នាក់មិនមានមនុស្សរស់នៅទេ ហើយខ្ញុំក៏មិនដឹងថា ម្ចាស់ផ្ទះត្រូវខ្មែរក្រហមជម្លៀសចេញតាំងពីពេលណាដែរ។ បងស្រីរបស់ខ្ញុំម្នាក់ឈ្មោះ ស៊ីន ញិប មិនបានមកជាមួយខ្ញុំទេ ព្រោះគាត់ធ្វើការក្នុងកងចល័តនៅកន្លែងផ្សេង។ ខ្ញុំចេញពីឃុំស្រែចារ ដោយជិះរទេះរយៈពេលបីថ្ងៃទើបទៅដល់ភូមិកាត់ដៃឃុំស្នួលស្រុកស្នួលខេត្តក្រចេះ។ ខ្ញុំស្នាក់នៅភូមិកាត់ដៃបានចំនួន៥ថ្ងៃ ស្រាប់តែមានកងទ័ពធ្លាប់ស្នាក់នៅផ្ទះខ្ញុំពីមុនមក បានមកប្រាប់ម្តាយ និងគ្រួសារខ្ញុំថា ឪពុកខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់នៅចម្ការក្រូច ចម្ងាយប្រមាណ២គីឡូម៉ែត្រពីភូមិកាត់ដៃ។ ពេលខ្ញុំនិងម្តាយបានឮដំណឹងនេះភ្លាម ម្តាយខ្ញុំគិតតែពីយំ និងអស់សង្ឃឹមយ៉ាងខ្លាំង ព្រោះមិនមានអ្នកចិញ្ចឹមកូនតូចៗ។

នៅចុងឆ្នាំ១៩៧៦ ខ្មែរក្រហមជម្លៀសខ្ញុំនិងក្រុមគ្រួសារចេញពីភូមិកាត់ដៃឲ្យទៅនៅស្រែព្រីង ក្នុងស្រុកស្នួល ខេត្តក្រចេះ ចំណែកគោ និងរទេះត្រូវបានខ្មែរក្រហមយកទាំងអស់។ អំឡុងខែវស្សាមានភ្លៀងធ្លាក់រាល់ថ្ងៃ ដូច្នេះយើងត្រូវសង់ខ្ទមតូចមួយនៅក្នុងព្រៃផុតពីទឹក ព្រោះខែវស្សាកន្លែងណាក៏មានទឹកដែរ ហើយម៉្យាងទៀតខ្លាចសត្វពស់ខ្យាដំរី ចឹក ឬទិច។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជីសម្រាប់ដាក់ដំណាំ និងស្រូវ ចំណែកម្តាយខ្ញុំពេលព្រឹកត្រូវចេញទៅដកស្ទូងនៅវាលស្រែ។ ចំពោះការហូបចុកនៅស្រែព្រីងពិបាកខ្លាំងណាស់ ព្រោះមិនមានអង្ករសម្រាប់ដាំបាយ ហូប។ ខ្មែរក្រហមប្រាប់យើងថា អង្ករយើងនៅសល់មួយចំនួនតូចសម្រាប់ផ្គត់ផ្គង់កងកម្លាំងចេញទៅសមរភូមិមុខ ចំណែកសមមិត្តទាំងអស់គ្នាត្រូវដើររកក្តួច ដំឡូងមកលាយជាមួយបបរ។ ខ្ញុំត្រូវចេញទៅរកក្តួចយកមកហូបបន្ថែម ហើយដោយសារតែការស្រេកឃ្លានខ្លាំងពេក ទើបខ្ញុំយកក្តួចទៅចម្អិនហូបទាំងមិនទាន់សាបជាតិពុល។ បន្ទាប់ពីហូបក្តួចរួច ប្រហែលមួយម៉ោងក្រោយមកខ្ញុំមានអារម្មណ៍មិនស្រួលខ្លួន។ ខ្ញុំពុលក្តួច ដោយរកកល់ចង់ដេកបន្តិច និងឈឺក្បាលបន្តិចៗ។ ចាប់តាំងពីពេលនោះមក ខ្ញុំស្អប់ក្តួច និងស្អប់បបរមកដល់សព្វថ្ងៃ។ ចំពោះបបរ ពេលខ្ញុំឈឺហើយពេទ្យតម្រូវឲ្យខ្ញុំហូបបបរក៏ខ្ញុំមិនហូបដែរ គឺខ្ញុំសុខចិត្តអត់ ព្រោះខ្ញុំស្អប់បបរតាំងពីសម័យខ្មែរក្រហម។ នៅក្នុងមួយថ្ងៃខ្ញុំហូបអាហារ

ពីរពេល គឺមានតែអង្ករបួនដប់គ្រាប់លាយជាមួយទឹករាវៗ ហើយនៅក្នុងម្នាក់ទទួលបានបបរកន្ទះកូនការៗ ខ្ញុំឃើញតាជាន់ គឺជាអ្នកភូមិតាម៉ៅជាមួយខ្ញុំ បានចេញទៅលួចកាប់ពោតយកមកដុតហូប ព្រោះគាត់ឃ្លានខ្លាំងពេក ប៉ុន្តែមិនទាន់បានហូតពោតផងស្រាប់តែខ្មែរក្រហមមកទាន់ក៏ចាប់គាត់យកទៅសម្លាប់ចោល។

ក្រោយមក ខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំឲ្យទៅរស់នៅភ្នំព្រិចវិញ។ នៅទីនោះ ខ្មែរក្រហមបានចោទប្រកាន់ម្ដាយខ្ញុំថា បន្កភាពចលាចលដោយបបួលគ្នារត់ទៅប្រទេសវៀតណាម។ ព្រឹកឡើងមានកម្មាភិបាលបីនាក់ចូលមកចាប់ម្ដាយខ្ញុំ និងមនុស្សប្រុសចំនួន៥នាក់ទៀត ចេញពីភ្នំព្រិចដើម្បីយកទៅសួរចម្លើយមួយថ្ងៃពេញ ទើបឲ្យត្រឡប់មកផ្ទះវិញ។

ចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ខ្ញុំនិងគ្រួសារទៅរស់នៅភូមិកោះរង៉ាវ ឃុំកំពង់ក្របី ស្រុកសំបូរ ខេត្តក្រចេះ ដោយនៅសងខាងកោះមានទឹកទន្លេព័ទ្ធជុំវិញ។ ខ្ញុំរស់នៅទីនោះបានរយៈពេលមួយខែស្រាប់តែបានជួបបងស្រីខ្ញុំឈ្មោះ ស៊ីន ញិប ធ្វើជាកងចល័តនៅកោះរង៉ាវ ហើយក្រោយមកខ្មែរក្រហមឲ្យឈប់ធ្វើកងចល័តមកដាំដំណាំបន្លែបន្ការវិញ។ នៅទីនោះ ខ្ញុំក៏ដាំបន្លែ ដូចជាត្រប់ សណ្ដែក និង ពោតដែរ។ ខ្ញុំនៅកោះរង៉ាវបានយូរជាងកន្លែងផ្សេងៗ បន្ទាប់មកទើបខ្ញុំចេញទៅថ្មក្រែរង់ចាំកប៉ាល់ដឹកទៅស្រុកស្ទឹងត្រង់។ ពេលមកដល់ស្រុកស្ទឹងត្រង់ មានឡានមកដឹកគ្រួសារខ្ញុំនិងគ្រួសារពីរទៀតបន្តទៅស្រុកចម្ការលើ។ ប្រហែលម៉ោង១២ថ្ងៃត្រង់ ទើបខ្ញុំទៅដល់ស្រុកចំការលើ ខេត្តកំពង់ចាម ដោយមានអ្នកភូមិមកទទួល និងឲ្យចេកហាលមកខ្ញុំ និងគ្រួសារហូបម្នាក់មួយឆ្អែត។ ប្រធានសហករណ៍នៅស្រុកចំការលើ បែងចែកប្រជាជនជាក្រុម ហើយក្រុមខ្ញុំគឺត្រូវបានចាត់តាំងឲ្យទៅដឹកដំឡូងចំណែកបងស្រីនិងម្ដាយទៅច្រូតស្រូវ។ ខ្ញុំរស់នៅទីនោះរហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមកដល់ ហើយព្រឹកឡើងក៏ប្រកាសឲ្យប្រជាជនត្រឡប់ទៅស្រុកកំណើតរៀងខ្លួនវិញ។ ខ្ញុំដើរចេញពីស្រុកចំការលើទៅសម្រាកទីរួមខេត្តកំពង់ចាមមួយយប់។ នៅថ្ងៃបន្ទាប់ក៏មានរថយន្តកងទ័ពវៀតណាមដឹកខ្ញុំ និងក្រុមគ្រួសារពីទីរួមខេត្តកំពង់ចាមទៅដាក់នៅស្ទួង ហើយត្រូវខ្ញុំបន្តដំណើរដោយថ្មើរជើងរហូតដល់ផ្ទះ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានបាត់បង់បងប្រុសឈ្មោះ ស៊ីន នី ធ្លាប់ធ្វើជាគ្រូពេទ្យនៅស្រុកមេមត់ បន្ទាប់ពីខ្មែរក្រហមចូលមកដល់គាត់ឈប់ពីគ្រូពេទ្យមកចូលធ្វើជាកងទ័ពវិញ ហើយចាប់តាំងពីពេលនោះមកបងប្រុសខ្ញុំបាត់ខ្លួនរហូតមកដល់សព្វថ្ងៃ។



កង់រទេះនៅផ្ទះ ស៊ីន សាលីន។
( ឈុំ រ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា )



ឧបករណ៍នេសាទបែបបុរាណ
ដែលប្រជាជនអាចយកមកគ្រងមាន់
ឬ ធ្វើសប្បុកមាន់ៗ
( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

*រូបក្របមុខ និង រូបក្របក្រោយ ៖*
*ប្រជាជនកម្ពុជាវិលត្រឡប់មកផ្ទះសម្បែង និងភូមិកំណើតវិញ*
*បន្ទាប់ពីរបបខ្មែរក្រហមខ្មែរក្រហម ដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 288, December 2023 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.